# សេចក្ដីពោរពេញរបស់ព្រះត្រូវបានពន្យល់

សូមអរគុណប្អូនប្រុស ខាលសាន់។ និងសូមស្វាគមន៍បងប្អូនទាំងអស់ និងបងប្អូនបម្រើព្រះអម្ចាស់។ គ្រាន់តែជា...ខ្ញុំជួនកាលមានអារម្មណ៍ស្ទាក់ស្ទើរ បន្តិចក្នុងការក្រោកឡើង ពេលខ្ញុំបានស្ដាប់ទីបន្ទាល់ដ៏អស្ចារ្យ ជាច្រើន និងមានបន្តទៀត ដូចអ្វីដែលដែលខ្ញុំបានធ្វើនៅព្រឹកនេះ។ ដូច្នេះហើយ ពលរដ្ឋនៅក្នុង ការរងទុក្ខនិងបៀតបៀនដូចជាបងប្អូនប្រុសស្រីបាបទីស្ទដែលបានឆ្លងកាត់ កាលពីមុន—ជា បាបទីស្ទទាំងខ្លួនខ្ញុំផ្ទាល់ជាបេសកជនបាបទីស្ទ និង—និងដឹងថាវាមានន័យយ៉ាង ណាពេលមនុស្សរបស់អ្នក...

2 ខ្ញុំមានអ្វីដូចគ្នា។ មនុស្សរបស់ខ្ញុំបែរចេញពីខ្ញុំ និងពួកគេគិតថាពួកគេបញ្ជូនខ្ញុំចេញព្រោះខ្ញុំឆ្កួតហើយ។ ហើយខ្ញុំក៏បានរកឃើញ និងជាធម្មតាខ្ញុំនិយាយវាជាបែបផ្លូវវង្វង់ "បើខ្ញុំឆ្កួតទុកឲ្យខ្ញុំនៅម្នាក់ឯងចុះ ព្រោះខ្ញុំរីករាយភាពជាបែបនេះជាងកាលខ្ញុំមានគំនិតត្រឹមត្រូវ" ដូច្នេះនោះគឺ ជាបែបទស្សនៈវិជ្ជាបន្តិចដែលខ្ញុំកាន់ខ្ជាប់ផ្ទាល់ខ្លួនរបស់ខ្ញុំ។ និង—ហើយ ខ្ញុំពិតជារីករាយបែបនេះណាស់—ពេលនេះក្នុងរបៀបនេះ។

3 ហើយបងប្អូនមកពីក្រុមជំនុំនៃព្រះគ្រីស្ទតូចមួយនៅទីនេះ ជាធម្មតាសំដៅលើវា ឬជាក្រុមចលនាស្ដារឡើងវិញ។ និងចងចាំពួកគេជា អ្នកខិតខំប្រឹងប្រែងទាស់ប្រឆាំងយ៉ាងខ្លាំង ពេលដែលការប្រជុំចាប់ផ្ដើម។ ប៉ុន្តែអ្នកដឹងទេយើងមានម្នាក់ឈ្មោះប៉ុល មានពេលមួយរបៀបដូចគ្នា ហើយគាត់ក៏ក្លាយជា ម្នាក់ក្នុងចំណោមយើង។ ដូច្នេះ នោះជាការពិត។ ខ្ញុំគិតថាអ្វីដែលពួកគេតែងតែស្វែងរកគឺជីវិតអ្នករស់នៅ។ អ្នកដឹងថាវាប្រសើជាងដែល ផ្សាយផ្ទាល់ពីខ្ញុំជៀសជាងអធិប្បាយពីខ្ញុំតែម្នាក់ ពេលណាក៏ដោយ។ ខ្ញុំ...

4 មានពេលមួយកន្លងទៅ អ្នកដឹកនាំធំម្នាក់ ជាបុរសពេញដោយ ដំណឹងល្អអ្នក—ទាំងអស់គ្នាស្គាល់ គាត់ខ្ញុំគិតថាចឹង គឺលោកបុព្វជាចារ្យប៊ូតក្លីប័ន (Rev.Booth-Clibborn) ដែលអាចអធិប្បាយដំណឹងល្អជាប្រាំពីរភាសាផ្សេងគ្នា។

គាត់ឆ្លាត។ ហើយខ្ញុំ...គាត់ជាយក្សខាងគំនិត។ ហើយយើងបានធ្វើ ដំណើរជាមួយគ្នាមួយរយៈហើយគាត់និងបងប្អូនប្រុសម័រ(Moore)ព្រមទាំងខ្ញុំបាន ពិភាក្សារឿងមួយ ចំនួន។ ខ្ញុំនៅទល់មុខជាមួយនឹងគាត់ ហើយគាត់មើលមកខ្ញុំ។ គាត់និយាយ "អ្នក មិនស្គាល់ព្រះគម្ពីរ របស់អ្នកឡើយ។" អ្នកអាចដឹងទេថា តើបងប្អូនប្រុសប៊ូត (Booth) អាចនិយាយមកបាន។

5 ខ្ញុំនិយាយ "នោះជាការពិតហើយបងប្អូនប្រុស ប៊ូទ ប៉ុន្តែខ្ញុំស្គាល់អ្នកនិពន្ធយ៉ាងច្បាស់" ដូច្នេះខ្ញុំ—ខ្ញុំចង់...អ្នកដឹងទេ មិនមែនស្គាល់តែព្រះបន្ទូលទ្រង់ជាជីវិតឡើយប៉ុន្តែ "គឺស្គាល់ទ្រង់គឺជីវិត" ជាការពិត។ ឃើញទេ? មិនថាខ្ញុំស្គាល់ព្រះបន្ទូលទ្រង់ បើខ្ញុំអាចស្គាល់ទ្រង់! ហើយនោះហើយជា ការពិតនៃសេចក្តីពិត។

6 ខ្ញុំគឺនៅព្រឹកនេះបានចាប់ដៃជាមួយ មនុស្សល្អៗរបស់គាត់នៅទីនេះ ដែលជាអ្នកដឹកនាំ។ ខ្ញុំអង្គុយនៅទីនេះ...ខ្ញុំមិនមាន ន័យថាធ្វើឲ្យនរណាម្នាក់លេចធ្លោនោះឡើយ។ ប៉ុន្តែបុរសជនជាតិ ស្បែកពណ៌ម្នាក់មក បងប្អូនប្រុសដែលអង្គុយនៅទីនោះ។ ខ្ញុំនិយាយទៅកាន់លេខាខ្ញុំទីនេះ "នោះជាគ្រីស្ទបរិស័ទពិត។"

7 អ្នកបានរំលឹកខ្ញុំយ៉ាងច្រើនពីលោកចាស់ទុំស្មីត(Smith)ដែលធ្លាប់នៅក្រុមជំនុំ ព្រះជាម្ចាស់ក្នុង ព្រះគ្រីស្ទខ្ញុំជឿ។ ខ្ញុំធ្លាប់អធិប្បាយយ៉ាងច្រើនពីពួកគេនៅទីនោះ ហើយ—ហើយខ្ញុំមិនទាន់ជួបគាត់នៅឡើយ។ គាត់ដូចជាអ្វីដែលបងប្អូននៅទីនេះ ខុស គ្នាត្រង់តែគាត់មានពុកមាត់ពណ៌ប្រផេះ។ ខ្ញុំចូលមកតាមទ្វាខាងក្រោយ ហើយខ្ញុំមិនដែលភ្លេចពីការបង្ហាញ នៃបុរសចាស់ម្នាក់ដែលបាននិយាយមើលទៅហើយពួកបរិសុទ្ធនឹងច្រៀងអ្នកដឹងទេ។ និងធ្លាប់មានក្មេងស្រីម្នាក់ច្រៀងផ្ទាល់នៅផ្លូវកាច់ជ្រុង។ ចម្រៀងដែលខ្ញុំចូលចិត្តគឺ *លើកទ្រង់ឡើង*។ ពួកគេទាំងអស់គ្នា ទះដៃបែបពេនទីកុស្តអ្នកស្គាល់ហើយ*លើកទ្រង់ឡើង*។ ពួកគេស្រឡាញ់ខ្ញុំហើយខ្ញុំក៏ ស្រឡាញ់ពួកគេដែរ។ ហើយពេលយើងដើរក្នុង... គាត់ធ្លាប់អង្គុយនៅទីនោះ ដែលមានក្បាលរបស់គាត់*បែបនេះ* នៅលើតុនិងមើលពួកគេអ្នកដឹងហើយ។ គាត់និយាយ "ចូលមក លោកចាស់ទុំ។ ទុកម្ហូកចុះ ។ ទុកមួយកចុះ។"

8 បងប្អូននៅទីនេះនិងខ្ញុំដឹងរួចមក នោះជាអ្នកចម្រៀង ដំណឹងល្អដែលខ្ញុំចូលចិត្តគឺជាប្រពន្ធរបស់គាត់។ ហើយខ្ញុំព្យាយាមរកវិធីតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យគាត់ច្រៀង។ តែគាត់ក៏បានស្នើរសុំ មិនឲ្យហៅគាត់ ហើយខ្ញុំដឹងថាវាមានន័យ

យ៉ាងណា។ ប៉ុន្តែខ្ញុំនឹងអញ្ជើញគាត់ដោយបុគ្គលផ្ទាល់ បើសិនជាគាត់អាច សូមមកហើយច្រៀងចុះ។

9 ល្អ តើមិនមែនបងប្អូនស្រីទេឬ ដែលច្រៀង—ច្រៀងថា *កាប៉ាល់ អាហូយ* នៅព្រឹកមួយនៅក្នុងក្រុមធុរៈកិច្ចគ្រីស្ទាន ឥឡូវ? [បងប្អូនស្រីនិយាយ "ចាស ចាស"—Ed]។ ខ្ញុំសង្ឃឹមថាប្រពន្ធខ្ញុំក្រោកនៅព្រឹកនេះហើយខ្ញុំចង់ឲ្យគាត់ស្ដាប់អ្នកដែរ ព្រោះខ្ញុំបានអួតច្រើនណាស់។ ហើយបើសិនជាអ្នកខកខានថតកាសែត យើងនឹងរៀបចំវា។ ខ្ញុំចូលចិត្តការច្រៀងនោះណាស់។

10 ហើយខ្ញុំធ្លាប់ប្រាប់មនុស្សថាខ្ញុំ—ខ្ញុំមិនអាចច្រៀងបានឡើយ។ អូ ខ្ញុំ ខ្ញុំនៅឆ្ងាយពីវារាប់លានម៉ាយ។ ប៉ុន្តែខ្ញុំនិយាយ "បើអ្នកបានទៅ ស្ថានសួគ៌និងរស់នៅក្នុងវាំងដ៏ធំរបស់អ្នក អ្នកដឹងទេ នៅទីនោះ" ខ្ញុំនិយាយ "តាមផ្លូវនៅខាងជើង ភ្នំនៅក្នុងព្រៃនៅទីនោះ មានបន្ទប់តូចមួយនៅទីនោះ។ នោះហើយវាជារបស់ខ្ញុំ។ ហើយមាន ព្រឹកមួយនៃចំណោមព្រឹកៗ បែបនេះពេលអ្នកដើរចេញទៅ វានហាល និងឮនរណា ម្នាក់ឈរច្រៀងនៅទីនោះ 'ព្រះគុណអស្ចារ្យ! ជាសព្ទពិរោះដែលប្រោសមនុស្ស យ៉ាងដូចខ្ញុំ!' អ្នកនិយាយ 'សរសើរព្រះអង្គ! ទីបំផុតបងប្អូនចាស់អ័ប្រាហាំ អាចធ្វើ បានហើយ'" វានឹងមានខ្ញុំនៅទីនោះស្ដាប់ និងព្យាយាមច្រៀង។

11 ចំពោះបងប្អូនគ្រីស្ទបរិស័ទរបស់ខ្ញុំ និងចំពោះ...ខ្ញុំជឿថា បងប្អូនម្នាក់ណែនាំគាត់មកយើង នៅព្រឹកនេះជា អ្នកដឹកនាំខាងពុទ្ធសាសនានៅទីនោះ។ គាត់សូមស្វាគមន៍ដល់បងប្អូនជាមិត្តសម្លាញ់ល្អរបស់ខ្ញុំ។ ហើយខ្ញុំបានធ្វើការងារជាច្រើនមិនច្រើនពេកទេជាមួយ មនុស្សអ្នក ខាងពុទ្ធសាសនា ជាពិសេសនៅកាណាដាចំណោម ប្រជាជនចិន ហើយខ្ញុំឃើញថាពួកគេ គួរឲ្យស្រឡាញ់ និងផ្អែមល្ហែម។

12 ខ្ញុំចាំថាមានបុរសពុទ្ធសាសនិកជនតូចម្នាក់ មកពីវិហារពុទ្ធសាសនា មកជួបយើងនៅការជួបជុំ វីននីផេក(Winnipeg) ហើយគាត់ងងិតភ្នែក។ គាត់តូចណាស់ ជាមនុស្សផ្អែមល្ហែម ហើយពួកគេជឿថាព្រះនិងប្រោសឲ្យជា។ និងពេលអធិស្ឋានសម្រាប់គាត់ហើយគាត់ក៏ថាតាមគាត់ស្រឡាញ់ព្រះជាមួយគ្នានោះភ្នែកគាត់ក៏បើកឡើង ក្នុង...និងវាដូចជា—រឿងដែលអស្ចារ្យ។ ដូច្នេះ យើង—យើងរីករាយជាមួយមនុស្សគ្រប់គ្នា និងបុគ្គលគ្រប់រូប។

13 ឥឡូវ ខ្ញុំមិនមានឱកាសនេះពីមុនឡើយ នៅក្នុងឈីកាហ្គោ ដើម្បីព្យាយាមនិយាយ...ដែលជាខ្ញុំប្រហែលជាមិនព្យាយាមនាំសារជាក់លាក់ណាមួយ ព្រោះអ្នកដឹកនាំទីនេះអាចធ្វើបានច្រើនជាងខ្ញុំ ដែលអាចនាំសារ។ ប៉ុន្តែ បន្ទាប់ពីរឿងទាំងអស់អ្នកមិននៅទីនេះដើម្បី ស្ដាប់សារឡើយ។ ប៉ុន្តែខ្ញុំគិតថាវាជាពេលនៃសិរីរុងរឿងដែលខ្ញុំអាចជួបអ្នកដឹកនាំ នៃឈីកាហ្គោនៅស្រុកនេះ និងមានការទាក់ទងគាត់បន្ថែមទៀតជាមួយពួកគាត់ និងមានទំនាក់ទំនងបន្ថែមទៀត។ និង ខ្ញុំពិតជាអរព្រះគុណព្រះអម្ចាស់សម្រាប់ឱកាសនេះ។ ព្រោះ ខ្ញុំមកក្នុងក្រុងនេះជា ច្រើនដងនៅទីនេះក្រោមការឧបត្ថម្ភនៃក្រុមជំនុំមួយនិងក្រោមការឧបត្ថម្ភក្រុមអ្នកជំនួញ គ្រី ស្ទាន(Christian Business Men) ដូច្នេះមិនមែនជាឱកាសដើម្បីបញ្ជាក់ខ្លួនឯងថាជាសម្ពន្ធ័បងប្អូននោះទេ។

14 និង—និងបន្ទាប់មកខ្ញុំគិត មានសេចក្ដីជាច្រើនដែល ខ្ញុំតែងតែដើរតាមព័ន្ធកិច្ចបែបនេះទាំងចេញនិងចូល ឡើងនិងចុះ រហូតដល់មានមនុស្ស មួយចំនួនងាយទាញទៅតាមការសម្ដែងចេញខុស។ និង ខ្ញុំចង់យកបែបនេះនៅពីរបីនាទីបន្ទាប់ដើម្បីព្យាយាមពន្យល់ និង—និងធ្វើវាអោយបានច្បាស់ដើម្បីបង្ហាញបងប្អូនរបស់ខ្ញុំច្បាស់ដូចរបៀបដែលបង្កើតវាឡើង។

15 និងខ្ញុំ—ខ្ញុំមិនបានស្កប់ចិត្តនិងមិនអាចធ្វើ—ការពិភាក្សា ដែលអាចមើលទៅដូចជាសមហេតុផលចំពោះមនុស្ស ដែលជាអ្នកមានការសិក្សាអប់រំ។ ខ្ញុំមិនមាន ការសិក្សាអប់រំឡើយ ហើយខ្ញុំមានការខ្វះខាតបែបនោះ។ ប៉ុន្តែខ្ញុំ...ស្រឡាញ់ព្រះអម្ចាស់។ និងព្រះអម្ចាស់ប្រទានឲ្យខ្ញុំ ប្រហែល របៀបផ្សេងទៀតដែលវាអាចបំពេញចន្លោះអ្វីដែលឪពុកម្ដាយរបស់ខ្ញុំមិនអាចផ្ដល់ឲ្យមកខ្ញុំ គឺការអប់រំ។ ចេញពីផ្ទះក្រីក្រ និងមានកូនដប់នាក់ ហើយមានឪពុកដែលមានជំងឺដូច្នេះខ្ញុំមិនមានឱកាសទទួលការសិក្សាអប់រំឡើយ។ ដូច្នេះ ប៉ុន្តែតាំងពីកំណើតមក មានអ្វីដែលកើត ឡើងនៅទីនោះ...ជាបទពិសោធន៍ជាមួយព្រះ ចំពោះម្ដាយនិងឪពុករបស់ខ្ញុំ។ ហើយខ្ញុំបានអានរឿងរបស់ខ្ញុំ។ ហើយ ដោយតាមរបៀបនោះ ខ្ញុំព្យាយាមដាក់ក្នុង ចំណែករបស់ខ្ញុំ ជាមួយអ្នកបងប្អូន ដើម្បីព្យាយាមទាញមនុស្សបាបទៅកាន់ព្រះគ្រីស្ទ។ ហើយ ឥឡូវ ខ្ញុំ...

16 ខ្ញុំមិនមែន អបិយជំនឿទេ។ ប៉ុន្តែ ខ្ញុំតែងតែ មុនចាប់ផ្ដើមព្រះបន្ទូល ខ្ញុំចូលចិត្តនិយាយពីអ្នកនិពន្ធបន្តិច។ ហើយយើងអាចឲ្យនក្បាល របស់យើងម្ដង

ទៀតមួយ ភ្លែត។

17 ព្រះវរបិតាដ៏វិសេស របស់ទូលបង្គំរាល់គ្នា ទ្រង់ជាព្រះរបស់ទូលបង្គំរាល់គ្នា ហើយយើងចូលទៅកាន់ទ្រង់តំណាងឲ្យដំណឹងល្អ។ ទូលបង្គំនៅទីនេះពីមុខបុត្រធីតារបស់ទ្រង់ ជាគ្រូគង្វាលរបស់ទ្រង់ និងបងប្អូនដែលមានជំនឿរួមគ្នា។ ហើយវាបាននាំឲ្យមានសេចក្តី ស្រើបដល់ចិត្តទូលបង្គំក្នុងការ ស្តាប់មនុស្សនេះដែលធ្លាប់បានយល់ច្រឡំ និងបញ្ជូនជាការផ្តួចផ្តើមឡើង សម្រាប់ជាប្រយោជន៍នៃនគររបស់ទ្រង់មើលរបៀបដែលទ្រង់បានត្រាស់ ហៅកូនរបស់ទ្រង់នៅថ្ងៃចុងក្រោយ។

18 ហើយទូលបង្គំជឿថា ព្រះវរបិតា គឺទូលបង្គំកំពុង រស់នៅចុងបញ្ចប់នៃជាតិសាសន៍។ ព្រោះលោកព្យាការីថ្លែងថា "នឹងមានពន្លឺនៅពេលព្រលប់" និងជឿថាថ្ងៃនេះទូលបង្គំជាអ្នកនាំសារ នៃពន្លឺដំណឹងល្អដ៏អស្ចារ្យដែល ដោយព្រះគុណទ្រង់ទ្រង់អនុញ្ញាតិឲ្យទូលបង្គំនាំទៅកាន់ចុងបញ្ចប់នៃផែនដីដែលការផុសផុលនេះបានចេញទៅ។

19 ហើយ ទូលបង្គំអធិស្ឋានថា ចេញពីចិត្ត ដែលទ្រង់នឹងអនុញ្ញាតិឲ្យទូលបង្គំបង្ហាញទៅកាន់បងប្អូនទូលបង្គំ នៅព្រឹកនេះ ជាគោលបំណងនិងគោលដៅនៃជីវិតចំពោះទ្រង់ ដែលពួកគេអាចយល់។ សូមទទួលយក ដែលទូលបង្គំអាចមានក្តីស្រឡាញ់គ្រប់ល័ក្ខ និងការប្រកបគ្នានិងការរួបរួម នៅក្នុងកិច្ចការនៃដំណឹងល្អ។ សូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ ដែលទ្រង់បាន អធិស្ឋានឲ្យទូលបង្គំរួមគ្នាតែមួយ។ ជឿសេចក្តីនេះថា "ដើម្បីឲ្យមនុស្សទាំងអស់ដឹងថាអ្នករាល់គ្នាជាសាវករបស់ខ្ញុំ ពេលអ្នកមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក" អាម៉ែន។

20 ឥឡូវ សូម...ហើយខ្ញុំសង្ឃឹមនិងទុកចិត្តថាខ្ញុំមិនធ្វើឲ្យបងប្អូនធុញទ្រាន់ឡើយ ចំពោះរឿងនេះ។ ប៉ុន្តែខ្ញុំនឹងធ្វើខ្លួនឯងឲ្យកាន់តែច្បាស់ ដូច្នេះអ្នកមិនចាំបាច់ឮអ្វីដែលនរណាម្នាក់ទៀតប្រាប់ឡើយ។ ហើយខ្ញុំពន្យល់ ជាច្រើនលើកក្នុងការប្រជុំព័ន្ធកិច្ចប៉ុន្តែនេះជាលើកទីមួយដែលនៅចំពោះក្រុមឈីកាហ្គោ និងខ្ញុំនឹងធ្វើខ្លួនឯងឲ្យបានល្បីល្បាញ គឺអ្វីដែលខ្ញុំព្យាយាមនឹងធ្វើ។

21 នៅក្នុងដំណឹងល្អចាស់ដែលមានពរត្រង់នេះ ជំពូកទី២៦នៃគម្ពីរកិច្ចកា យើងអាន:

*បពិត្រព្រះករុណាអ័គ្រីប៉ាអើយ នៅថ្ងៃនេះ ទូលបង្គំមានចិត្តអំណរណាស់ ដោយមានច្បាប់នឹងដោះសាខ្លួននៅចំពោះទ្រង់ ពីអស់ទាំងសេចក្តីដែលសាសន៍យូដាចោទប្រកាន់ទូលបង្គំ:*

22 នេះជាការពិតណាស់ប៉ុលនិយាយ ដែលអស់ទាំងអ្នកដឹកនាំ ដូចបានសំដៅមកវិញចំពោះគាត់ព្រោះគាត់...យើងរួមគ្នាតែមួយជឿ ថាគាត់ជាសាវកចំពោះក្រុម ជំនុំសាសន៍ដទៃដែលព្រះបានហៅគាត់—ជាសាក្សីដល់សាសន៍ដទៃ។ និងព័ន្ធកិច្ចរបស់គាត់ត្រូវបានគេហៅដើម្បីសាកសួរ។

23 ហើយជាធម្មតាអ្វីដែល មិនធម្មតាលេចចេញមក វាតែងត្រូវបានគេហៅទៅសាកសួរ។ វាជា ហើយខ្ញុំគិតថាវាមិនមែនអ្វីក្រៅជាងពីសិទ្ធិនោះទេ វាគួរត្រូវបានហៅទៅសាកសួរដែរ។ ហើយខ្ញុំគិតថាជួនកាលគ្រូគង្វាលមានភាពសង្ស័យនៃ—អ្វីដែលពួកគេបានឮ។ ខ្ញុំគិតថាពួកគេមានសិទ្ធិក្នុងការស្តាប់ឮ។ ព្រោះបើខ្ញុំយល់ពីការបកប្រែពាក្យ *គ្រូគង្វាល* មានន័យថា "អ្នកឃ្វាល" និង ដូច្នេះ ទ្រង់ជា—ជា—ជាអ្នកចំអែតឬអ្នកចិញ្ចឹមសត្វ នៃក្រុមមនុស្សប្រុសស្រី ដែលមានព្រះវិញ្ញាណបរិសុទ្ធធ្វើឲ្យពួកគេមើលឃើញវែងឆ្ងាយ។ និងគាត់ដឹងថាតើអាហារបែបណាដែល ចៀមទទួលនិងវាបានមកពីណា។ ខ្ញុំគិតថាគាត់មានសិទ្ធិបែបនោះ។

24 ហើយ បើគ្រូគង្វាលឬជួនកាលមនុស្សហាក់ដូចជាមានចិត្តសង្ស័យបន្តិចនោះ មិនដូច្នេះទេ មិនដែល មិនគួររំខាននរណាម្នាក់ឡើយ។ វាគួរតែនាំមានការគោរពដល់ចិត្តមនុស្សសម្រាប់មនុស្សដូចពួកគេ ដែលឈរឡើងដែលគួរតែសួរ។ និងបន្ទាប់ពីនោះបើអ្នកមិនប្រាកដថាអ្នក អ្នកនៅតាមសេចក្តីត្រឹមត្រូវ តើអ្នកអាចដើរដោយជំនឿម្តេចបាន?

25 បើអ្នកដាក់ក្នុងគំនិត...ឥឡូវនេះហាក់ដូចជាចិត្តវិទ្យា ដែលអាចជា និងវាជា ប៉ុន្តែវាមិនអីទេ។ ប៉ុន្តែអ្នកគឺការពិតធ្វើចេញពីចិត្ត អ្នកគិតថានឹងមិនងើបចេញពីតុឡើយ អ្នកប្រហែលជា មិនសោះឡើយ។ ឃើញទេ? អ្នកដឹង...វាគ្រាន់ជាឧទាហរណ៍។

26 អ្នកត្រូវតែជឿ អ្នកត្រូវមានជំនឿ។ អ្នកត្រូវមានទំនុកចិត្ត។ និងតើអ្នកអាចមានទំនុកចិត្តយ៉ាងណាក្នុងអ្វីដែលអ្នក—ដែលអ្នកមិន ដឹងថាអ្នកទៅណា? តើការ ធ្វើដំណើរតាមផ្លូវដូចម្តេច បើអ្នកមិនធ្លាប់ធ្វើពីមុន ជាមួយនឹងល្បឿនដែលគ្រោះ ថ្នាក់។ ហើយទាំងអស់វាកោង មិនដឹងថាតើផ្លូវកោងបន្ទាប់នឹងមានអ្វី? អ្នក

ត្រូវ តែឃើញថាអ្នកទៅណា ឬក៏អ្នកមិនដងថា អ្នកដើររបៀបណាទេ។ និងនោះជារបៀបដែលគ្រប់គ្នាត្រូវជាបែបនោះ។ និងបន្ទាប់មកពេលអ្នកអាច អ្នកឃើញវា វានឹងបើកឲ្យអ្នកឃើញ និងអ្នកដឹងថាអ្នកទៅណា ដូច្នេះគ្មានអ្វីដែលបញ្ឈប់អ្នកបានឡើយ។

27 ហើយនោះគឺ ខ្ញុំគិត ប៉ុល ជាអ្វីដែលគាត់ព្យាយាមពន្យល់អ័គ្រីប៉ាត្រង់នេះ។ នោះ គាត់—គាត់ប្រាប់ ពួកគេបែបនោះ "ពេលខ្ញុំនៅជា ម្នាក់ដូចអ្នករាល់គ្នា។"

28 ហើយខ្ញុំតម្រូវឲ្យ ប្រហែល បើ—បើបងប្អូនប្រុសបាបទីស្ទនេះ និងអាចទៅក្រុមជំនុំបាបទីស្ទព្រឹកនេះ គាត់និងប្រពន្ធរបស់គាត់ នោះអាចជាទីបន្ទាល់សម្រាប់ពួកគេ "ខ្ញុំ—ខ្ញុំធ្លាប់ជាម្នាក់ក្នុងចំណោមអ្នក។"

29 ឬក្រុមជំនុំព្រះគ្រីស្ទ ឬ—បងប្អូនប្រុស ខេមប៉ែលីត(Campbellite)នៅទីនេះអាចទៅ—មនុស្សរបស់គាត់។ ខ្ញុំជឿថានឹងបានហៅឈ្មោះប្រសើរឡើង សាវ័កនៃព្រះគ្រីស្ទ ពួកគេហៅដូច្នេះប៉ុន្តែវាសម្រាប់គោលលទ្ធិ Alexander Campbell។ និងក្រុមជំនុំសម្រាប់ព្រះគ្រីស្ទ ទាញអ្នកចេញ លើទិន្នន័យភ្លេង។ នោះគឺត្រូវហើយមិនចឹង? ហើយបើគាត់អាចត្រឡប់ទៅរកពួកគេវិញ គាត់អាចនិយាយ "ខ្ញុំធ្លាប់ជាអ្នកដូចជាអ្នកដែរ។"

30 ហើយប៉ុលត្រឡប់ទៅវិញចំពោះស្ដេចអ័គ្រីប៉ា និង Festus និងនិយាយ "ខ្ញុំធ្លាប់ជាម្នាក់ក្នុងចំណោមអ្នករាល់គ្នាដែរខ្ញុំជាពួកផារ៉ាស៊ីនៃពួកផារ៉ាស៊ី" គាត់ទទួលការបង្ហាត់បង្រៀនពី Gamaliel ជាគ្រូដ៏ធំ ហើយគាត់ស្គាល់អស់ទាំងក្បួនច្បាប់និងវិន័យរបស់ពួកគេ និងដូចជាអ្វីដែលពួកគេបានជឿ និងអ្វីដែលពួកគេមិនជឿ។ និងគាត់និយាយ "រហូតដល់ខ្ញុំបានបៀតបៀនក្រុមជំនុំនៃព្រះដល់ស្លាប់ទៀតផង" ឃើញ? គាត់និយាយ "អ្វីដែលខ្ញុំមានជាសំណួរ ខ្ញុំធ្លាប់ជាអ្នកបៀតបៀន។"

31 ហើយ ខ្ញុំតែងតែគិតថាសេចក្ដីស្លាប់របស់ស្ទេផានត្រូវតែកើតមានចំពោះប៉ុលព្រោះពេលគាត់ឃើញ សិរីរុងរឿងនៅលើមុខរបស់ស្ទេផាន។ ពេលគាត់មើលឃើញភាពល្វើល្វើនឹងវាយគាត់រហូតដល់ស្លាប់ និងគាត់និយាយ "ខ្ញុំឃើញព្រះយេស៊ូវគង់នៅខាងស្ដាំព្រះ" និងអ្នកដឹងហើយ អ្នកអាចសម្លាប់អ្នកនាំសារ ប៉ុន្តែអ្នកមិនអាចសម្លាប់សារបានឡើយ។ ហើយសារនោះទោះបីស្ទេផានបានចេញបាត់ទៅ នៅជាមួយព្រះយេស៊ូវតែសាររបស់គាត់នៅបន្ត ព្រោះប៉ុលនៅតែនិយាយជានិច្ច ពីរឿងនោះនិងអ្វីគាត់"តូចជាងគេ" នៃពួកគេហើយមិនសក្តិសមនឹងហៅជាម្នាក់ផងព្រោះ

គាត់បានធ្វើ ទីបន្ទាល់និង—និងផ្តល់ ការយល់ព្រមរបស់ គាត់ដើម្បីលុបបំបាត់មនុស្ស កោត ខ្លាចព្រះនេះ។

32 ហើយដូច្នេះប៉ុលក៏ដូចជា មនុស្សទាំងអស់នៅពីមុខមនុស្សដែលគួរធ្វើ ប៉ុលបានយកបទពិសោធន៍របស់—របស់គាត់ ត្រឡប់ពីដំបូង ពីអ្វីដែលគាត់ធ្លាប់ជាដើម្បីបង្ហាញថាអ្វីដែល គាត់ធ្វើគឺតាមបទគម្ពីរ។ ទោះបីជាវាបញ្ច្រាសការជឿរបស់ពួកគេក៏ដោយ តែគាត់នៅតែបង្ហាញដល់ពួកគេថាវាគឺតាមបទគម្ពីរ។

33 ដូច្នេះខ្ញុំគិតថាយើង...អ្វីក៏ដោយ ដូចខ្ញុំបាននិយាយជាញឹកញាប់ បងប្អូនដែលជាអ្នកនៅក្នុងអង្គប្រជុំគ្នា ថា បើសិនជារកឃើញថាខ្ញុំនិយាយអ្វីដែលមិនមែនតាមបទគម្ពីរ ដូច្នេះខ្ញុំគិតថាពិតណាស់ដែលថា...ឬបងប្អូនផ្សេងទៀត យើងគួរតែមកជួបគ្នានិងនិយាយ "នោះគឺមិនមានក្នុងព្រះគម្ពីរឡើយ" អ្នកឃើញទេ។ បើសិនវាមិននៅក្នុងព្រះគម្ពីរប្រហែលមកពីអ្នកមានការបកស្រាយខុសគ្នា ប៉ុន្តែវាគឺបើសិនជានៅក្នុងព្រះគម្ពីរគឺត្រឹមត្រូវ។

34 ឥឡូវប៉ុលបានផ្តល់ ការបកស្រាយរបស់គាត់ពី អ្វីដែលព្យាការីបាននិយាយ និងអ្វីដែលលោកម៉ូសេបាននិយាយ គឺបានសម្រេចពិត។ហើតគាត់ជួបព្រះយេស៊ូវ នៅតាមផ្លូវ នៅក្នុងនិមិត្ត។ ហើយព្រះយេស៊ូវ បានត្រាស់ហៅ គាត់ឲ្យចេញមក។

35 អ្វីដែលវាមិនគួរជារឿងពិបាកសម្រាប់ពួកយូដាទាំងនោះដូចគាត់បាននិយាយ "អ្នកថ្លៃថ្នូរហ្វេសទុស" ហើយ—និងផ្សេងទៀតជាដើម នោះវា... "តើវាគួរចម្លែកទេចំពោះអ្នក ដែលព្រះអាចប្រោអ្នកស្លាប់ឲ្យរស់បាន?" ឃើញ "ព្រោះបើអ្នកដឹងពីអ្វី ដែលព្រះត្រឡប់ទៅដោយ—ខគម្ពីរ ពិតណាស់អ្នកដឹងហើយថាទ្រង់អាច ប្រោសមនុស្សស្លាប់ឲ្យរស់វិញបាន។"

36 ហើយដូច្នេះគាត់និយាយ គាត់បានផ្តល់បទពិសោធន៍ដល់ពួកគេតាមផ្លូវរបស់គាត់ទៅដាម៉ាស នៃអ្វីដែលបានកើតឡើង នោះ ដើម្បីឲ្យពួកគេដឹងថាព្រះ យេស៊ូវនោះ—ដែលពួកគេបង្ករឲ្យមាន កោឡាហលពីគាត់ដែលអធិប្បាយវា គឺជាព្រះតែមួយដែលពួកគេបម្រើគ្រប់ពេល។ ព្រោះទ្រង់បានគង់នៅជាមួយគេក្នុងវាលរហោស្ថានជាអង្គដែលដឹកនាំគេជាពន្លឺភ្លើង សសរភ្លើងដែលដឹកនាំពួកគេ។ ហើយទ្រង់លេចចេញមកប៉ុលក្នុងរបៀបដូចគ្នា ជាពន្លឺម្តងទៀត ដែលធ្វើឲ្យគាត់ខ្វាក់ភ្នែក។ និងគាត់ក៏សួរ "ទ្រង់ជានរណាព្រះអម្ចាស់?"

37 ហើយទ្រង់មានបន្ទូល "ខ្ញុំគឺជាព្រះយេស៊ូវដែលអ្នកបៀតបៀន។ ហើយវេទនា ហើយដែលទាត់ជល់ជន្លួញ។"

38 ហើយគាត់ព្យាយាមពន្យល់ ពួកគេថានោះ ជាអ្វីនិង—និងគាត់ព្យាយាម បង្រៀនពួកគេបែបនោះ "ព្រះយេស៊ូវជាព្រះមេស្ស៊ី ដែលទ្រង់បានសុគត ហើយព្រះបានប្រោសទ្រង់រស់ឡើងវិញ" ហើយនោះវាស្របតាមបទគម្ពីរ។ "ហើយនោះទ្រង់ឥឡូវត្រូវបានលើកឡើងទៅកាន់ព្រះវរបិតា" និងនោះ—នោះគឺគាត់ ជាទីបន្ទាល់នៃការរស់ឡើងវិញរបស់ទ្រង់។ ហើយនោះជាការអស្ចារ្យទាំងនេះ និងទីសម្គាល់និងការអស្ចារ្យដែលជារឿង ចម្លែកចំពោះមុខមនុស្ស ប៉ុន្តែមិនមែនជារឿងថ្មីចំពោះការពិតឡើយ អ្នកជឿខគម្ពីរ ព្រោះព្រះគម្ពីរបាននិយាយរួចហើយ។

39 ក្រលេកមើលពួកព្យាការីតើបានថ្លែងទំនាយយ៉ាងណាអ្វីជាការយាងមករបស់ព្រះមេស្ស៊ី និងអ្វីដែលទ្រង់ធ្វើ "ពួកមនុស្សខ្វិននឹងលោតឡើងដូចក្តាន់ញី" ក្នុងគម្ពីរអេសាយ35និងមានខគម្ពីរខុសគ្នា ដែលសំដៅលើការនោះដែរ។ យើងមិនមានសរសេរត្រង់នេះទេ ប៉ុន្តែប្រហែលជាសំដៅត្រឡប់ ទៅពាក្យខ្លី របស់គាត់ពីមុខស្តេច ព្រោះពួកគេប្រហែលមិនមែនជាមនុស្ស ដែលស៊ូទ្រាំជាមួយគាត់ដូចជាបងប្អូនជាមួយខ្ញុំដែរ។ ដូច្នេះ និងបន្ទាប់មក—គាត់ក៏ពន្យល់វា និងព្យាយាមប្រាប់ពួកគេពីព្រះតែមួយដែលពួកគេបម្រើ...

40 ហើយគាត់និយាយម្តងទៀត "ក្នុងរបៀបដែលហៅថាអញ្ញមតិ" នោះជា "ភាពលីលា" ឃើញ។ "របៀបដែលហៅថាអញ្ញមតិ នោះជារបៀបនោះដែលខ្ញុំថ្វាយបង្គំព្រះដែលអ្នកបានថ្វាយបង្គំ" ឃើញ "នោះជារបៀបដែលហៅថាអញ្ញមតិ។"

41 ខ្ញុំប្រាកដថាថ្ងៃនេះបើសិនជាយើងឈរលើក្រុមជំនុំកាលពីមុនដែលយើងធ្លាប់ជាកម្មសិទ្ធិនោះ ដូចជា ព្រីសប៊ីស្ទើរៀន កាតូលិក បាបទីស្ទ គឺខុសគ្នា យើងអាចនិយាយទីបន្ទាល់ ដូចគ្នានឹងអស់អ្នក ដែលនិយាយតាមចិត្តរបស់គេដូចជាយកបងប្អូនទៅដាក់ខាងពេទ្យវិកលចារិត ឬអ្វីដែលស្រដៀងនោះ។ "ក្នុងរបៀបដែលហៅថាសាសនាខុសឆ្គង ជារបៀបខ្ញុំថ្វាយបង្គំ ព្រះនៃឪពុករបស់ពួកយើង។"

42 ហើយអ្វីដែលជាទីបន្ទាល់ សំខាន់ដែលមាននៅពីមុខអ័គ្រីប៉ា ទោះនៅពាក់កណ្តាលអ្វីដែលគាត់បាននិយាយរបស់គាត់ អ័គ្រីប៉ាស្រែកឡើង និងនិយាយថា "ប៉ុល សូល អ្នកធ្វើឲ្យយើងជិតក្លាយជាគ្រីស្ទានហើយ។" ឃើញ របៀបដែលគាត់បាននាំបទគម្ពីរឲ្យចេញមកច្បាស់ តែវាផ្ទុយពីសាលាប្រជុំរបស់គាត់វិញ។

ប៉ុន្តែ បទគម្ពីរគឺជាក់ច្បាស់ណាស់ រហូតគាត់និយាយ "អ្នកស្ទើរតែនាំយើងឲ្យក្លាយដូចជាអ្នកដែរ។"

43 ប៉ុលនិយាយថា "ខ្ញុំប្រាថ្នាឲ្យអ្នកទាំងអស់គ្នាមិនចង់ឲ្យអ្នកជាប់ក្នុងច្រវ៉ាក់ទាំងនេះដូចខ្ញុំជាប់ដែរ" អ្នកឃើញទេ ប៉ុន្តែជាអ្នកជឿដូចគាត់ពីមុន។ ពាក្យមួយទៀតបើសិនជាខ្ញុំ..."ខ្ញុំប្រាថ្នាឲ្យព្រះដែល អ្នកបានឃើញការបើកសម្ដែងដូច—ដូចខ្ញុំឃើញវា។" ន័យម្យ៉ាងទៀត "ខ្ញុំ—ខ្ញុំប្រាថ្នាឲ្យអ្នកអាចធ្វើបាន។" ឃើញ? "ខ្ញុំប្រាថ្នាឲ្យអ្នកអាច។"

44 ពេលដែល Festus ខ្ញុំជឿ នៅព្រឹកនេះ បងប្អូនអើយ បានប្រាប់គាត់ពីអ្វីដែលគាត់មាន "រៀនរៀនពេក" គាតពេលនោះ "ចេញពីក្បាលរបស់គាត់។" ប៉ុន្តែគាត់ឲ្យគាត់ដឹងថា គាត់—ថាគាត់មិន នោះគឺគាត់—គាត់ដឹងថាគាត់នៅត្រង់នោះ។

45 ហើយខ្ញុំអាចនិយាយបែបនេះ ព្រឹកនេះ បងប្អូន ខ្ញុំទាំងអស់គ្នាប្រាថ្នាឲ្យខ្ញុំអាច...មិនសំដៅជីវិតរបស់ប៉ុល ប៉ុន្តែដើម្បីផ្ដល់គ្រឹះក្នុងការពិភាក្សាបន្តិច។ ព្រោះមានមនុស្សជាច្រើននៅព្រឹកនេះដែលត្រូវនិយាយ ប៉ុន្តែខ្ញុំចង់បានឱកាសនេះដើម្បីនិយាយការនេះ។ ឥឡូវ ខ្ញុំចង់បានក្រុមជំនុំមកខុសៗគ្នា ពេលដែលខ្ញុំឮអ្នកទាំងអស់គ្នាប្រព្រឹត្តិទៅ ព្រះវិហារបេតអែលឯករាជ្យក្រុមជំនុំគ្រួសារព្រះ និងមានខុសៗគ្នា...ខ្ញុំចង់បានទាំងអស់គ្នា បែបនោះអ្នកអាចឃើញអ្វី ដែលខ្ញុំឃើញដែលអ្នក អាច។ ខ្ញុំប្រាថ្នាឲ្យអ្នកអាចឃើញនិមិត្តដែលខ្ញុំឃើញ រួចអ្នកអាចមានការយល់ដឹងច្បាស់ឡើង នោះជាព័ន្ធកិច្ច។

46 ពេលដែលខ្ញុំចាកចេញពីក្រុមជំនុំបាបទីស្ទ ដើម្បីក្លាយជា អ្នកពេនទីកុស្ត និងDr. Roy E. Davis ជាអ្នកតាំងខ្ញុំទៅបេសកជន ក្រុមជំនុំបាបទីស្ទប្រាប់ខ្ញុំថាខ្ញុំនឹងមានការលំបាកពេលដែលនិមិត្តនៃព្រះអម្ចាស់យាងមកនិង—និងនិយាយមកកាន់ខ្ញុំ។ និង—និង អ្នកដឹងថាការប្រោសឲ្យជា វាគឺនៅក្នុងលំនាចដែលទាប។

47 និង—និងខ្ញុំមិនស្គាល់អ្វីទាំងអស់ពីពេនទីកុស្ត។ ខ្ញុំឮពីគាត់ថាជា ក្រុមហូលីរ៉ូលឡឺដែលដេកលើកម្រាលនិងហៀរទឹកមាត់ដូចជាឆ្កែឆ្កួត ហើយគេត្រូវបក់ពួកគេឲ្យរស់វិញនិងអ្វីៗ ទាំអអស់ដូច្នោះ។ នេះជាអ្វីដែលខ្ញុំ ដឹងពីមនុស្សជាអ្នក ពេនទីកុស្ត។

គាត់និយាយ "អ្នកគិតថានរណានឹងស្ដាប់លឺអ្នក?"

48 ខ្ញុំនិយាយ "បើព្រះបញ្ជូនខ្ញុំមក មានកន្លែងខ្លះនិងមាននរណាម្នាក់ដែលទ្រង់នឹងបញ្ជូនមកខ្ញុំ" នោះត្រឹមត្រូវទេលោក។ ឃើញ "ព្រោះ" ខ្ញុំនិយាយ "Dr. Davis" ខ្ញុំនិយាយ "ទ្រង់មានវត្តមានពិតខ្ញុំឈរឡើងហើយមើទៅទ្រង់" ខ្ញុំនិយាយគេប្រាប់ខ្ញុំថានោះជានិមិត្ត...

49 ខ្ញុំជាអ្នកជឿធំមួយបងប្អូននោះ—អំណោយទាននោះដែលបានហៅមកដោយមិនស្តាយ។ ខ្ញុំ—ខ្ញុំ ជឿបែបនោះ។ អ្នកកើតមក អ្នកមិនអាចទៅជាអ្វីដែលអ្នកមិនអាចនោះទេ។ ហើយពេលណាដែលអ្នកព្យាយាមធ្វើអ្វីដែលអ្នកមិនត្រូវជា អ្នកត្រឹមតែព្យាយាមធ្វើ ជាអ្នកកំពុតប៉ុណ្ណោះ។ ហើយព្រះអនុញ្ញាតិឲ្យខ្ញុំស្លាប់តាមអ្វីដែលខ្ញុំជាអ្នកកំពុត ឃើញ។ ចូរឲ្យខ្ញុំក្លាយជាអ្វីដែលខ្ញុំនឹងក្លាយទៅជាចុះ ហើយវានឹងងាយហើយច្បាស់។ និង—និងបន្ទាប់មកចូរ—ចូរឲ្យខ្ញុំទៅតាមផ្លូវនោះ និងគ្រប់គ្នាបានដឹង។ រួចអ្នកដឹងយ៉ាងច្បាស់។

50 ហើយឥឡូវ ដូចអ្នកបានដឹងហើយ ខ្ញុំមិនបានរៀងសូត្រច្រើនទេ ដូចខ្ញុំបាននិយាយ។ ដូច្នេះនៅក្នុង...ទេវសាស្ត្ររបស់ ខ្ញុំជាអ្នកដែលមិនចេះដឹងអ្វី។ ហើយខ្ញុំទាយថាអ្នកដឹងបាន ឃើញ។ និង ជាអ្នកអធិប្បាយ ខ្ញុំពិបាកក្នុងការហៅខ្លួនឯងថាជាម្នាក់ព្រោះមិនបានរៀនសូត្រនិងមិនស្គាល់ពាក្យ និងអ្វីទៀត។ ប៉ុន្តែ អ្វីតិចតួចដែលខ្ញុំមានដើម្បី...ជាចំណេះដឹង ដែលខ្ញុំដឹងដោយ ព្រះគុណរបស់ទ្រង់ជាព្រះអម្ចាស់យេស៊ូវ ខ្ញុំព្យាយាមចែកចាយរឿងនោះជាមួយបងប្អូនគ្រប់កន្លែង ដើម្បីចែកចាយរឿងនេះ។

51 ហើយប៉ុន្តែពេលខ្ញុំចាកចេញក្រុមជំនុំបាបទីស្ទ...ជាក្រុមជំនុំ តែមួយដែលខ្ញុំបានចូលហើយក៏បានតាំងជាអ្នកដឹកនាំ។ ហើយខ្ញុំត្រូវបានតែងតាំងក្នុងឆ្នាំ1933 នៅក្នុងក្រុមជំនុំបេសកជនបាបទីស្ទ ជេសាន់វីល អ៊ីនឌៀអាយណា។ វាគឺ—គឺ...វាជាសមាជិកនៃពួកជំនុំបាបទីស្ទខាងត្បូង។ រួចយើងក្នុងពេលនេះខ្ញុំ...ពេលខ្ញុំរុញចេញ និងត្រឹមតែ...

52 ឥឡូវក្រុមជំនុំបាបទីស្ទ ជាក្រុមជំនុំមានអំណាច។ យើង—យើងទាំងអស់គ្នាដឹងថា នោះគឺ—វាគឺ...អ្នកអាចអធិប្បាយពីអ្វីដែលអ្នកចង់ បើសិនជាអង្គសន្និបាតរបស់អ្នកអាចទទួលយកបាន។ ពួកគេត្រឹមតែ...អ្នក អាចអធិប្បាយតាមអ្នកចង់។

53 ហើយខ្ញុំចូលចិត្តបែបនោះឃើញ ព្រោះខ្ញុំជឿថាវាជាសាវក។ ពីព្រោះ ក្បាលជាកន្លែងខ្ពស់តាមលំដាប់នៅក្នុងក្រុមជំនុំ ជាអ្នកគង្វាល យើងដឹងថា គ្រូគង្វាល។

និង—និងបើជា—ជា...បើសិនជាអ្នកដឹកនាំ ឬ នរណាម្នាក់ទៀតនឹងគោះការបើក សម្លេងចេញពីគ្រូគង្វាលដូច្នេះតើព្រះនឹងធ្វើការក្នុងក្រុមជំនុំរបស់គាត់រឺ? អ្នកឃើញ អ្នកមិនអាចយល់វាបាន។ ដូច្នេះ និង ខ្ញុំមាន...

54 ពេលខ្ញុំចេញមកពីនោះ ខ្ញុំបានជួបនឹងក្រុមមួយ ដែលជាការប្រោសឲ្យជា នៃ Betty Daugherty, at St. Louis, Missouri តូចមួយ។ និងវាជា សហ ការណ៍ពេនតីកុស្ដឬក្រុមជំនុំពេនទីកុស្ទព្រះនាមព្រះយេស៊ូវ និង គ្រូគង្វាលនេះ ជាកម្មសិទ្ធិ និងក្មេងស្រីតូចមួយរបស់គាត់បានទទួលការប្រោសឲ្យជា។ ដោយក្ដី គោរព ខ្ញុំគិតថានោះហើយដែលនាំឲ្យគាត់ក្លាយជាអ្នកពេនទីកុស្ដ ព្រោះនោះជាអ្វី ដែលគេបានហៅខ្លួនគេ "ព្រះយេស៊ូវតែមួយគត់" និង ហើយខ្ញុំគិតនោះហើយដែល ធ្វើឲ្យពួកគេក្លាយជាពេនទីកុស្ដ ព្រោះនោះហើយដែលគេបានហៅខ្លួនរបស់ ពួកគេ និង នោះគឺមានភាពខុសគ្នា។ ដូច្នេះ ល្អ បន្ទាប់មកពីទីនោះខ្ញុំទៅ...

55 ហើយបុរសល្អម្នាក់ មានការជួបជុំធំមួយនៅ St.Louis, ដែលជារូបភាព លេចឡើងនៅទីនោះ។ និងយើងមាន Kiel Auditorium និងយប់ទីមួយ ឬទីពីរ មានមនុស្សមួយម៉ឺនបួនពាន់នាក់ចាប់យក យើងមិនអាចសូម្បីតែ... ត្រូវដាក់ប៉ូលីសនៅមាត់ទ្វា ដើម្បីកុំឲ្យគេចូលមក។

56 ហើយពីពេលនោះមក ចុះទៅ Richard T.Reed នៃ the Blessed Old Bible Hour Tabernacle, នៅចូនេសបូរ៉ូ(Jonesboro)ដែលជាអង្គការតែមួយ។ និងចេញពីនោះ មកដល់Dr. G. H. Brown ដែលជាអង្គការដូចគ្នានៅផ្លូវ ៥០៥ វិកទ័រនៅLittle Rock, Arkansas។ និងពីទីនោះទៅឆ្នេរភាគខាងលិច(West Coast)។

57 ហើយរួចពេលខ្ញុំទៅដល់West Coast ខ្ញុំក៏បញ្ឆេះភ្លើង។ រួចខ្ញុំរកឃើញថា មានការបែងចែកក្នុង ចំណោមអ្នកជា ពេនទីកុស្ដ នៅក្នុងអង្គការដូចយើងជា អ្នកបាបទីស្ទមានដែរ។ ឃើញពួកគេ—ពួកគេមានភាពផ្សេងគ្នាជាច្រើនមានដូច្នោះ ពួក គេមានភាពខុសគ្នា។ មានក្រុមជំនុំព្រះជាម្ចាស់ និងក្រុមជំនុំនៃព្រះ និងមានអ្វី ផ្សេងទៀតនិងអ្វីផ្សេងទៀតនិងផ្សេងទៀត និង—ខុសគ្នា។ ហើយ ពួកគេបែងចែក ពីគ្នានិងគូសដែនបន្ទាត់តូចមួយបន្តិច។ ហើយបងប្អូនផ្សេងទៀតទាំងអស់មកឯខ្ញុំ និងប្រាប់ខ្ញុំ "ហេតុអ្វីបានជាអ្នកនៅក្រុម ព្រះយេស៊ូវតែមួយគត់ ក្នុងក្រុមនេះនៅ ទីនេះ។"

ខ្ញុំនិយាយ "ទេ ខ្ញុំមិន—ខ្ញុំមិនហៅខ្លួនខ្ញុំថាបែបនោះឡើយ" ឃើញ?

គាត់និយាយ "ហេតុអ្វី អ្នកប្រកបសង្គមជាមួយពួកគេ។"

58 ខ្ញុំនិយាយ "ល្អ នោះ—នោះមិនមែននាំឲ្យខ្ញុំទៅជាបែបនោះឡើយ" ឃើញ? និង ខ្ញុំនិយាយ "ខ្ញុំ—ខ្ញុំ—ខ្ញុំគ្រាន់តែ...ពួកគេជាបងប្អូន។"

59 ហើយគាត់និយាយ "ហេតុអ្វីបានជាពួកគេគ្រាន់តែជាក្រុមនៃ...ហេតុអ្វី ពួកគេមិនមានអ្វីក្រៅពីក្រុមនៃឬសចម្លែក និងអ្វីៗ ក្នុងរង្វង់បែបនោះ ជាកន្លែង..."

60 ខ្ញុំនិយាយ "ឥឡូវ ខ្ញុំសូមឲ្យអ្នកសូមទោស។ ខ្ញុំជួបអ្នកកោតខ្លាចព្រះពិតនៅទីនោះ។ ហើយពួកគេជាមនុស្សកោតខ្លាចព្រះ" និងខ្ញុំនិយាយ "ខ្ញុំ—ខ្ញុំពិតជាតូចចិត្តដែលហៅពួកគាត់ ថាជាមនុស្សអាក្រក់ ព្រោះពួកគេមិនមែននោះឡើយ។"

61 ល្អបន្ទាប់មកខ្ញុំព្យាយាមទប់វាដកចេញតាមតែអាចធ្វើទៅបាន ដោយមិនបានបង្ហាញពីរបៀបណាទាំងអស់។ ល្អ ខ្ញុំចាប់ផ្ដើមសិក្សាគឺអ្វីដែលជាគំនិតរបស់ពួកគេ និងអ្វីដែលនាំឲ្យពួកគេបែកចេញពីគ្នា និងអ្វីនាំឲ្យគេបែកចេញ។ ហើយខ្ញុំរកឃើញក្រុមមនុស្សពីរធំៗ មួយក្នុងចំណោមនោះគឺ ព្រះយេស៊ូវតែមួយគត់ និងមួយទៀតហៅថា ក្រុមជំនុំព្រះជាម្ចាស់។ ហើយពួកគេហៅដាច់ចេញពីគ្នា ដោយសាររឿងជ្រមុជទឹកមួយក្រុមប្រើ "ព្រះវរបិតា ព្រះបុត្រានិងព្រះវិញ្ញាណបរិសុទ្ធ" និងមួយ ក្រុមទៀតគឺប្រើព្រះនាម "ព្រះយេស៊ូវ។"

62 ល្អខ្ញុំមើល និងទាំងពីរផ្នែកសុទ្ធ តែមានមនុស្សអស្ចារ្យ ជាអ្នកបម្រើព្រះ។ ហើយខ្ញុំគិត "ឱ ព្រះអើយ តើទូលបង្គំសុំឲ្យឃើញទាំងពីរក្រុមរលាយចូលគ្នា...ទៅស្រុបគ្នានិងមាន...កុំឲ្យមានការគួសបន្ទាត់របស់ពួកគេ និងនិយាយ 'យើងមិនដើរតាមជាមួយម្ខាងទៀត' "ប៉ុន្តែខ្ញុំរកឃើញថាក្នុងរបៀបនេះអារក្សបាននៅក្នុងចំណោមពួកគេនិងបានបង្ករឲ្យមានសំអប់និងច្រណែន ដែលកើតមានលើពួកគេ។ ខ្ញុំគិត "នោះគឺល្អដូចជាតាមអ្វីដែលអារក្សចង់បានដែរ។ នោះជាអ្វីដែលអារក្សចង់បាន" ដំរាបណាអ្នកមានកាំភ្លើងដែលហ្វឹកហាត់ តម្រង់លើក្រុមមួយទៀត អារក្ស មិនចាំបាច់ខំសូម្បីតែលិឍ។ ហើយខ្ញុំ...

63 ហើយដូច្នោះ វាបានមក ដល់ការបង្ហាញ។ ហើយការបង្ហាញនោះធ្វើនៅស៊ីថល វ៉ាស៊ីនតោនប្រហែលជាឆ្នាំ 1946។ និងនៅព្រឹកមួយខ្ញុំត្រូវបាននាំទៅ

កាន់បន្ទប់សណ្ឋាគារ មានអ្វីបែបនេះ ជាមួយ—អាហារពេលព្រឹកនៃអ្នកដឹកនាំមួយចំនួន។ ហើយខ្ញុំត្រូវនិយាយទៅកាន់មនុស្សធំៗពីររូប។

64 ហើយម្នាក់ក្នុងចំណោមពួកគេគឺ បណ្ឌិតណេស. ខ្ញុំគិតថាជាអ្នកនៅក្រុមជំនុំព្រះជា ម្ចាស់ បើតាមខ្ញុំចាំពីគាត់។ គាត់នៅដែនដីភាគខាងជើង ជាមនុស្សអស្ចារ្យឆ្លាត ជាគ្រូ និងតំណាងក្រុមជំនុំព្រះជាម្ចាស់។

65 ហើយបន្ទាប់គឺលោកDr.Scismក្រុមជំនុំពេនទីកុស្ដសហរដ្ឋអាមេរិក។ ខ្ញុំគិតថាអ្នកជាបងប្អូនមកពីពេនទីកុស្ដអាមេរិកនិងស្គាល់គាត់។ គាត់ក៏ជាអ្នកមកពីដែនដីភាគខាងជើងដែរ នោះគាត់គ្រប់គ្រង ពួកគេនិងបែងចែកតំបន់នៅទីនោះ។

66 ល្អមនុស្សទាំងពីនាក់ជួបគ្នា។ ហើយខ្ញុំត្រូវនាំទៅកាន់ ពីមុខរបស់ពួកគេ ព្រោះ—គែមនោះវាមុតខ្លាំងណាស់ ហើយវាកាត់ខ្ញុំគ្រប់កន្លែង។ ហើយខ្ញុំគិត "តើខ្ញុំត្រូវធ្វើយ៉ាងណា? ខ្ញុំអាចធ្វើអ្វី?"

67 ឥឡូវ ល្អពួកគេបើសិនជាអ្នកនិយាយ "ល្អ អ្នកត្រូវនៅខាងណាមួយ។ ថាតើអ្នកនៅក្នុងព្រះនាមព្រះយេស៊ូវ។ អ្នកត្រូវតែនៅក្នុងព្រះនាមព្រះយេស៊ូវ។ និងបើសិនជាអ្នកនៅក្នុងក្រុមជំនុំព្រះ អ្នកត្រូវតែចាកចេញពីព្រះនាមព្រះយេស៊ូវ និងទៅជាក្រុមជំនុំព្រះជាម្ចាស់ ឬបន្តបែបនោះ" វាមកដល់កន្លែង ដែលខ្ញុំត្រូវបង្ហាញពីប្រភេទណាមួយ។

68 ខ្ញុំអធិស្ឋានយ៉ាងច្រើននៅព្រឹកនោះ មុនពេលចូលទៅ។ ខ្ញុំនិយាយ "ព្រះអើយ ជួយទូលបង្គំ។ ព្រោះមានមនុស្សធំៗពីររូបមានអ្នកបម្រើរាប់ពាន់ ហើយទ្រង់បញ្ជូនទូលបង្គំមកទីនេះដើម្បីព័ន្ធកិច្ច។ ហើយពួកគាត់ទាំងពីរជាអ្នកបម្រើទ្រង់។ តើទូលបង្គំគួរបោះឥទ្ធិពលបន្តិចបន្តួច ដែលមានទៅក្នុងអង្គការពេលមានជម្លោះគ្នាឬទេ?" ឃើញ? "ខ្ញុំ—ខ្ញុំមិនមានអារម្មណ៍ថា ត្រឹមត្រូវទេដែលធ្វើបែបនោះ។ ខ្ញុំមិនគិតថានោះជាព្រះហឫទ័យរបស់ព្រះគ្រីស្ទក្នុង ការធ្វើបែបនោះឡើយ" ហើយខ្ញុំនិយាយ "ព្រះអើយ ជួយទូលបង្គំនិងប្រទានឲ្យទូលបង្គំធ្វើអ្វីមួយ ឬប្រទានអ្វីមួយដល់ទូលបង្គំឲ្យធ្វើ។"

69 ហើយខ្ញុំមិនមានអ្វីមួយឡើយខ្ញុំត្រូវនៅ ទីនោះដូចព្រះអម្ចាស់យេស៊ូវ និងខ្ញុំនៅព្រឹកនោះ។

70 ល្អការពិភាក្សាយ៉ាងធំចូលមកដល់"តើអ្នកនឹងធ្វើអ្វី? អ្វី—អ្វី—អ្វីជាការសម្រេចចិត្តដែលអ្នកនឹងធ្វើ?"

71 ខ្ញុំនិយាយ "ការសម្រេចចិត្តរបស់ខ្ញុំត្រូវបានធ្វើរួចហើយ។ នោះគឺការសម្រេចចិត្តរបស់ខ្ញុំ គឺត្រូវឈរចន្លោះអ្នកទាំងពីរ ហើយមិនចូលរួមទាំងអង្គការណាមួយឡើយនិងនិយាយជាមួយដៃព័ទ្ធជុំវិញអ្នកទាំងពីរ 'យើងជាបងប្អូន'" ឃើញ? ឃើញទេយើងជាបងប្អូន។ ឃើញ? ហើយខ្ញុំនិយាយ "ខ្ញុំព្យាយាមអានសៀវភៅទាំងអស់តាមតែអាចធ្វើបានតើវាចេញមករបៀបណា អ្វីដែលហៅថានេះជា 'បញ្ហាថ្មី' និងពីរបៀបដែលគេបែកចេញពីគ្នានិងរបៀបដែលមួយ *នេះ* ចាប់ផ្ដើម របៀប *នោះ*" ហើយខ្ញុំនិយាយ "ក្នុងជម្លោះរវាងអ្នកទាំងពីរ" ខ្ញុំនិយាយ "នោះគឺដូចគ្នា ដែលបែកចេញ ជាចលនាពេនទីកុស្ត នៅថ្ងៃ...បន្ទាប់ពីពេនទីកុស្ត។ ពួកគេចាប់ផ្ដើមជជែក ឈ្លោះពីពេលនោះមក" ខ្ញុំនិយាយ "អ្វីៗបានបែកគ្នាម្ដងទៀត។"

72 ខ្ញុំនិយាយ "មានផ្លូវណាដែលអាចទៅរួចដែលជាផ្លូវកណ្ដាលរវាងអ្នក បងប្អូនអើយ? តើមានអ្វីដែលថា—អាចឈរបានទេ?"

73 ល្អ ពួកគេមិនបើកមាត់របស់គេព្រោះរឿងនោះឡើយ ព្រោះវាមុតណាស់។ អ្នកដឹងទេ ប្រហែល ដប់ប្រាំទៅម្ភៃឆ្នាំមុន វាគឺយ៉ាងណា ព្រោះមានក្រុមមួយបានរុញចេញពីក្រុមមួយទៀត ហើយក៏មានវិវាទខ្លាំងណាស់។

74 ដូច្នេះ ខ្ញុំនិយាយ "ល្អ បងប្អូនប្រុស នេះជាអ្វីដែលខ្ញុំចង់ធ្វើ។ ខ្ញុំនឹង...ព្រះមិនដែលបញ្ជូនខ្ញុំ ឲ្យទៅជ្រមុជទឹកឡើយ របៀបណាក៏ដោយ។ ទ្រង់បញ្ជូនខ្ញុំឲ្យអធិស្ឋានដល់កូនទ្រង់មានជំងឺ" ខ្ញុំនិយាយ "ដូច្នេះខ្ញុំនឹង—អធិស្ឋានសម្រាប់កូនៗដែលឈឺ ហើយអ្នកជាអ្នកដឹកនាំនឹងធ្វើការជ្រមុជទឹកចុះ" ខ្ញុំនិយាយ។

75 ខ្ញុំនិយាយ "ឥឡូវខ្ញុំចង់ធ្វើសួរអ្នកអ្វីមួយ ដូច្នេះអ្នកនឹងយល់" ខ្ញុំនិយាយ "បងប្អូនប្រុសណែស (Ness)...មនុស្ស ដែលប្រើ ព្រះនាមព្រះយេស៊ូវទាំងនេះតើលោកជឿថាពួកគេមានព្រះវិញ្ញាណបរិសុទ្ធឬទេ ពេលគេនិយាយភាសាដទៃ និងដូចគ្នាដែរដែលលោកធ្វើដូចគ្នានៅក្នុងក្រុមជំនុំព្រះជាម្ចាស់?"

និយាយ "ពិតណាស់។"

76 ខ្ញុំនិយាយ"បងប្អូនប្រុសស៊ីម (Scism) តើលោកជឿ ថាក្រុមជំនុំគ្រួសារព្រះមានព្រះវិញ្ញាណបរិសុទ្ធ ពេលនិយាយភាសាដទៃ និងធ្វើដូចគ្នាដែលលោកធ្វើលើការជ្រមុជទឹកឬទេ?"

គាត់និយាយ "ប្រាកដ ខ្ញុំជឿ។"

77 ខ្ញុំនិយាយ "ឥឡូវព្រះគម្ពីរនិយាយ 'ព្រះទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធនោះដល់អ្នកដែលស្តាប់បង្គាប់ដល់ទ្រង់' ឥឡូវនរណាស្តាប់បង្គាប់ទ្រង់? នរណាស្តាប់បង្គាប់ទ្រង់? បងប្អូនមួយណាក្នុងចំណោមអ្នកស្តាប់បង្គាប់ទ្រង់? ហើយព្រះប្រទានដល់អ្នកទាំងពីរមានព្រះវិញ្ញាណបរិសុទ្ធ" ឃើញទេ?

78 ខ្ញុំនិយាយ "តើលោកអាចនិយាយ ស៊ីម ឬបងប្អូនប្រុស ណោស ដែលមិនបានទទួលព្រះវិញ្ញាណបរិសុទ្ធ?"

និយាយ "ទេ។"

79 ខ្ញុំនិយាយ "តើលោកនិយាយថាបងប្អូនប្រុស ស៊ីម មិនមានព្រះវិញ្ញាណបរិសុទ្ធឬទេ?"

80 "ទេ" ឃើញ? នោះ ពួកគេទាំងពីរជឿថាគ្នា ពួកគេមាន ព្រះវិញ្ញាណបរិសុទ្ធ។

81 ប៉ុន្តែអ្នកឃើញទេវាមិនមានហេតុផលឡើយ បងប្អូន។ ហើយខ្ញុំព្ បន្តិចបន្តួចពីរឿងនោះ...

ខ្ញុំនឹងត្រឡប់មកចំណុចរបស់ខ្ញុំវិញបន្តិចទៀត។

82 បងប្អូន ហ្វាំងឡង់ នៅទីនេះ បន្ទាប់ពីខ្ញុំចាកចេញពីប្រទេសហ្វាំងឡង់ កន្លែងដែលព្រះប្រទានឲ្យយើងអ្វីខ្ញុំគិតជាការជួបជុំធំមួយមិនមែនតូចទេ ក្មេងប្រុសតូចម្នាក់ស្លាប់ត្រូវបានប្រោសឲ្យរស់ឡើងវិញ និងមានរឿងច្រើនទៀត។ ខ្ញុំជួបនៅ ស្តុកខលប្រទេសស៊ុយអ៊ែត ជាមួយលោក លេវីប៉េទ្រូនៃក្រុមជំនុំហ្វីឡាដេហ្វា។ បងប្អូនប្រុស ហ្គុលដុនលីនសាយដែលតឡូវ...ខ្ញុំគិត ខ្ញុំមិនគិតថាគាត់ជាកម្មសិទ្ធិនៅទីនោះទៀតឡើយបច្ចុប្បន្ន ប៉ុន្តែគាត់ជាកម្មសិទ្ធិ នៅក្នុងក្រុមជំនុំ ព្រះជាម្ចាស់។

83 ហើយក្រុមជំនុំគ្រួសារព្រះជាអ្នកឧបត្ថម្ភដល់ខ្ញុំយ៉ាងធំមួយ ជាអន្តរជាតិ។ និងដំណឹងល្អទាំង៤ គឺចេញពីក្រុមជំនុំព្រះជាម្ចាស់ ក៏ជាអ្នកឧបត្ថម្ភដល់ខ្ញុំយ៉ាងធំមួយដែរ។ ឃើញ? ហើយខ្ញុំក៏មានកន្លែងឈរ គឺចាកចេញពីគែមដែលមុតស្រួច ហើយក៏ឈរជាជំហរ ហើយខ្ញុំនឹងមិនឈរទាំង ផ្នែកណាមួយនៃការរុញឡើយ។ រហូតដល់

យើឃើញថាយើងជាបងប្អូននិងទៅជាមួយគ្នានិងបន្ទាប់មក យើងនឹង—យើងនឹងឃើញទាំងអស់ថាមានការឆ្លោះទៅត្រង់ដូចគ្នា ដែលយើងចូលមក ជម្រុញនិងមានគោលបំណងនៃការធ្វើយ៉ាងនេះ។

84 ហើយអ្នក—អ្នកត្រូវតែល្បងលការ ជម្រុញនិងគោលបំណងទីមួយ។ ទីមួយស្វែងរកបំណងព្រះទ័យ របស់ព្រះនិងបន្ទាប់ គឺស្វែងរកគោលដៅរបស់អ្នកនិងពិនិត្យការជម្រុញរបស់អ្នកនិងមើលថា តើការជម្រុញរបស់ អ្នកត្រឹមត្រូវឬទេ។ បន្ទាប់មកព្រះយេស៊ូវក៏មានបន្ទូលនៅក្នុងម៉ាកុស 11:24 "បើអ្នកនិយាយទៅកាន់ភ្នំដោយឥតសង្ស័យ 'ចូររើចេញ' និងមិនសង្ស័យក្នុងចិត្ត" ប៉ុន្តែដរាបណាអ្នកមានចិត្តសង្ស័យក្នុងចិត្តថា តើនោះជាព្រះហឬទ័យរបស់ព្រះឬអត់ ឬការជម្រុញ និងគោលបំណងរបស់អ្នកមិនត្រឹមត្រូវតើវារើទៅយ៉ាងណា? ប៉ុន្តែពេលអ្នកដឹងថាគោលបំណងរបស់អ្នកត្រឹមត្រូវ វាត្រូវតែរើ។ នោះគឺបែបនោះហើយ ឬ បើមិនដូច្នេះមានន័យថាព្រះមានបន្ទូលខុស។

85 នោះជាហេតុផល ពេលខ្ញុំទៅវេទិការ ក្នុងក្រុមជំនុំ មិនមាននរណាម្នាក់ឮខ្ញុំបញ្ជាក់ពីអ្វីលើវេទិការនោះទេ បញ្ហានោះ ខ្ញុំទុកឲ្យពួកគេនៅតាមរបៀបគេ។ ឃើញ វាអាស្រ័យលើ អ្នកជាអ្នកធ្វើ។ ឃើញ? ខ្ញុំនៅទីនេះដើម្បីជួយឈោងចាប់ព្រលឹងវិញ្ញាណថ្វាយដល់ព្រះគ្រីស្ទតាមរយៈអំណោយទានមកពីព្រះអ្នកឃើញ។ ឃើញ? វាមិនមានភាពខុសគ្នាឡើយ...អ្នកធ្វើការ ជ្រមុជទឹករបស់អ្នក។ ប៉ុន្តែបន្ទាប់មក ពេលវាមកដល់...

86 ជាប្រធានបទ ខ្ញុំត្រូវបានហៅថាជាអ្វីៗគ្រប់យ៉ាង។ ខ្ញុំត្រូវបានគ្រាស់ហៅ ខ្ញុំមិនដឹងថាប៉ុន្មាន នាក់កន្លែងណាមកពី—"ការប្រសូត្រនៃ ព្រះបុត្រារបស់ព្រះ" តទៅ—"អារក្ស" ដែលបែបនោះ គ្រប់យ៉ាង។ ប៉ុន្តែនៅពីក្រោយនោះ ខ្ញុំជាបងប្អូន ជាពលរដ្ឋដើរតាមនគររបស់ព្រះ ធ្វើការជាមួយអ្នកទាំងអស់គ្នា សម្រាប់នគរព្រះ។ និងវាជាការពិត។

87 ឥឡូវ ខ្ញុំនឹង បើវាត្រឹមត្រូវនិងអ្នកគិតថាយើងមានពេលត្រូវ ខ្ញុំចង់ប្រាប់អ្នកពីរបៀបយើងពិភាក្សានោះ។ អ្នកនឹងមិនមានបញ្ហា បងប្អូន សុំត្រឹមពេលមួយនាទី? [អ្នកដឹកនាំនិយាយ "បន្តចុះពិតណាស់"—Ed]។ បងប្អូនបងប្អូន ប្រុសណែស (Ness)និងពួកគេ...ត្រូវហើយ។ និងវាអាចជួយអ្នកបន្តិច។ វានឹងជួយអ្នកឲ្យយល់ប្រភេទនៃ។

88 ខ្ញុំសរសេរទីនេះ ជាអ្វីៗដែលខ្ញុំចងចាំពួកគេចេញពីទីនោះ។ និងដូច្នេះពួកគេសួរខ្ញុំ អ្វីដែលខ្ញុំជឿពី "ត្រីឯក" តើខ្ញុំជឿថាថា មានភាព "ត្រីឯក" នៃព្រះ?

89 ឥឡូវបងប្អូន ពេលយើងចូលទៅទីនេះ ខ្ញុំសង្ឃឹមថា ពេលវាចប់ យើងនឹងបានជាបងប្អូនដូចគ្នាដែលយើងទាំងអស់គ្នាដើរតមក។ ឃើញ? ប៉ុន្តែខ្ញុំមានអារម្មណ៍ថាខ្ញុំខ្ចីអ្នក ព្រោះមនុស្សរបស់អ្នកបានចូលរួមការប្រជុំ និងខ្ញុំមិនចង់ឲ្យនរណាម្នាក់ចាកចេញឡើយ ទាំងបញ្ឆោត។

90 ហើយខ្ញុំតែងតែប្រាប់ដល់ មនុស្សដែលសរសេរសំណួរមកខ្ញុំ ខាងក្រៅនៃអ្វីដែលខ្ញុំអធិប្បាយ លើវេទិការ...និងទីនេះគឺតែងតែជាលេខារបស់ខ្ញុំ និងបែបនេះ។ បើសិនពួកគេសួរសំណួរមកខ្ញុំ "ចុះយ៉ាង*នេះ*វិញ ចុះយ៉ាង*នោះ*វិញ?"

91 ខ្ញុំនិយាយ "សួរគ្រូគង្វាលរបស់អ្នកឃើញ។ ព្រោះបើគាត់ ដឹកនាំអ្នកឆ្ងាយរហូតដល់អ្នកទទួល ព្រះវិញ្ញាណបរិសុទ្ធ គាត់នឹងនាំអ្នកបន្តទៀត អ្នកឃើញ។ អ្នកឃើញ អ្នកសួរគ្រូគង្វាលរបស់អ្នក" ព្រោះការតូចមួយបែបនោះនាំឲ្យមានការយល់ច្រឡំ និងដូច្នេះខ្ញុំចាកចេញពីវា អ្នកឃើញ។

92 ឥឡូវខ្ញុំបាននិយាយថាខ្ញុំជា—អ្នកច្បាំងជាមួយអង្គការ។ ឥឡូវខ្ញុំមិនមែននោះទេ។ ខ្ញុំគិតថាអង្គការនោះគឺល្អហើយ ប៉ុន្តែពេលប្រព័ន្ធនៃអង្គការរបស់អ្នកពុកខូចនោះហើយជាអ្វីដែលខ្ញុំទាស់ប្រឆាំង។ ឃើញ? មិនថាអ្វីទេជាភាពតែមួយឬ—ឬវាជាត្រីឯកឬអ្វីក៏ដោយ ប្រព័ន្ធដែលពេលអ្នកទៅ ដល់ចំណុចអ្នកឥឡូវ...ហើយនិយាយ "យើងជាក្រុមជំនុំព្រះជាម្ចាស់។"

"ល្អ នរណាដែត្រូវឆ្លងផ្លូវ?"

93 "អូ នោះជាបងប្អូនរបស់យើង។ ពួកគេជា—ពួកគេត្រូវបានហៅថាសហព័ន្ធពេនទីកុស្ត។"

"ល្អ នរណានៅទីនោះ?"

94 "អូ មានបងប្អូនមកពីដំណឹងល្អទាំងបួន។ អូ យើងជាបងប្អូនយ៉ាងល្អ។ យើងមានការប្រកបអស្ចារ្យ រួមជាមួយគ្នា"

"អូ អ្នកទាំងអស់គ្នាជឿអ្វីដូចគ្នា?"

"អូ មែន យើងជឿ។"

"ឥឡូវ ល្អ ចូរអ្នកធ្វើបែបនេះ?"

95 "ល្អ បងប្អូន*ទាំងនេះ*បានជ្រមុជទឹកតាមរបៀប*នេះ*។ និងការជ្រមុជរបៀប*ទាំងនេះ* របៀប*នេះ* ខុសពីយើង និងការជ្រមុជទឹក*នេះ*..."

96 ដូចជានៅអាហ្វ្រិកខាងត្បូង បងប្អូន យើងរត់តាមបែបនោះ។ ពួកគេសួរខ្ញុំ។ ក្រុមមួយដែលជ្រមុជទឹកបីដង មុខទៅមុខ។ និងក្រុមមួយទៀតជ្រមុជទឹកបីដង មុខបែរក្រោយ និងពួកគេនិយាយ...ខ្ញុំនិយាយ "តើអ្នកទទួលវាមកពីណា?"

97 ម្នាក់និយាយថា "ពេលទ្រង់សុគត ព្រះគម្ពីរនិយាយថាទ្រង់ដួលទៅមុខ" និងនិយាយ "ដូច្នេះយើងគួរផ្តួលពួកគេទៅមុខ។"

98 និងខ្ញុំនិយាយ "ល្អ" ទៅក្រុមមួយទៀត "តើ...ចុះអ្នកវិញ?"

និយាយ "តើអ្នកធ្លាប់កប់មនុស្សផ្កាប់មុខទេ?"

99 ល្អ តើអ្នកដឹងទេថាហេតុអ្វី? ពួកគេញែកខ្លួនដោយផ្ទាល់ និងបង្កើតជាក្រុមពីរ។ អូ ជួយផងបងប្អូន! នោះជាអ្វីដែលអារក្សចង់។ នោះជាអ្វីដែលវាចង់។ មែន។ ស្វែងយល់ខ្លួនអ្នកចុះ...

100 ឥឡូវឃើញវាមិនមែនជា បេសកកម្មជំនឿសាវកទេ ឬ—ឬគឺទាំងវាជាក្រុមជំនុំពេនទីកុស្តនៅផ្នែកម្ខាងទៀត។ វាមិនមែនដូច្នេះឡើយ។ មានមនុស្សល្អទាំងពីរក្រុម ដូចនៅទីនេះដែរ។ ប៉ុន្តែ អ្នកឃើញហើយពីប្រព័ន្ធនៃអ្វីៗ។

101 វាដូចជាកាតូលិកដែរ ដូចអ្វីខ្ញុំបាននិយាយញឹកញាប់។ បើសិនជាគាត់ជាកាតូលិក និងពឹងលើព្រះគ្រីស្ទដើម្បីសេចក្តីសង្គ្រោះ គាត់ទទួលបានការសង្គ្រោះហើយ។ ពិតណាស់ នោះត្រឹមត្រូវហើយ។ បើសិនជាគាត់ពឹងលើក្រុមជំនុំ គាត់វង្វេងហើយ។ និងទោះបីជាបងប្អូនពេនទីកុស្តណាមួយស្គាល់ថា បើយើងស្វែងរក ក្រុមជំនុំពេនទីកុស្ត ណាមួយដើម្បីសង្គ្រោះយើង "យើងនៅក្នុងចំណោមមនុស្ស ដែលអាក្រក់បំផុត" នោះពិតហើយ ព្រោះយើងវង្វេង។ នោះត្រឹមត្រូវហើយ។

102 ប៉ុន្តែ បើសិនជាយើងស្វែងរកព្រះយេស៊ូវគ្រីស្ទ ដូច្នេះយើងបានការសង្គ្រោះហើយ "ដោយជំនឿរបស់អ្នក" (នោះ អ្វី?) ជាកិច្ចការបានបញ្ចប់។ និងអ្វីដែលបានធ្វើតិចតួចនេះ និងស្លាកសញ្ញា វាមិនបានធ្វើឲ្យមាន ភាពខុសគ្នាខ្លាំងនោះទេ។

103 ឥឡូវ ខ្ញុំនិយាយទៅកាន់បងប្អូនប្រុស Scismដើម្បី...និងបងប្អូនប្រុសណោស "ដើម្បីឆ្លើយសំណួររបស់អ្នក" ខ្ញុំនិយាយ "ឥឡូវ ខ្ញុំមិនយកខាងណា

ទាំងអស់ជាមួយអ្នក។ ហើយខ្ញុំដឹងទោះបីជាអ្នកុញ ប៉ុណ្ណាក៏ដោយ អ្នកទាំងពីរគឺខុស។ ឃើញ? ពីព្រោះខ្ញុំអាចខុសក្នុងគោលលទ្ធិរបស់ខ្ញុំនិងត្រូវក្នុងចិត្តជាងត្រូវក្នុងគោលលទ្ធិរបស់ខ្ញុំប៉ុន្តែខុសក្នុងចិត្ត" ឃើញ? ខ្ញុំនិយាយ "បន្ទាប់មក វាជាល័ក្ខខណ្ឌក្នុងចិត្ត។"

104 និងខ្ញុំធ្វើការអនុវត្តនោះឡើង ដើម្បីឲ្យដឹងការនេះៈនោះ បើមនុស្សម្នាក់ មិនថាគាត់ធ្វើអ្វីឡើយ និងគាត់ខុសប្លែកប៉ុណ្ណាទេ និងគាត់និយាយអ្វីពីខ្ញុំ បើសិនជាក្នុងចិត្តខ្ញុំមិនមែនមកពីតួនាទី ប៉ុន្តែមកពីចិត្ត ខ្ញុំមិនអាចស្រឡាញ់អ្នកនោះបានឡើយ ក៏ដូចជាស្រឡាញ់អ្នកណាផ្សេងទៀតដែរ ដូច្នេះ ខ្ញុំដឹងថាមានអ្វីមួយខុសនៅត្រង់នេះ ឃើញ។ នោះត្រឹមត្រូវហើយ ព្រោះវាជា—វា...មិនថា បើសិនជាគាត់...

105 បងប្អូនប្រុសតូចមួយចូលមក មិនជាយូកន្លងទេ ជាបងប្អូនប្រុសមកពីក្រុមជំនុំព្រះគ្រីស្ទ។ និង អូ គាត់ឈរឡើងត្រង់នោះ និងនិយាយ "មនុស្សនេះជាអារក្ស" ឃើញ? គាត់និយាយ "គាត់និយាយពីព្រះវិញ្ញាណបរិសុទ្ធ" គាត់និយាយ "មិនមានអ្វីបែបនោះឡើយ។ ពួកគេ ល្អ មានតែសាវកទាំងដប់ពីរប៉ុណ្ណោះដែលទទួលព្រះវិញ្ញាណបរិសុទ្ធ។ និង—និងកាប្រោសឲ្យជាពីព្រះប្រទានឲ្យតែសាវកទាំងដប់ពីរប៉ុណ្ណោះ" និង បន្តកន្លះម៉ោង។

106 ហើយខ្ញុំនិយាយ "មួយខណៈពេល បងប្អូន។ ខ្ញុំគិតអ្នកគួរតែផ្តល់ឱកាសដល់ខ្ញុំការពារការនេះ មើល។" ខ្ញុំនិយាយ "អ្នកនិយាយថា អ្នកនិយាយថាកន្លែងណាដែលព្រះគម្ពីរនិយាយ និង តើស្ងាត់ នៅកន្លែងណាដែលស្ងាត់"

ហើយ គាត់និយាយ "យើងធ្វើ។"

107 ខ្ញុំនិយាយ "ឥឡូវអ្នកនិយាយ មានសាវក ទាំងដប់ពីរតែប៉ុណ្ណោះដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ។ ព្រះគម្ពីរនិយាយ 'មានមនុស្ស មួយរយម្ភៃនាក់នៅបន្ទប់ខាងលើពេល ដែលព្រះវិញ្ញាណបរិសុទ្ធយាង ចុះមកស្ត្រីនិងទាំងអស់គ្នា។' និង តើអ្នកមិនថាអីទេដែលប្រាប់ខ្ញុំថា តើអ្នកគិតថាប៉ុលមិនមានព្រះវិញ្ញាណបរិសុទ្ធ? ព្រោះគាត់ទទួលបានបន្ទាប់ពីព្រឹត្តិការណ៍នោះឃើញ។ ហើយអ្នកនិយាយ 'អំណោយទានប្រោសឲ្យជា ប្រទានឲ្យតែសាវកទាំងដប់ពីរតែប៉ុនោះ' ហើយស្ទេផានបានមកនៅបីបួនថ្ងៃក្រោយ គាត់មិនមែនជាម្នាក់ក្នុងចំនោមសាវកទាំងដប់ពីរឡើយ គាត់មិនទាំងជាអ្នកអធិប្បាយផង។ គាត់ជាចាស់ទុំនិងចុះទៅ

សាម៉ារីក៏ដេញអារក្ស" ហើយខ្ញុំនិយាយ "អូ បងប្អូនអើយ!" វាស្ងាត់ណាស់នៅត្រង់នេះមែនទេ តើអ្នកចង់ទុកវាចោលឬ។

108 ហើយបន្ទាប់ពីវាបានចប់ទៅ"ប៉ុន្ដែ" ខ្ញុំនិយាយ "ខ្ញុំអត់ទោសឲ្យអ្នកដែលហៅខ្ញុំថាអារក្ខ ព្រោះខ្ញុំដឹងថាអ្នកមិនមានន័យបែបនោះឡើយ។"

109 ហើយបន្ទាប់ពីគាត់បានបញ្ចប់ គាត់ឡើងមក។ គាត់នយាយ "មានរឿងមួយដែលខ្ញុំអាចនិយាយ។ អ្នកមានវិញ្ញាណនៃព្រះគ្រីស្ទ។"

110 ខ្ញុំនិយាយ "ឥឡូវបងប្អូនអើយខ្ញុំជាមួយណា អារក្ខឬព្រះគ្រីស្ទ?" ឃើញ? ឃើញ?

111 ប៉ុន្ដែខ្ញុំប្រាប់អ្នកមើលព្រោះ នោះជាបុរសម្នាក់ គាត់អាចប្រាប់ថាខ្ញុំស្រឡាញ់គាត់មិនថាជាអ្វី គាត់មិនយល់ស្រប និងមិនយល់ស្របយ៉ាងខ្លាំង និងជេរប្រទេចក៏ដោយ។ គាត់...

112 ខ្ញុំជាអ្នកប្រម៉ាញ់ សត្វព្រៃពេញមួយជីវិតរបស់ខ្ញុំ។ ហើយមនុស្សបាននិយាយ "ដោយរបៀបណា..."ពេលនោះពេលដែលខ្ញុំ ត្រូវសម្លាប់ខ្លាឃ្មុំដោយកាំបិត មើល។ និយាយ "តើអ្នកមិនខ្លាចទេឬ?"

113 ខ្ញុំនិយាយ "ទេ បើខ្ញុំខ្លាច វានឹងសម្លាប់ខ្ញុំ ឃើញ។"

114 ប៉ុន្ដែមើល អ្នកមិនអាច—អ្នកមិនអាចបញ្ឆោតពួកវាបាន។ វាដឹងថាអ្នកខ្លាចវា ឬអត់។ អ្នកខ្លាចសេះ នោះសម្លឹងមើលតើសេះធ្វើយ៉ាងណា វានឹងជាន់អ្នក។ ឃើញ? ដូច្នេះ បើអ្នកខ្លាច...អ្នកមិនអាចបញ្ឆោតវាបានឡើយ។ អ្នកត្រូវតែចាប់វា។

របៀបនោះ ក៏ដូចជាអារក្ខសាតាំងដែរ។

115 នោះជារបៀបក្នុងចំណោមមនុស្ស។ អ្នកត្រូវតែស្រឡាញ់មនុស្ស។ អ្នកមិនអាចបញ្ឆោតគេបាន។ អ្នកត្រូវតែយល់ បើមិនដូច្នោះ ពណ៌របស់អ្នកនឹងលេចចេញពេលណាមួយត្រង់កន្លែងណា ឃើញ។ នោះគឺត្រឹមត្រូវ។ អ្នកត្រូវតែស្រឡាញ់មនុស្ស ហើយពួកគេដឹងថាអ្នកស្រឡាញ់គេ។ មើលមានអ្វីចំពោះវា។

116 ហើយមានមនុស្សម្នាក់ឥឡូវ ហៅប្រពន្ធខ្ញុំ ពីរបីថ្ងៃកន្លង និងនិយាយ "តើបងប្អូនប្រុសប្រានហាំនៅឬទេ?"

និយាយ "ទេ។"

117 និយាយ "ល្អ មានរឿងមួយខ្ញុំត្រូវនិយាយ។ ខ្ញុំមិនយល់ស្របជាមួយគាត់ ក្នុងផ្នែកទេវសាស្ត្រ ប៉ុន្តែខ្ញុំនិយាយគាត់ជាអ្នកបម្រើរបស់ព្រះគ្រីស្ទ។"

118 ល្អ ដូច្នេះនិងមុនខ្ញុំចាកចេញគាត់ផ្ញើ សំបុត្រមកខ្ញុំនិងគាត់និយាយ "ខ្ញុំមកហើយ ពេលណាអ្នកត្រឡប់មកវិញ។ ខ្ញុំចង់ជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធដែលអ្នកបាននិយាយ"

119 ដូច្នេះ អ្នកឃើញកន្លែងដែលអ្នកមាន...បើសិនជាខ្ញុំមានអារម្មណ៍នោះ ដោយនិយាយ "ហេតុអ្វី អ្នកមិនជាអ្វីនោះទេ និកាយចាស់របស់អ្នកមិនល្អនោះទេ និង—និងមនុស្សទាំងអស់ នៃក្រុមជំនុំនៃ ព្រះគ្រីស្ទរបស់អ្នកទាំងអស់សុទ្ធតែមិនល្អ។ អ្នកមិនល្អ—អ្នកជាអារក្ខ" ខ្ញុំនឹងមិនទទួលបានបុរសម្នាក់នោះឡើយ។ ហើយបើខ្ញុំប្រាប់គាត់បែបនេះថាខ្ញុំស្រឡាញ់គាត់។ ហើយបើខ្ញុំប្រាប់គាត់ថាខ្ញុំស្រឡាញ់គាត់ និងមិនមានន័យពិតក្នុងចិត្ត គាត់នឹងមិនដឹងកាន់តែច្បាស់នោះទេ។ នោះជាអ្វីដែលត្រូវធ្វើ។ អ្នកត្រូវតែមានន័យពិតក្នុងចិត្ត។

120 និងមានយប់មួយពេល ខ្ញុំដើរចេញពីវេទិការ ដោយអំណាចនៃការស្មង់វិញ្ញាណ។ ខ្ញុំមិនគិតពីវាទេ។ ខ្ញុំមិនបានបរិភោគមក ពីអាហារពេលល្ងាច និងអធិស្ឋានហើយតម និងស្នាក់នៅក្នុងបន្ទប់។ ព្រោះទ្រង់សន្យាទ្រង់នឹងធ្វើវា។ ហើយដូច្នេះ ខ្ញុំចាកចេញដោយគ្មានស្រមោលនៃការសង្ស័យ ព្រោះទ្រង់សន្យាទ្រង់នឹងធ្វើ។ ដូច្នេះ មើល របស់ខ្ញុំ...ខ្ញុំស្គាល់ការជម្រុញរបស់ខ្ញុំជាអ្វី(អ្វី?) គោលបំណងរបស់ខ្ញុំជា(អ្វី?) សម្រាប់តែនគរព្រះ។

121 បើមនុស្សទៅដោយ*របៀបនេះ របៀបនោះ* ក្រុមជំនុំណាក៏ដោយដែលគាត់ទៅ ដរាបណាគាត់ចូលមកក្នុងព្រះគ្រីស្ទ នោះមិនជាបញ្ហាសម្រាប់ខ្ញុំឡើយ។ ហើយនោះជាចិត្តរបស់ខ្ញុំឃើញ? និងមិនមានបញ្ហាទេបើយងទៅចូលរួមក្រុមជំនុំព្រះគ្រីស្ទ នោះក៏មិនអីដែរ។ នោះគឺមិនជាអ្វីឡើយ។ នោះមិនអីទេ។ បើគាត់...ក្រុមជំនុំមួយណាក៏ដោយដែលគាត់ចូលរួម វាមិនមានបញ្ហាសម្រាប់ខ្ញុំឡើយ។ ប៉ុន្តែដរាបខ្ញុំអាចទទួលបានព្រលឹងមនុស្សជាមួយព្រះគ្រីស្ទ នោះជារឿងចំបង។

122 ដូច្នេះខ្ញុំនិយាយ "បងប្អូនប្រុស Ness មិនមានភាពខុសប្លែកទេ..."ឥឡូវខ្ញុំនឹង...វាអាចទេដែលប្រើ*បែបនេះ* បងប្អូនប្រុស? [បងប្អូនប្រុសនិយាយ "ប្រាកដណាស់"—Ed។] ខ្ញុំនិយាយ "ខ្ញុំចង់និយាយ និងពន្យល់" និងក្នុងរបៀបនេះខ្ញុំអាចនិយាយទៅកាន់បងប្អូននៅទីនេះ។ ឥឡូវ កុំបញ្ជាក់បង្ហាញក្នុងចំណោមពួកជំនុំ

ប្រជុំរបស់អ្នកឡើយ។ បើអ្នកនឹង ធ្វើឲ្យខ្ញុំរឿងមួយ ត្រឹម—ត្រឹម—ត្រឹមតែឲ្យខ្ញុំក្លាយជាបងប្អូនរបស់អ្នក។ អ្នកឃើញ? និងខ្ញុំនិងបើ—បើខ្ញុំខុសដូច្នេះសូមអ្នកអត់ទោស ឲ្យខ្ញុំ។ ប៉ុន្តែខ្ញុំចង់ពន្យល់ដល់អ្នក មានទាំងពីរក្រុមអង្គុយទីនេះនៅព្រឹកនេះ ទាំង Oneness និង—ក្រុមជំនុំ Assemblies ក៏មានទាំង អ្នកជឿព្រះត្រីឯកផងដែរ។

123 ឥឡូវ ខ្ញុំចង់ធ្វើសេចក្តីថ្លែងនេះ។ ខ្ញុំចង់និយាយថាទាំងសងខាងគឺខុសដរាបណាគេនៅតែជជែកឈ្លោះជាមួយភាគីម្ខាងទៀត ព្រោះការជម្រុញរបស់គេខុស។ និងកាល បើការជម្រុញរបស់អ្នកខុស មិនថាអ្នកមានគលបំណងអ្វីទេ ប៉ុន្តែការជម្រុញចំពគោលបំណងខុស ដូច្នេះនោះមិនមានដំណើរការឡើយ។ នោះគឺត្រូវហើយ។

124 ឥឡូវ មនុស្សខ្លះនិយាយ "បងប្អូនប្រុសប្រានហាំ អ្នកគឺមកពីព្រះយេស៊ូវតែ មួយគត់" ខ្ញុំចង់និយាយថានោះគឺខុសហើយ។ ខ្ញុំមិនមែនមកពី ព្រះយេស៊ូវតែមួយគត់នោះទេ។

125 មាននរណាម្នាក់និយាយ "បងប្អូនប្រុសប្រានហាំ អ្នកមកពីក្រុមត្រីឯករឺ?" ទេលោក។ ខ្ញុំមិនមែនជាអ្នកត្រីឯកនោះទេ។ ឃើញ? ខ្ញុំ—ខ្ញុំ—ខ្ញុំមិន...ពាក្យត្រីឯកមិនទាំងមាននៅ ក្នុងព្រះគម្ពីរឡើយពាក្យ "ត្រីឯក" និងខ្ញុំមិនជឿថាមានព្រះជាបុគ្គលឡើយ។

126 ខ្ញុំជឿថាមានព្រះតែមួយក្នុងការិយាល័យ: ព្រះវរបិតា ព្រះបុត្រា ព្រះវិញ្ញាណបរិសុទ្ធ នោះជាហេតុដែលយើងត្រូវមានបេសកម្មឲ្យជ្រមុជទឹកក្នុងនាម ព្រះវរបិតា ព្រះបុត្រា ព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំជឿថាជាព្រះបន្ទាបអង្គយាងចុះមក។

127 ឥឡូវព្រះពេលទ្រង់លេចចេញដំបូងមកកាន់មនុស្ស ទ្រង់មានទម្រង់ជាសរសភ្លើង។ អ្នកជឿទេ ឬមិនជឿ? មាន...អ្នកអានព្រះគម្ពីរមួយចំនួនដឹងថាសរសរភ្លើងនោះគឺក្នុងវាលរហោស្ថាន ជាសញ្ញាប៉ុណ្ណោះ នោះនោះជាទេវតានៃការតាំងសញ្ញាជាព្រះគ្រីស្ទ។

128 ព្រោះ ទ្រង់មានបន្ទូល...ទ្រង់ជា...វាមិន...ខ្ញុំជឿគឺលោកសាវកយ៉ូហាន6 នៅទីនោះ គាត់និយាយ "មុនអាប្រាហាំ" នៃ "គឺយើងមានវត្តមាន" ទ្រង់ជា "ព្រះមានវត្តមាន។"

129 ដូច្នេះគឺជាព្រះ បរិសុទ្ធទោះបីជាមនុស្ស ប៉ះភ្នំក៏ដោយអ្នកនោះត្រូវតែស្លាប់ មើល។ ជាការពិត។ ឥឡូវ នោះដូចគ្នាជាមួយព្រះដែលព្យាយាមធ្វើការរបស់ទ្រង់ ត្រឡប់មកស្នាព្រះហស្តទ្រង់បង្កើត។ ឥឡូវ ទ្រង់មិនអាចមកជិតពួកគេ ព្រោះ ពួកគេមានបាប និងឈាមនៃកូនពពែ និង ចៀមមិនអាចយកបាបចេញបាន ឡើយ។ យើងដឹង។ វាត្រឹមគ្របបាំងបាបប៉ុណ្ណោះ។

130 ឥឡូវគឺជាព្រះដដែលនៅសសរភ្លើង ទ្រង់បានក្លាយជាសាច់ឈាម តាមរយៈ ព្រះបុត្រានិងគង់ក្នុងរាងកាយដែលហៅថាអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះគម្ពីរនិយាយ "ក្នុងទ្រង់មានគ្រប់ទាំងសេចក្ដីពោរពេញរបស់ព្រះ។" និងព្រះយេស៊ូវមានបន្ទូល នៅក្នុង...ល្អក្នុងធីម៉ូថេខ្សែទីមួយ3:16 "ពិតប្រាកដជាសេចក្ដីអាថ៌កំបាំងរបស់ សាសនានៃយើង នោះជ្រាលជ្រៅណាស់" ហើយបើសិនពួកគេហៅថាអស្ចារ្យ ហេតុអ្វី យើងគួរធ្វើយ៉ាងណាឃើញ? "ពិតប្រាកដជាសេចក្ដីអាថ៌កំបាំងរបស់ សាសនានៃយើង នោះជ្រាលជ្រៅណាស់ គឺដែលព្រះបានលេចមកក្នុងសាច់ឈាម បានរាប់ជាសុចរិតដោយព្រះវិញ្ញាណ ពួកទេវតាបានឃើញទ្រង់ មនុស្សបាន ប្រកាសប្រាប់ពីទ្រង់ដល់ពួកសាសន៍ដ៏ទៃ មានគេជឿដល់ទ្រង់ក្នុងលោកីយ៍នេះ រួចព្រះបានលើកទ្រង់ឡើងទៅក្នុងសិរីល្អវិញ" និងតទៀត។ ឥឡូវ និងទ្រង់មាន បន្ទូលក្នុងយ៉ូហាន14 ទៅថូម៉ាស "ឬ អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញ ព្រះវរបិតាដែរ ចុះធ្វើដូចម្ដេចបានជាអ្នកថា សូមបង្ហាញឲ្យឃើញព្រះវរបិតា?" ព្រះគម្ពីរនិយាយថា "ព្រះគង់ក្នុងព្រះគ្រីស្ទ ហើយបានផ្សះផ្សាលោកកិយជាមួយ ទ្រង់។"

131 ឥឡូវ ព្រះទ្រង់មិនមែនជាបុគ្គលបីនោះឡើយ ព្រះបីអង្គ។ មិនមែនព្រះយេស៊ូវ ជាបីតារបស់ព្រះអង្គផ្ទាល់ផង។ ឃើញ? ដូច្នេះ អ្នកឃើញ វាធ្វើឲ្យមានភាពខុស។

132 ឥឡូវ និង ឥឡូវបើអ្នកត្រឹមតែកត់សម្គាល់ វាមិនមានកន្លែង...បើយើងមានព្រះ បីអង្គ យើងជាសាសន៍ដទៃ។ ឥឡូវយើងដឹង។

133 ដូចជាជនជាតិយូដានិយាយ មកកាន់ខ្ញុំពេលមួយ ពេលខ្ញុំនិយាយទៅកាន់ គាត់និយាយ "តើមួយណាក្នុងចំណោម នោះជាព្រះរបស់អ្នក? មួយណាជាព្រះ របស់អ្នក ព្រះវរបិតា ព្រះបុត្រា ឬព្រះវិញ្ញាណបរិសុទ្ធ? មួយណាជារបស់អ្នក?"

ហើយខ្ញុំនិយាយ "ហេតុអ្វីមិនមានព្រះបីអង្គ។"

134 គាត់និយាយ "អ្នកមិនអាចកាត់—កាត់ព្រះ ជាបីចម្រៀកនិងឲ្យទៅកាន់ពួកយូដាឡើយ។"

ខ្ញុំនិយាយ "ទេ លោក" ខ្ញុំនិយាយ...

135 ពេលដែលចនរីន(John Rhyn) ត្រូវបានប្រោសឲ្យជាពីខ្វាក់ភ្នែកនៅហ្វតវីន(Fort Wayne) អ្នកដឹងហើយ និងគ្រូរបស់គាត់នៅទីនេះនៅឯMishawa-... ឬទៅFort...Benton Harbor។ គាត់និយាយ "អ្នកមិនអាចកាត់ព្រះជាបីចម្រៀករួចហុចវាទៅឲ្យជនជាតិយូដាឡើយ។"

136 ខ្ញុំនិយាយ "ពិតជាមិនអាច ខ្ញុំមិនធ្វើចឹងទេ" ខ្ញុំនិយាយ "លោកគ្រូ តើពិបាកទេដែលលោកជឿព្យាការីទាំងនោះ?"

គាត់និយាយ "ទេ។"

137 ខ្ញុំនិយាយ "ក្នុងគម្ពីរអេសាយ9:6 តើគាត់កំពុងនិយាយពីនរណា 'ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១មកយើងហើយ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា និងជាម្ចាស់នៃមេត្រីភាព'?"

គាត់និយាយ "នោះជាព្រះមេស្ស៊ី។"

ខ្ញុំនិយាយ "ដូច្នេះលោកគ្រូ តើអ្វីជាទំនាក់ទំនងរវាងព្រះមេស្ស៊ីជាមួយព្រះ?"

គាត់និយាយ "ទ្រង់នឹងក្លាយជាព្រះ។"

138 "នោះជាអ្វីដែលខ្ញុំគិត" ឃើញ? ឥឡូវអ្នកឃើញ នោះជាភាពត្រឹមត្រូវ។ នោះជាទ្រង់និងខ្ញុំក៏និយាយ "ប្រាប់ខ្ញុំមកត្រង់ណា ដែលព្រះយេស៊ូវមិនបានបំពេញអ្វីដែលព្យាការីបានថ្លែងមកថាទ្រង់នឹងធ្វើ" និងគាត់ចាប់ ផ្ដើមយំនិងដើរជុំវិញ។ ខ្ញុំនិយាយ "ដោយសេចក្ដីនោះចនរីន(John Rhyn)បានភ្លឺភ្នែករបស់គាត់" ឃើញ?

និងគាត់និយាយ "ឆ្ងាយណាស់ពីរឿងព្រះមានព្រះបុត្រា!"

139 ខ្ញុំនិយាយ "មានព្រះយេហូវ៉ាគ្របបាំងលើស្ត្រីម្នាក់ ដូចព្យាការីបានថ្លែងថាទ្រង់នឹងធ្វើ និងបង្កើតបានជាកោសិកាឈាម។ ហើយតាមរយៈកោសិកាឈាមនោះគឺជាកន្លែងដែលរាងកាយព្រះគ្រីស្ទចេញមក។

140 "មើល ក្នុងសញ្ញាចាស់ លោកគ្រូ" ខ្ញុំនិយាយ "ពេលដែលមនុស្សថ្វាយតង្វាយ គេត្រូវយកកូនចៀម។ គាត់ដឹងថាគាត់ខុសនឹងវិន័យរបស់ព្រះ ដូច្នេះគាត់

យកកូនចៀម។ គាត់សារភាពបាបរបស់គាត់ និងចៀមរបស់គាត់ត្រូវតែសម្លាប់។ ពេល...ដៃរបស់គាត់ដាក់លើចៀម។ ការសារភាពរបស់គាត់ គឺថាគាត់ដឹងថាគាត់សមនឹងស្លាប់ សម្រាប់បាបរបស់គាត់ ប៉ុន្តែចៀមជាអ្នកដែលជំនួសគាត់វិញ។ ហើយកោសិកាឈាមត្រូវបំបែក ហើយគាត់ត្រូវកាន់ចៀម តូចដោយដៃរបស់គាត់ រហូតដល់គាត់មានអារម្មណ៍ថាជីវិតតូចមួយបានចេញពីវា និងហូរចេញ។ រួចពួកសង្ឃតាមមុខងារ បោះឈាមលើ—លើភ្លើង អាសនាដែលលឿងដូចស្ពាន់ដែលជំនុំជម្រះ។"

141 បន្ទាប់មក ខ្ញុំនិយាយ "មនុស្សនោះ ដូច្នេះ គាត់ចេញទៅទីនោះ ដឹងថាចៀមបានជំនួសកន្លែងគាត់ហើយ ប៉ុន្តែគាត់ចេញទៅមានចិត្តបំណងដដែលដូចពេលដែលចូលមក ឃើញ ព្រោះវាមិនអាចយកបាបចេញ។ ឃើញ? ប៉ុន្តែដូច្នេះ ករណីនេះ 'អ្នកថ្វាយបង្គំធ្លាបបន្សាត់មិនមានមនសិកានៃបាបទៀត'។ មាន មាន គង្វាយដែលធ្វើរៀងរាល់ឆ្នាំប៉ុន្តែ" ខ្ញុំនិយាយ"ឥឡូវ ពេលនេះ 'អ្នកថ្វាយបង្គំត្រូវបានបន្សាត់ មិនមានមនសិកាពីបាប'" ព្រោះ...

142 "មើលលោកគ្រូ។ នៅក្នុងអេម៉ូក្លូប៊ីនជីវិតតូចនោះមាននៅក្នុងកោសិកា វាចេញមកពីភេទបុរស ទៅក្នុងស្ត្រី។ ហើយនាងបង្កើតបានជាស៊ុត ប៉ុន្តែ មាន់ក៏អាចមានពងដែរ តើនោះមិនមែនមកពីបក្សីឈ្មោលទេវី វាមិនដែលញាស់ទេ។"

143 ហើយខ្ញុំនិយាយ "ដូច្នេះព្រះជាអង្គដែលអស្ចារ្យ ដែលមានគ្រប់ពលនិងគ្រប់កន្លែងបានយាងចុះមកជាផ្ទៃកតូចមួយទៅកាន់ពោះស្ត្រី។" ហើយខ្ញុំនិយាយ "ពេលយើងទទួលបាន ការសង្គ្រោះថ្ងៃនេះ...ព្រះយេស៊ូវ មិនមែនជាជនជាតិយូដា ឬ សាសន៍ដទៃឡើយក៏ក្លាយជា ស៊ុតដើម្បីបង្កើតជាសាច់ឈាម។ ក្នុងឈាមមានជីវិត។ ដូច្នេះយើង—យើងជា...ព្រះគម្ពីរនិយាយថា 'យើងបានសង្គ្រោះដោយលោហិតព្រះ' ឃើញ ទ្រង់មិនមែនជាជនជាតិយូដា ឬសាសន៍ដទៃឡើយទ្រង់ជាព្រះ។ ដូច្នេះពេលយើងចូលចំពោះអាសនានិងដាក់ដៃរបស់យើង ដោយជំនឿ នៅលើសិរសាទ្រង់និងមានអារម្មណ៍ថាស្រក់ទឹកភ្នែក និងសោកសៅនៅកាល់វ៉ារី និងសារភាពបាបរបស់យើង ដែលយើងបាខុស និងទ្រង់សុគតជួសយើង!

144 "ដូច្នេះ អ្នកឃើញ" ខ្ញុំនិយាយ "ឈាមនៃកូនចៀមមិនអាចត្រឡប់មកត្រង់ចំណុចនេះឡើយ ជាឈាមដែល...កោសិកាបានបំបែក និងជីវិតដែលលែងទៅ

នៅក្នុងការបំបែក ឈាមនៃកូនចៀម មិនអាចត្រឡប់មក អ្នកថ្វាយបង្គំវិញឡើយ ព្រោះវាជាជីវិតរបស់សត្វ និងវាមិនស៊ីគ្នាជាមួយជីវិតមនុស្សដែរ។

145 "ប៉ុន្តែនៅពេលនេះ ពេលដែលកោសិកាឈាមត្រូវបានបំបែក វាមិនត្រឹមតែមនុស្សទេ។ នោះជាជីវិតរបស់ព្រះ ត្រូវបានបញ្ចេញទៅ។ និងពេលអ្នកថ្វាយបង្គំបានដាក់ដៃ ដោយជំនឿ លើព្រះបុត្រារបស់ព្រះ និងសារភាពបាបរបស់គាត់ មិនមែនជាជីវិត នរណាផ្សេងទៀតឡើយ ប៉ុន្តែជីវិតរបស់ព្រះបានត្រឡប់មនុស្សនោះវិញដែលជាជីវិតអស់កល្ប។ ពាក្យថាសូ(*Zoe*) ដែលបានបកប្រែមក 'ជីវិតរបស់ព្រះផ្ទាល់'។ ហើយទ្រង់មានបន្ទូលថាទ្រង់នឹងប្រទានZoeដល់យើង ជាជីវិតអស់កល្ប និង ឥឡូវយើងជាបុត្រធីតារបស់ព្រះ។ នោះជាអ្នកហើយ"

146 ខ្ញុំនិយាយ "ឥឡូវនោះអ្វី? វាជាព្រះ ដែលបានបន្ទាបចុះមក។ ទ្រង់យាងមកដំបូង 'មិនមានមនុស្សណាអាចពាល់ដល់ទ្រង់' ព្រោះមនុស្សមានបាប។ ដូច្នេះទ្រង់យាងចុះមកជារាងកាយ 'ដើម្បីភ្លក្ស រសជាតិបាប...ដើម្បីទទួលយកបាប' ឃើញ ទ្រង់ជាអ្វីតែមួយដែលព្រះអាចធ្វើ ដើម្បីបានជាយុត្តិធម៌ គឺធ្វើវាបែបនោះ។"

147 សម្រាប់ឧទាហរណ៍ អ្វីថាតើខ្ញុំអាចមានការកាត់ក្ដីជាមួយអ្នកស្ដាប់នៅ ព្រឹកនេះ ដូចជាព្រះមានលើមនុស្សជាតិ និងខ្ញុំនិយាយថា "មនុស្សដំបូងដែលសម្លឹងមើលបង្គោលនោះ នឹងស្លាប់" និងថូមីហ៊ីក (Tommy Hicks) សម្លឹងមើលវា? ឥឡូវជាឧទាហរណ៍ ខ្ញុំយកខាល (Carl)-..."បងប្អូនប្រុសខាលសុន(Carlson) លោកត្រូវស្លាប់សម្រាប់គាត់" នោះមិនយុត្តិធម៌នោះទេ។ ខ្ញុំគួរនិយាយ "លីអូ(Leo) អ្នកជាជំនួយការរបស់ខ្ញុំ អ្នកស្លាប់ជំនួសគាត់" នោះក៏មិនយុត្តិធម៌ដែរ។ "ប៊ីលីប៉ុល(Billy Paul) កូនប្រុសរបស់ខ្ញុំ អ្នកស្លាប់ជំនួសគាត់" នោះមិនយុត្តិធម៌ឡើយ។ របៀបតែមួយដែលខ្ញុំអាចយុត្តិធម៌គឺយកកន្លែងនោះដោយខ្លួនឯងផ្ទាល់។

148 និងនោះហើយ ជាអ្វីដែលព្រះបានធ្វើ។ ព្រះទ្រង់ជាវិញ្ញាណ។ ហើយទ្រង់បង្កើត...ទ្រង់ ទ្រង់ប្ដូរវាសនារបស់ទ្រង់។ វាគួរតែត្រូវដាក់ទោស ចំពោះមនុស្សដើម្បីគិតពីព្រះយេហូវ៉ាតិចតួច។ ទ្រង់គួរយាងមក ហើយមានភាពជាមនុស្សពាក្យមុុដពេញលេញប៉ុន្តែទ្រង់យាងមកក្នុងស្នូក លើគំនរអាចម៍លាមក។ ជាព្រះយេហូវ៉ាតូចមួយយំដូចជាទារក។ ព្រះយេហូវ៉ាតូច លេងដូចជាក្មេងប្រុសម្នាក់។ ព្រះយេហូវ៉ាតូចធ្វើជាងឈើ ដូចជាមនុស្សធ្វើការ។ ព្រះយេហូវ៉ាតូចពេលវ័យជំទង់ ព្រះយេហូវ៉ាជាប់នៅ ចន្លោះស្ថានសួគ៌និងផែនដី ជាមួយនឹងក្រុមទាហានស្រវឹងនិង

ស្តោះទឹកមាត់ដាក់ព្រះភក្រ្ដទ្រង់។ ព្រះយេហូវ៉ាសុគតជំនួសកូនទ្រង់។ ព្រះយេហូវ៉ាសុគតដើម្បីរំដោះមិនមែនមនុស្សណាទៀតឡើយ ប៉ុន្តែគឺដោយព្រះអង្គទ្រង់! ឃើញព្រះដែលជាកិច្ចការរបស់ទ្រង់។ ហេតុអ្វី? ទ្រង់ព្យាយាមយកចិត្តមនុស្សមកវិញ។

149 ឥឡូវ យើងមិនអាចពាល់ទ្រង់មាន ទីនេះ យើងមានអារម្មណ៍ ស្គាល់ទ្រង់ដោយដៃ។ ឥឡូវទ្រង់ធ្វើយ៉ាងណា តាមរយៈតង្វាយនៃរាងកាយ? ទ្រង់ក្លាយជាព្រះយេហូវ៉ាក្នុងយើង។ យើងជាផ្នែកនៃទ្រង់។ នៅថ្ងៃបុណ្យទី50 សរសរភ្លើងឆេះឡើងផ្ទាល់ និងអណ្តាតភ្លើងតាំងនៅចំពោះម្នាក់ៗ បង្ហាញថាព្រះបានញែកអង្គទ្រង់ក្នុងចំណោមយើងក្នុងព្រះវិហារទ្រង់។

150 ដូច្នេះ បងប្អូន បើយើងអាចរួមគ្នា និងនាំសេចក្តីនោះមកជាមួយគ្នា! ដូច្នេះយើងអាចមានព្រះយេហូវ៉ាពេញលេញ ពេលយើងចូលរួមគ្នា។ ប៉ុន្តែយើងអាចដោយរបៀបណាពេលម្នាក់ *នេះ* និយាយភាសាដទៃនិងជ្រមុជដោយព្រះវិញ្ញាណម្នាក់ *នេះ* និង និយាយភាសាតិចតួចនៃភ្លើងនៅទីនេះ និងម្នាក់*នេះ*? ចូរដាក់ចូលគ្នា។

151 ពេលព្រះជាម្ចាស់នៅ ថ្ងៃបុណ្យទី50 យាងចុះមក និងព្រះគម្ពីរនិយាយ "អណ្តាតភ្លើងតាំងលើពួកគេ" និងពួកគេ..."ភាសាដទៃ ដូចជាភ្លើង" ជះមក។ វាជាសសរភ្លើងដែលបែងចែកទៅផ្ទាល់ ក្នុងចំណោមមនុស្ស ដែលយើងអាចធ្វើជាបងប្អូន។ "នៅថ្ងៃនោះអ្នកនឹងដឹងថាខ្ញុំនៅក្នុងព្រះបិតា ព្រះវរបិតានៅក្នុងខ្ញុំ ខ្ញុំនៅក្នុងខ្ញុំ និងអ្នកនៅក្នុងខ្ញុំ" និង យើង យើងរួមតែមួយ មិនបែងចែក។

152 ឥឡូវ ព្រះយេហូវ៉ាជាព្រះ មក*ទីនេះ* មិនអាចពាល់មនុស្សជាតិ ព្រោះច្បាប់នៃភាពបរិសុទ្ធរបស់ទ្រង់ ព្រះយេហូវ៉ាជាព្រះក្លាយជាបាបជំនួសយើង និងសងថ្លៃគឺដូចជាព្រះយេហូវ៉ាអាចយាងមកនិងរស់ក្នុងយើង។ ព្រះដែល*នៅលើ*យើង ព្រះដែលគង់*ជាមួយ* យើង ព្រះដែលគង់*ក្នុង* យើង។ មិនមែនជាព្រះបីអង្គជាព្រះមួយអង្គ! លោកសាស្រ្តាចារ្យឆ្កួតហើយ ព្យាយាមស្វែងរកវាឲ្យឃើញនោះ។ វា—វាជាការបើកសម្តែង។ វាត្រូវបើកសម្តែងចំពោះអ្នក។

153 ឥឡូវ ឥឡូវ ពេលចូលមកដល់ការជ្រមុជទឹកឥឡូវ មនុស្សជាច្រើន...ឥឡូវអ្នកត្រូវធ្វើបែបនោះ បងប្អូន ឬ វាដូចជាអ្វីដែលខ្ញុំបាននិយាយទៅកាន់បងប្អូនប្រុសScism និងបងប្អូនប្រុសNess នោះបើអ្នក...ជម្លោះ—ជម្លោះកើតមាន។ និង គ្រូជាច្រើនណាមួយនៅទីនេះ ដែលមានភាពបរិបូរណ៍ជាងខ្ញុំ ប៉ុន្តែខ្ញុំបាន

ធ្វើការសិក្សាយ៉ាងច្រើនពីប្រធានបទ។ ហើយខ្ញុំបានអាន*Pre—Nicene Fathers* និង*ក្រុមប្រឹក្សានីសិន* និងប្រវត្តិសាស្ត្រទៀត។

154 បញ្ហានោះមាននៅក្រុមប្រឹក្សានីសិន (Nicene) ទាំងពីរផ្នែកឆ្លោះទៅគ្រាប់ពូជនោះ ពេលក្រុមជំនុំកាតូលិកយកភាព ជ្រុលពេកនៃផ្នែកព្រះត្រីឯក និងអ្នកផ្សេងទៀតផ្ដោតលើការរួមគ្នា និងទាំងសងខាងក៏ងាកចេញពីប្រភពដើម។ ត្រឹមត្រូវណាស់ ព្រោះមនុស្សមានអ្វីដែលត្រូវធ្វើ។

155 អ្នកត្រូវអនុញ្ញាតិឲ្យព្រះធ្វើវា មិនចាំបាច់ប្រើការស្វែងរកវាទេ។ ចូរឲ្យនៅតែភាពជាបងប្អូន។ ចូរនៅតែបន្តជាបងប្អូននិងអនុញ្ញាតឲ្យព្រះធ្វើអ្វីដែលទ្រង់នឹងធ្វើ។ បើសិនជាទ្រង់ព្រះមិនមាន ដែនកំណត់និងជ្រាបសេចក្ដីទាំងអស់ និងកំណត់បានពីចុងបញ្ចប់ដែលមាន ប្រភពពីខាងដើម តើយើងអាចធ្វើអ្វីពីវាបានយ៉ាងណានោះ? ចូរបន្តទៀត។ នោះជាផ្លូវ។ រក្សាជំហាន ដូចខ្ញុំបាននិយាយពីយប់ម្សិលជាមួយយ៉ូស្វេខ្លាំងពូកែរបស់យើង។

156 ឥឡូវមើល បើសិនជាមាន ព្រះបីអង្គវា...ខ្ញុំចង់បង្ហាញបងប្អូនថាតើគួរអស់សំណើចយ៉ាងណា។ បើសិនជាមានព្រះបីអង្គ ដូច្នេះព្រះយេស៊ូវជាព្រះបិតាផ្ទាល់ទ្រង់—...ព្រះយេស៊ូវមិនអាចជាព្រះបិតាផ្ទាល់នោះទេ ជារួមតែមួយ។ និងបើសិនជាមានបីអង្គ ទ្រង់មិនប្រសូត្រនឹងកំណើតព្រហ្មចារីឡើយ។ ឥឡូវ តើប៉ុន្មាន...[បងប្អូនប្រុសប្រានហាំបង្ហាញ ប្រើវត្ថុបី—Ed]។ ខ្ញុំនឹងនិយាយបែប*នេះ* ជាព្រះបិតា និង *នេះ* ជាព្រះជាបុត្រា និង*នេះ* ជាព្រះវិញ្ញាណបរិសុទ្ធ។

157 ឥឡូវ ចំពោះអ្នកដែលជាបងប្អូនខុសៗគ្នានៅទីនេះ សូមអ្នកមើលការនេះមួយនាទីហើយ អ្នកនឹងឃើញ ខ្ញុំព្យាយាមចង្អុលបង្ហាញ។ ខ្ញុំអធិស្ឋានថាព្រះនឹងអនុញ្ញាតិឲ្យអ្នកឃើញវា។ ឥឡូវ មើល អ្នកទាំងអស់ជឿរឿងដូចគ្នា ប៉ុន្តែអារក្សនៅចន្លោះរវាងអ្នកទាំងពីរដើម្បីបំបែកបំបាក់។ វាជាការដូចគ្នា និងខ្ញុំនឹងបង្ហាញដល់អ្នកដោយជំនួយមកពីព្រះ និងដោយព្រះគម្ពីររបស់ព្រះ។ បើសិនជាវាមិននៅក្នុងព្រះគម្ពីរទេ ដូច្នេះកុំទទួលវា។ នោះជាការពិត។

158 ប៉ុន្តែឥឡូវសូមមើល [បងប្អូនប្រុសប្រានហាំបង្ហាញ ប្រើវត្ថុ—Ed។] *នេះ* គឺ(*អ្វី?*)ព្រះជាបិតា *នេះ*ព្រះជាបុត្រា *នេះ*ជាព្រះវិញ្ញាណបរិសុទ្ធ។ ល្អឥឡូវឈប់បន្តិច ដាក់វត្ថុទាំងបីនៅទីនេះ ព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។

159 អូ ខ្ញុំ—ខ្ញុំ មិនមានពេលដើម្បីធ្វើវាទេ ខ្ញុំ…[បងប្អូនប្រុសនិយាយ "ចូរបន្តទៀត! ចូរបន្តទៀត!"—Ed។] ប៉ុន្តែមើល ល្អ ខ្ញុំនឹងប្រញាប់ លឿនតាមតែអាចធ្វើទៅបាន។ សូមអត់ទោសឲ្យខ្ញុំផងបងប្អូន ប៉ុន្តែ ខ្ញុំ—ខ្ញុំ—ខ្ញុំ មិនបាច់និយាយជាមួយបងប្អូនទេ ហើយខ្ញុំ—ខ្ញុំចង់ធ្វើការនេះ។

160 និង ដូច្នេះ មើលព្រះជាបិតា ព្រះបុត្រា ព្រះវិញ្ញាណបរិសុទ្ធ។ ឥឡូវ នរណាជាព្រះបិតារបស់ព្រះគ្រីស្ទ? ព្រះជាព្រះបិតារបស់ព្រះយេស៊ូវគ្រីស្ទ។ យើងទាំងអស់ជឿថា នោះជាការពិត? [ពួកជំនុំនិយាយ "អាមែន"—Ed។] ត្រឹមត្រូវណាស់។

161 ដូច្នេះឥឡូវយើងនិយាយពីម៉ាថាយ28:19 ពេលព្រះយេស៊ូវមានបន្ទូល"ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ" ដប់ថ្ងៃក្រោមក ពេត្រុសនិយាយ "ចូរប្រែចិត្ត និងជ្រមុជទឹកដោយព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ទ" មានការបញ្រ្ចាស់គ្នាត្រង់មួយ។ ឥឡូវ ចូរកុំ…មាន…

162 គ្រប់គ្នាមានទីបន្ទាល់ និងអ្វីៗ ។ ត្រង់នេះជា នេះជាជំនឿរបស់ខ្ញុំ និងខ្ញុំនឹងដាក់វានៅមុខអ្នករាល់គ្នា បងប្អូន។ ខ្ញុំមិននិយាយថានេះជារឿងចេញពីវេទិការ វាអាស្រ័យលើអ្នក។ ប៉ុន្តែខ្ញុំចង់ឲ្យបងប្អូនឃើញអ្វីដែលនៅទាំងសងខាង ដូច្នេះព្រះវិញ្ញាណបរិសុទ្ធបើកសម្តែងវាទៅកាន់អ្នក ឃើញ។

163 ឥឡូវម៉ាថាយ28:19និងបើ—បើម៉ាថាយ28:19 បញ្រ្ចាស់ជាមួយកិច្ចការ2:38 ដូច្នេះនឹងមានភាព បញ្រ្ចាសគ្នា នៅក្នុងព្រះគម្ពីរ ហើយវាមិនមានតម្លៃទេដែលក្រដាសនេះសរសេរចេញមក។

164 ឥឡូវ បើសិនជាអនកកត់សម្គាល់នៅក្នុងម៉ាថាយជំពូក16 ព្រះយេស៊ូវផ្តល់ឲ្យពេត្រុសនូវការបើកសម្តែងមួយ និងផ្តល់នូវគន្លឹះ។

165 ឥឡូវសូមចងចាំ ព្រះគម្ពីរមិនមែនបើកសម្តែង ដោយទេវវិទ្យាធ្វើដោយការបញ្ឆោតមនុស្សទេ។ វាមិនដូច្នេះទេ។ វាជាការបើកសម្តែង។

166 វាជាការបើកសម្តែង ដែលចាប់ផ្តើម។ ហេតុអ្វីបានជាអេបិលបានថ្វាយទៅព្រះជាយញ្ញបូជាប្រសើរជាងកាអ៊ីន? "វាជាការបើកសម្តែងចំពោះគាត់" វាមិនមែនជាផ្លែល្វា ឬប៉ោម និងក្រូច និងផ្លែប៉ោមទេ។ បើសិនជាផ្លែប៉ោមអាចធ្វើឲ្យស្ត្រីដឹងថាខ្លួននៅអាក្រាត យើងគួរតែឆ្លងកាត់ផ្លែប៉ោមម្តងទៀត បងប្អូន។ តើអ្នកគិតដូច្នេះឬទេ?

ឥឡូវ នោះ សម្លេងនោះស្តាប់ទៅដូចជាសៅហ្មង ប៉ុន្តែខ្ញុំមានន័យថាបែបនោះទេ។ ប៉ុន្តែ វាមិនមែនជាផ្លែប៉ោម។ មិនមែនទេ លោក។ ឥឡូវ និងបើវាដូច្នេះ "វាត្រូវបានបើកសម្តែងទៅអេបិល" ថាគាត់ជាឈាមរបស់ឪពុក។ ដូច្នេះ គាត់ថ្វាយតង្វាយជាឈាមព្រោះវាជាការបើកសម្តែង។ អ្វីទាំងមូលគឺសង់ឡើងលើនោះ។

167 ឥឡូវមើលនេះជាបុរស នេសាទចាស់ម្នាក់ ដែលគេមិនយកចិត្តទុកដាក់មិនមានការអប់រំគ្រប់គ្រាន់ផង…ព្រះគម្ពីរនិយាយគាត់មិនសូវចេះដឹង មិនមានការរៀនសូត្រ។ ប៉ុន្តែគាត់មានជំហរនៅត្រង់នោះ និងព្រះយេស៊ូវសួសំណួរដល់គាត់ "តើអ្នកនិយាយថាខ្ញុំបុត្រមនុស្សជានរណា?"

168 មនុស្សម្នាក់និយាយ "ហេតុអ្វីអ្នកជា—អ្នកជាម៉ូ-…"ឬ"ពួកគេ—ពួកគេនិយាយ 'លោកជាម៉ូសេ។'"

"តើពួកគេ និយាយថាខ្ញុំជានរណា?"

មនុស្សម្នាក់និយាយ "ហេតុអ្វី លោកជាយេរេមា ឬ ព្យាការី និង *នេះ នោះ* ឬ អ្នកណា*ផ្សេងទៀត។*"

169 ទ្រង់មានបន្ទូល "នោះមិនមែនជាសំណួរ។ ខ្ញុំសួរ*អ្នក*។ អ្នកនិយាយថាខ្ញុំជានរណា?"

170 និង ពេត្រុសនៅស្ងៀម និងឆ្លើយ "ទ្រង់ជាព្រះបុត្រារបស់ព្រះ។"

171 ហើយទ្រង់មានបន្ទូល "មានពរហើយស៊ីម៉ូន កូនយូណាសអើយ" ឥឡូវសូមមើល។ "មិនមែនសាច់ឈាមទេដែលបើកការនេះដល់អ្នក ប៉ុន្តែព្រះវរបិតានៅស្ថានសួគ៌ទេតើ" ឃើញ?

172 ឥឡូវមើល ឥឡូវ ក្រុមជំនុំកាតូលិកនិយាយថាទ្រង់សង់ក្រុមជំនុំលើពេត្រុស។ នោះគឺខុសហើយ។

173 ក្រុមជំនុំប្រូតេស្តង់និយាយ "ទ្រង់សង់វាលើអង្គទ្រង់" ប៉ុន្តែឥឡូវពិនិត្យនិងរកមើល មើលវាជាយ៉ាងណា។

174 ទ្រង់សង់វាលើការបើកសម្តែងខាងវិញ្ញាណនៃថាទ្រង់ជានរណា ឃើញ ព្រោះទ្រង់មានបន្ទូល "មានពរហើយស៊ីម៉ូនកូនយ៉ូណាស។ មិនមែនសាច់និងឈាមទេដែលបើកសម្តែងការនោះដល់អ្នក។ ខ្ញុំហៅអ្នកថាស៊ីម៉ូន លើថ្មដានេះ" (ថ្មដាអ្វី?

ការបើកសម្តែង) "ខ្ញុំនឹងសង់ក្រុមជំនុំរបស់ខ្ញុំ និងទ្វានៃស្ថាននរកមិនអាចទាសបាន ឡើយ" [បងប្អូនប្រុសប្រានហាំគោះតុវេទិការបីដង—Ed។]។

175 ដូច្នេះពេលពេត្រុសឈរវត្តមាននៅ ម៉ាថាយ28 ដែលបាននិយាយដកស្រង់ និងត្រឡប់មកនិង ដប់ថ្ងៃក្រោយមក ដោយការបើកសម្តែង ង និងងការជ្រមុជ ដោយ "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ" ហេតុអ្វីបានជាគាត់ធ្វើដូច្នេះ? ជាមួយនឹងការបើក សម្តែងរបស់ព្រះ និងមានគន្លិះនៃនគរព្រះ បងប្អូន។

176 ឥឡូវខ្ញុំប្រហែលជាធ្វើ ឲ្យអ្នកឈឺចាប់មួយភ្លែត ម្ខាងនៃអ្នកប៉ុន្តែ ឈប់មួយភ្លែត។ វាមិនមានត្រង់ណាក្នុងព្រះគម្ពីរមិនមាននរណាម្នាក់ដែល ជ្រមុជទឹកដោយនាម "ព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" មិនមានខ គម្ពីរណានោះឡើយ។ ហើយបើមានធ្វើវាចុះ។ ហើយបើសិនជាអ្នក អាចរកឃើញ ត្រង់ណានៅក្នុងប្រវត្តិសាស្ត្រពីព្រះ រហូតដល់មានការបង្កើត ជាក្រុមជំនុំកាតូលិក ខ្ញុំចង់ឲ្យអ្នកធ្វើវា។ មិនមានត្រង់ណាឡើយ ឥឡូវ នោះជាករពិត។

ប៉ុន្តែឥឡូវសូមចាំ អ្នកជាក្រុមវ៉ៃនីស (Oneness) ដូចជាទីពីរ។

177 ឥឡូវ មិនមានត្រង់ណា...បើមនុស្សអាចបង្ហាញខ្ញុំអត្ថបទត្រង់កន្លែងកម្មវិធី ប្រើនៅក្នុងព្រះគម្ពីរជ្រមុជទឹកដោយនូវព្រះនាម "ព្រះវរបិតា ព្រះបុត្រា ព្រះវិញ្ញាណ បរិសុទ្ធ" អ្នកមានតួនាទីមកប្រាប់ខ្ញុំកន្លែង នរណាម្នាក់ជ្រមុជទឹកបែបនេះ។

178 ហើយមានអ្នកខ្លះ នៃពួកគេនិយាយ "ល្អ ខ្ញុំយកកន្លែងដែលព្រះយេស៊ូវមាន បន្ទូល មិនមែនពេត្រុសនិយាយ" បើសិនជាវាបញ្ច្រាសគ្នា ទៅវិញទៅមក តើយើង ធ្វើយ៉ាងណា? បើវាមិនមែនព្រះ អ្វីដែលជាផ្នែកនៃព្រះគម្ពីរគឺត្រឹមត្រូវ?

179 វាទាំងអស់គឺមានភាពប្រសព្វគ្នានិងរួមជាមួយគ្នា និងមានតែការបើកសម្តែង នៃព្រះតែមួយ។ សាលារបស់យើងនឹងមិនបង្រៀនឡើយ។ វាជាការបើសម្តែង ដែលអ្នកត្រូវតែមើល។

180 ដូច្នេះ បើមានមនុស្សពីរនាក់បញ្ច្រាស់គ្នា មួយផ្ទុយពីមួយ នោះតើព្រះគម្ពីរ ដែលយើងអាននោះជារបៀបណា? តើខ្ញុំអាចដឹងថាតើ យ៉ូហាន14ត្រឹមត្រូវឬទេ? តើខ្ញុំដឹងថាយ៉ូហានជំពូក3ត្រឹមត្រូវឬទេ? តើរបៀបណា តើ តើខ្ញុំដឹងរបៀបណា? មើល?

181 ប៉ុន្តែរបៀបតែមួយដែលខ្ញុំអាចមានជំនឿក្នុងព្រះ គឺដឹងថាព្រះ គម្ពីរនោះគឺត្រឹមត្រូវនិងជឿថាត្រឹមត្រូវ និងនៅតែត្រូវ។ ទោះបីជាខ្ញុំមិនយល់ ខ្ញុំធ្វើសកម្មភាពរបៀបណា។

182 ប៉ុន្តែពេលដែលភាព ផ្ទុយគ្នាកើតឡើង ដូច្នេះខ្ញុំទៅនៅពីមុខព្រះ ដើម្បីរកឲ្យឃើញ។ និង ទេវតាដូចគ្នាដែលនាំឲ្យខ្ញុំបានជួប និងនៅពេលយប់ វាដូចគ្នាជាអង្គដែលបង្រៀមខ្ញុំនេះ។ ឃើញ? ឥឡូវមើលថាតើវា តើនេះជាយ៉ាងណា។

183 ឥឡូវម៉ាថាយ28:19 ចូរពិនិត្យមើលមួយភ្លែត។ ឥឡូវខ្ញុំនឹងយកកិច្ចការ2:38ត្រង់នេះ ដែលពេត្រុសនិយាយ "ព្រះអម្ចាស់យេស៊ូគ្រីស្ទ" និងម៉ាថាយនិយាយ "ព្រះវរបិតា បុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។"

184 ឥឡូវសូមស្តាប់។ គាត់និយាយ "ជ្រមុជគេ..."មិន "ក្នុងព្រះនាមនៃព្រះបិតា ព្រះបុត្រា និងព្រះនាមព្រះវិញ្ញាណបរិសុទ្ធឡើយ" គាត់មិននិយាយបែបនោះ។ មិនមាន "នាម...ក្នុងនាម...ក្នុងនាម។"

185 គាត់មិននិយាយ "ជ្រមុជក្នុង*ព្រះនាម* នៃព្រះវរបិតា ព្រះបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ" ព្រោះវាមិនសមហេតុផល។

186 គាត់និយាយ "ជ្រមុជក្នុងព្រះនាម(នា-ម) នៃព្រះវរបិតា ព្រះបុត្រា និងវិញ្ញាណបរិសុទ្ធ" នោះជាការពិត? [ពួកជំនុំនិយាយ "អាម៉ែន"—Ed។]។ "...នៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" ជាការប្រសព្វគ្នា "និង និង និង។"

187 មិនមែន "ឈ្មោះ" មិន "ក្នុងព្រះនាមព្រះបិតា នាមព្រះបុត្រា នាមព្រះវិញ្ញាណបរិសុទ្ធ" មិនមែន "ក្នុងព្រះនាមនៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" ប៉ុន្តែ "ក្នុងព្រះនាម" នា—ម ឯកវចនៈ "នៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" ឥឡូវ តើឈ្មោះមួយណាជាឈ្មោះត្រឹមត្រូវក្នុងការជ្រមុជនោះ? វាជានាមតែមួយ។ តើមួយណា? គឺ "ព្រះបិតា" ជានាមត្រឹមត្រូវឬ ជា "ព្រះបុត្រា" ជានាមត្រឹមត្រូវ ឬជា "ព្រះវិញ្ញាណបរិសុទ្ធ"ជានាមត្រឹមត្រូវ?

188 វាជា "នាម" ត្រង់ណាមួយ។ នោះត្រូវទេ? [ពួកជំនុំនិយាយ "អាម៉ែន"—Ed។] ល្អ ឥឡូវខ្ញុំចង់សួរអ្នកអ្វីមួយ ដូច្នេះ។ បើសិន "នាម" ដូច្នេះ បើព្រះយេស៊ូវមានបន្ទូល "ជ្រមុជពួកគេដោយក្នុងព្រះនាមនៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ

បរិសុទ្ធ...”តើប៉ុន្មាននាក់ដែលជឿថា ព្រះយេស៊ូវមានបន្ទូលបែបនោះ? [“អាម៉ែន”] នោះជាបទគម្ពីរ។ វានៅក្នុងម៉ាថាយ28:19 “ក្នុងព្រះនាមនៃព្រះបិតា បុត្រា...។”

189 [បងប្អូនប្រុសប្រាបហាំមើលការរំខាន—Ed។] គឺអ្វីៗដែលយើង...ទេវាខ្ញុំគិត...ត្រឹមត្រូវទេលោក។ [បងប្អូនប្រុសនិយាយ “សូមទោស បងប្អូនប្រាបហាំ?”] បាទ។ [“ខ្ញុំចង់ប្តូរខ្សែរអាត់នេះ ហើយខ្ញុំមិនចង់បាត់វា] ត្រឹមត្រូវ [ខ្សែរអាត់ទទេ] ...?...។

190 ឥឡូវ “ក្នុងព្រះនាមព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ” ឥឡូវសូមស្តាប់បងប្អូនអើយ។ វាមិនមានអ្វីដែលថាក្នុងនាមនៃ “ព្រះបិតា”ព្រោះព្រះ*បិតា*មិនមែនជាឈ្មោះ។ វាជាងារ។ ក៏មិនមានអ្វីដូចជា នាមនៃ “ព្រះបុត្រា” ព្រោះព្រះ*បុត្រា*ជាងារ។ ក៏មិនមានអ្វីដែលថានាម “ព្រះវិញ្ញាណបរិសុទ្ធ” នោះគឺទ្រង់ជាទ្រង់។

191 ខ្ញុំនិយាយថានៅអាហារ ពេលព្រឹកមួយនិង មានស្រ្តីម្នាក់...មិនតាមលំដាប់ពិតណាស់ នរណាក៏ដោយអាចឆាឆៅ អ្វីៗបែបនោះ។ នាងនិយាយ “រង់ចាំមួយនាទី! ខ្ញុំសុំឲ្យអ្នកអត់ទោស!” និយាយ “ព្រះវិញ្ញាណបរិសុទ្ធជានាម។”

192 ខ្ញុំនិយាយ “នោះគឺវាដូច្នេះខ្ញុំជាមនុស្ស ប៉ុន្តែឈ្មោះរបស់ខ្ញុំមិនមែន ‘មនុស្ស’ឡើយ។”

193 វាជាព្រះវិញ្ញាណបរិសុទ្ធ។ នោះមិនមែនជាឈ្មោះនោះទេ។ នោះជាអ្វីមួយ។ វាជានាមមួយ ពិតណាស់ ប៉ុន្តែវាមិនមែន...វាជា—វាជា...វាមិនមែនជាឈ្មោះ។

194 ឥឡូវ បើទ្រង់មានបន្ទូល “ជ្រមុជទឹកពួកគេដោយព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ” និងមិនមែនព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធជាឈ្មោះ ដូច្នេះឈ្មោះនោះជាអ្វី? យើងចង់ស្វែងរក។

195 ឥឡូវយើងអាចមានអ្វីទាំងអស់ នៅកន្លែងមួយត្រង់នេះ បើអ្នកត្រឹមតែមើល និង—និង—និងប្រើពេលបន្តិចឥឡូវឬពន្យាពេលបន្តិចខ្ញុំមានន័យថាត្រូវនិយាយ។ ឥឡូវសូមសម្គាល់ម៉ាថាយ28:19។ ឥឡូវខ្ញុំមិននិយាយថា...

196 អ្នកអាចអ្នកប្រហែលអាចធ្វើវាមានបងប្អូនប្រុសស្រីខ្លះ អ្នកអាចយកសៀវភៅនៅថ្ងៃណាមួយ និងមើលខាងក្រោខ្នងវា និងនិយាយ “យ៉ូហាន និងម៉ារីរស់នៅរីករាយរៀងរហូត” ល្អ នរណាយ៉ូហាន និងម៉ារី? អ្វីជា...នរណាជាយ៉ូហាននិង

ម៉ារីដែលរស់នៅរហូត? មានវិធីតែមួយប៉ុនោះក្នុងការស្គាល់លោកយ៉ូហាន និងម៉ារី នោះវាជាចម្ងល់សម្រាប់អ្នកទៅវិញហើយអានទៀត។ ត្រូវអីទេ? [ពួកជំនុំនិយាយថា "អាម៉ែន"—Ed។] ត្រឡប់ទៅវិញនិងអាន វានឹងប្រាប់អ្នកនរណាជាយ៉ូហាន និងម៉ារី។

197 ល្អ បើសិនជាព្រះយេស៊ូគ្រីស្ទជាបុត្រានៃព្រះ ដែលមានបន្ទូល "ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមាន សិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ" មិនមែន *ជាព្រះបិតា ព្រះបុត្រា ឬព្រះវិញ្ញាណបរិសុទ្ធ* ជាឈ្មោះនោះទេ ដូច្នេះ បើសិនវាជាចម្ងល់ យើងប្រសើរជាងត្រូវទៅសៀវភៅដំបូង។

198 ឥឡូវសូមបើទៅវិញនៃទំព័រទីមួយ នៃគម្ពីរម៉ាថាយនិងយើង នឹងចាប់ផ្តើមទីនោះ ផ្តល់នូវទេវសាស្ត្រ រហូតដល់វាតចុះមកដល់ជំពូកទី18។

199 ឥឡូវមើលឥឡូវសូមពិនិត្យមួយនាទី។ [បងប្អូនប្រុសប្រានហាំបង្ហាញ ប្រើកម្មវត្ថុ—Ed។] នេះជាព្រះវរបិតា នៅផ្នែកខាងស្តាំខ្ញុំ នេះនៅកណ្តាលជាព្រះបុត្រា និងនេះជាព្រះវិញ្ញាណបរិសុទ្ធ។ ឥឡូវនេះជាព្រះបិតា នៃព្រះយេស៊ូវគ្រីស្ទ។ តើត្រូវឬទេ? [ពួកជំនុំនិយាយ "អាមែន"] ព្រះជាព្រះបិតានៃព្រះយេស៊ូវគ្រីស្ទ។ យើងទាំងអស់ជឿថាដូច្នេះ? ["អាមែន"] ត្រឹមត្រូវហើយ។

200 ឥឡូវម៉ាថាយ1:18 និយាយថា:

> *ឯកំណើតព្រះយេស៊ូវគ្រីស្ទ នោះបានកើតមកយ៉ាងដូច្នេះ គឺ...នាងម៉ារា មាតាទ្រង់ កាលដែលយ៉ូសែប...បានដណ្តឹងនាងហើយ នោះនាងមានគភ៌ ដោយព្រះវិញ្ញាណបរិសុទ្ធ មុនដែលបាននៅជាមួយគ្នា...*

201 [ពួកជំនុំនិយាយ "ព្រះវិញ្ញាណបរិសុទ្ធ"—Ed។] ខ្ញុំគិតថា ព្រះ ជាព្រះបិតា។

> *និងនាងនឹងប្រសូតបុត្រា១...ហើយអ្នកត្រូវថ្វាយព្រះនាមថាយេស៊ូវ...*

> *ឯយ៉ូសែប ប្តីនាង ជាមនុស្សសុចរិត...គាត់មិនចង់បើករឿងនាងឲ្យគេដឹងទេ បានជាគាត់គិតលែងនាងចេញ ដោយសំងាត់វិញ។*

> *កាលដែលគាត់កំពុង តែគិតពីការនោះ ស្រាប់តែមានទេវតានៃព្រះអម្ចាស់ លេចមកពន្យល់សប្តិ ប្រាប់គាត់ថា យ៉ូសែប ពូជហ្លួងដាវីឌ*

*អើយកុំឲ្យខ្លាចនឹងយកនាងម៉ារា ជាប្រពន្ធអ្នកឡើយ ដ្បិតបុត្រដែលមកចាប់ទំផ្ទៃនាង នោះកើតពី...*

202 [ពួកជំនុំនិយាយ "ព្រះវិញ្ញាណបរិសុទ្ធ"—Ed។] ខ្ញុំគិតព្រះគឺជាព្រះវរបិតារបស់ទ្រង់។ ដូច្នេះតើទ្រង់មានបិតាពីរអង្គរឺបងប្អូន? ["ទេ"] ទ្រង់មិនអាចមានទេ។ បើសិនជាទ្រង់បែបនោះ ប្រាកដជាទ្រង់ជាក្មេងឥតបានការ ហើយសាសនាបែបណាដែលយើងមាន? អ្នកត្រូវតែទទួលថាព្រះជាព្រះបិតា និងជាព្រះវិញ្ញាណបរិសុទ្ធគឺជាវិញ្ញាណផ្ទាល់។ ប្រាកដណាស់ វាបែបនេះ។ ពិតណាស់ វាជាវិញ្ញាណដដែល។ ឥឡូវ យើងត្រូវធ្វើឡើងបានហើយ និងឃើញបែបនោះ។

*នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថាយេស៊ូវៈព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប២១ នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា យេស៊ូវ ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប។*

*...ការទាំងនោះកើតមក ដើម្បីឲ្យបានសំរេចសេចក្តី...*

203 ខ្ញុំកំពុងដកស្រង់បទគម្ពីរ អ្នកជាអ្នកដឹកនាំដឹងហើយ ខ្ញុំបន្ត។

*...ដែលព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូល...ដោយសារ ហោរាថា*

*...មើលនាងព្រហ្មចារីនឹង មានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល* ដែលបានបកស្រាយ...

204 [បងប្អូនប្រុសប្រានហាំផ្អាក។ ពួកជំនុំនិយាយ "ព្រះគង់ជាមួយយើង"—Ed។] "ព្រះគង់ជាមួយយើង!" ត្រូវទេ? ["អាម៉ែន"]

205 ដូច្នេះនោះជាព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធរឺ? [បងប្អូនប្រុសនិយាយ "ព្រះយេស៊ូវគ្រីស្ទ"—Ed។] ល្អ ពិតណាស់។ វាជាហេតុផលដែលពេត្រុសជ្រមុជទឹកពួកគេក្នុងព្រះនាម "ព្រះយេស៊ូវគ្រីស្ទ"

206 ប៉ុន្តែ ខ្ញុំមិនខ្វល់ឡើយ បើសិនជាបងប្អូនជ្រមុជក្នុងនាមកុលាបនៃវាលសារ៉ុនជាផ្កាកំភ្លឹងដែលដុះនៅច្រកភ្នំជាផ្កាយព្រឹកនោះជានាមផងដែរ។ បើចិត្តរបស់អ្នកត្រឹមត្រូវចំពោះព្រះ ទ្រង់ជ្រាបចិត្តរបស់អ្នក។

207 ប៉ុន្តែឥឡូវ ឥឡូវ ខ្ញុំបញ្ជាក់បែបនោះ។ ឥឡូវ ឥឡូវ ខ្ញុំនិយាយ...ឥឡូវបងប្អូនប្រុសស៊ីម (Scism) និយាយ "ឥឡូវៗ" ត្រូវប្រាកដហើយ ក៏ដូចជា Oneness ដូច្នេះគាត់ត្រូវហើយពីកន្លែងនោះមក។

208 ឥឡូវខ្ញុំនិយាយ "ឥឡូវទីនេះខ្ញុំចង់និយាយអ្វីចំពោះអ្នកឥឡូវ" ឃើញ? ខ្ញុំនិយាយ "ឥឡូវខ្ញុំចង់បង្ហាញអ្នកសេចក្តីនេះទាំង មនុស្សទាំងពីរនិយាយការដូចគ្នា។"

209 ឥឡូវម៉ាថាយនិយាយ "ក្នុងព្រះនាមព្រះបិតា" គឺត្រឹមត្រូវ? [ពួកជំនុំនិយាយ "អាមែន"—Ed។]ត្រូវយពេត្រុសនិយាយ "ក្នុងព្រះនាមព្រះអម្ចាស់" ម៉ាថាយ28:19 និយាយ "ក្នុងព្រះនាមព្រះវរបិតា" និងកិច្ចការ2:38និយាយ "ក្នុងព្រះនាមព្រះអម្ចាស់" ដាវិឌនិយាយ "ព្រះអម្ចាស់មានបន្ទូលមកកាន់ព្រះអម្ចាស់របស់ខ្ញុំ" នោះជាអង្គណា? ព្រះបិតានិងព្រះអម្ចាស់គឺមាននាមដូចគ្នា ដាវិឌនិយាយ "ព្រះអម្ចាស់មានបន្ទូលមកកាន់ព្រះអម្ចាស់របស់ខ្ញុំ 'ចូរគង់នៅខាងស្តាំយើង'" ឃើញ "ក្នុងព្រះនាមព្រះបិតា ក្នុងព្រះនាមព្រះអម្ចាស់។"

210 ហើយម៉ាថាយនិយាយ "ក្នុងព្រះនាមព្រះបុត្រា" និងពេត្រុសនិយាយ "ក្នុងព្រះនាមព្រះយេស៊ូវ" នរណាជាព្រះបុត្រា? ព្រះយេស៊ូវ។

211 "ក្នុងព្រះនាមព្រះវិញ្ញាណបរិសុទ្ធ" គឺម៉ាថាយ និងពេត្រុសនិយាយ "ក្នុងព្រះនាមព្រះគ្រីស្ទ" ជាឡូហ្គូស(Logos)។

212 *ព្រះវរបិតា ព្រះបុត្រា ព្រះវិញ្ញាណបរិសុទ្ធ* "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ" ហេតុអ្វីនោះជាល្អណាស់មើលទៅ។ ឃើញ?

213 បង ស៊ីម(Scism)និយាយមកកាន់ខ្ញុំឬក៏ប្អូនប្រុសស៊ីម(Scism) បងប្អូនមកពីខាងវ៉នណេស គាត់និយាយ បងប្រុសប្រាណហាំ នោះត្រឹមត្រូវហើយ ប៉ុន្តែ" គាត់និយាយ "នោះគឺបែប*នេះ*។"

214 ខ្ញុំនិយាយ "ដូច្នេះនេះគឺបែប*នោះ*" នោះគឺ ត្រឹមត្រូវ។ ឃើញ? ខ្ញុំនិយាយ "បើសិន*នោះ*គឺបែប*នេះ នេះ*គឺបែប*នោះ* ។ ដូច្នេះបងប្អូនកំពុងរអ៊ូរទាំរឿងអ្វី?"

215 ខ្ញុំនិយាយ "សូមឲ្យខ្ញុំណែនាំដល់អ្នក បងប្អូន ថាតើខ្ញុំធ្លាប់ជ្រមុជទឹកឲ្យនរណាម្នាក់ នេះជាអ្វី..."

216 ខ្ញុំនិយាយ "ឥឡូវ ទីនេះមានបណ្ឌិតណេស" និងអ្នក...មាននរណាម្នាក់ និយាយ មួយស្រេបក់មុន អ្នកបងប្អូន ដែលអ្នកបានស្គាល់បណ្ឌិតណេស។

217 ល្អ ខ្ញុំនឹងនិយាយ ទីនេះ បងប្អូនប្រុស ហ៊ីក នៅទីនេះ ហាស់ហាហា...ខ្ញុំគិតថា លោកមានកម្រិតដុកទ័រ។ តើត្រឹមត្រូវរឺទេ? ត្រឹមត្រូវ។

218 ឥឡូវខ្ញុំនិយាយ "បើសិនដុកទ័រនេស អង្គុយនទីនេះ..."ឥឡូវខ្ញុំនិយាយ "បើសិនជាខ្ញុំចង់..."ឥឡូវ ពេលខ្ញុំយក មនុស្សទៅកាន់ទឹក ដើម្បីទឹកឲ្យពួកគេខ្ញុំដឹង ថាធ្វើដូចជាគេធ្វើ ខ្ញុំនិយាយ "នោះជាងារដែលសំដៅព្រះនាមទ្រង់"

219 ខ្ញុំនិយាយ "ឥឡូវ បងប្អូនមកពីក្រុមជំនុំព្រះប្រើងារ និងបងប្អូនខាងវ៉នណេសប្រើងាដែរ" ខ្ញុំនិយាយ "ឥឡូវខ្ញុំបង្ហាញដល់អ្នក អ្នកទាំងពីរគឺខុស ហើយខ្ញុំត្រឹមត្រូវ" អ្នកដឹងថាតើវាគួរនឹង...អ្នកមានមនុស្សនៅក្រុមវរាំងរបៀបនោះ អ្នកត្រូវមានហេតុផលបន្តិចនៃចំណូលចិត្ត ក្នុងរបៀបងារដែលមិនបក់បោក។ ដូច្នេះខ្ញុំនិយាយ "ខ្ញុំនឹងបង្ហាញអ្នកថា អ្នកទាំងពីខុស ខ្ញុំទើបត្រឹមត្រូវ។"

220 ខ្ញុំនិយាយ "ឥឡូវតើខ្ញុំចង់យកចិត្តទុកដាក់ពីបងប្អូនប្រុសនេស(Ness) ខ្ញុំចង់និយាយ..."

221 ឬ ឬបងប្អូនប្រុសហ៊ីក(Hicks)នៅទីនេះ ឃើញ។ ខ្ញុំនិយាយ "Hicks!" ឥឡូវសម្លេងនោះគឺល្អទេ? ទេ។ ល្អចុះបើខ្ញុំនិយាយ "ដុកទ័រ! ហេ ដុក! ចុះយ៉ាងណាវិញ?" ឥឡូវ សម្លេងនោះមិនមានការគោរពឡើយ មិនចឹង?

222 "ពេល"ខ្ញុំនិយាយ "នោះជារបៀបអ្នកក្រុមជំនុំព្រះជាម្ចាស់ធ្វើ ឃើញ។ ពេលអ្នកជាបងប្អូនក្រុមជំនុំព្រះជាម្ចាស់និយាយ 'ក្នុងព្រះនាមព្រះវរបិតា និងព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ' អ្នកនិយាយ 'ក្នុងព្រះនាមនៃបព្វជិត ដុកទ័រ។'"

223 ហើយខ្ញុំនិយាយ "ហើយបងប្អូនខាងវ៉ននីស ពេលគេជ្រមុជទឹក អ្នកនិយាយ 'ព្រះយេស៊ូវ!'" គេមិនប្រើទេ...

224 ពួកគេជា ព្រះយេស៊ូវតែមួយគត់ គឺប្រើព្រះនាម "ព្រះយេស៊ូវ។" មានយេស៊ូវ ច្រើន។ ប៉ុន្តែ វាជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ អ្នកឃើញ។ មាន...ការជ្រមុជទឹកក្នុងព្រះនាម "ព្រះយេស៊ូវ" ខ្ញុំនឹងមិនទៅឆ្ងាយពីនោះឡើយ មិនមានបទគម្ពីរ។ អ្នកមានភាពដើម មើលថាតើអ្នកមិនជា "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ" ពិត

ណាស់ ទ្រង់ជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ មានឈ្មោះយេស៊ូវជាច្រើន ពិតមែន។ និង*ព្រះគ្រីស្ទ*ទទួល "ប្រេងតាំង។"

225 ខ្ញុំនិយាយ "ឥឡូវបើសិនជាខ្ញុំនិយាយអ្វី ដែលដូចគ្នានឹងបងប្អូនប្រុសនេស។ ខ្ញុំនឹងនិយាយ តើវាស្ដាប់ទៅដូចជាត្រឹមត្រូវសម្រាប់ខ្ញុំនិយាយ 'ហេ នេស!'?" ខ្ញុំនិយាយ "នោះមានរបៀបដែលក្រុមវ៉ននីស និយាយវា។ ឃើញ? តើនោះមិនហៅថាសំដៅបព្វជិតមិនសំដៅមនុស្សដែលជាអ្នកសិក្សានិងគាត់ទទួលកម្រិតដុកទ័រទេរឺ? បើសិនជាអ្នកសិក្សាស្វែងយល់ពីនោះ គាត់នឹងត្រូវមានងារជាបែបនោះ។"

226 ហើយខ្ញុំនិយាយ "ដូច្នេះបើខ្ញុំនិយាយ 'ហេ ដុក!'" ខ្ញុំនិយាយ "តើស្ដាប់ទៅដូចជាភ្លាវទេព្រោះអ្នកដឹកនាំត្រូវបញ្ជាក់ម្នាក់ទៀត?" ឬខ្ញុំនិយាយ "មានរបៀបដែលអ្នកធ្វើ គ្រាន់តែតាមងារ។"

227 ប៉ុន្តែខ្ញុំនិយាយ "ពេលខ្ញុំយកមនុស្សទៅកាន់ទឹក ខ្ញុំដើរទៅទីនោះនិងសួរគាត់និងនិយាយ និងយកឈ្មោះគាត់និងមិនថានរណាក៏ដោយ និងជំនឿរបស់គាត់។

228 "រួចខ្ញុំអធិស្ឋាន និងនិយាយ 'ឥឡូវ ព្រះបិតា ទ្រង់ជាអ្នកប្រទានបេសកកម្មដល់ទូលបង្គំឲ្យ "ចេញទៅចុងបំផុតផែនដីដើម្បីបង្កើតសិស្សគ្រប់អស់ទាំងសាសន៍..."'អ្នកជាបងប្អូនស្គាល់ហើយឃ្លាដើមមើល។ ""...បង្កើតសិស្ស គ្រប់សាសន៍ជ្រមុជ ពួកគេដោយនូវព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណបរុសុទ្ធបង្រៀនពួកគេឲ្យស្វែងយល់អ្វីក៏ដោយដែលទ្រង់មាន...សេចក្ដីទាំងអស់ដែលទ្រង់បង្រៀនទូលបង្គំរាល់គ្នា។""

229 "ដូច្នេះបន្ទាប់មកខ្ញុំនិយាយ 'ដោយសារការ ប្រកាសដោយជំនឿ ដោយការប្រកាសរបស់អ្នកនៃបាបរបស់អ្នក និងជំនឿរបស់អ្នក ក្នុងព្រះបុត្រារបស់ព្រះខ្ញុំជ្រមុជទឹកឲ្យអ្នក ជាបងប្អូនជាទីស្រឡាញ់ ក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ'។"

230 ខ្ញុំនិយាយ "នោះជារបៀបដែលខ្ញុំជ្រមុជទឹក។ ខ្ញុំមានទាំងការស្គាល់ងាររបស់ទ្រង់ អ្វីដែលទ្រង់យ៉ាងណា ទាំងព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ និង ហេតុផលព្រះយេស៊ូវមានបន្ទូលគឺ..."

231 ឥឡូវមើល បើ—បើមិនដូច្នេះ អ្នកនឹងបញ្ជ្រាសខគម្ពីរហើយ អ្នកនឹងមាន ភាពបញ្ជ្រាស់។ តើអ្នកនឹងធ្វើអ្វីពេល...អ្វីដែល បងប្អូនប្រុសតូចអ្នកពុទ្ធសាសនានេះនឹងងើបឡើង ហើយនិយាយថា "ចុះ*នេះវិញ*ជាយ៉ាងណា?" អ្វីដែលពួកគេនិយាយ ពេលគេប្រាប់ខ្ញុំ...

232 នោះទីនោះមានបងប្អូនប្រុសជនជាតិឥណ្ឌា(Indian) ប្រជែងជាមួយម៉ារីសរីហ៊ែដ(Morris Reidhead) និងនិយាយទៅកាន់គាត់ និយាយ "ចុះយ៉ាងណាវិញម៉ាកុស16?" គាត់ត្រូវដកថយចំពោះវា។

233 អ្នកមិនដកថយអ្វីឡើយ។ នោះជាព្រះបន្ទូលរបស់ព្រះ។ នៅជាមួយវា។ ត្រឹមតែអធិស្ឋាន។ ទទួលការបើកសម្តែង។ វាទាំងអស់មានដំណើរដូចគ្នា។

234 ឃើញ ពួកគេទាំងនិយាយអ្វីឥឡូវ មិនមែនងា មិនភ្លាវ។ ខ្ញុំនិយាយ "ឥឡូវ..."

235 ខ្ញុំស្គាល់ទ្រង់។ ទ្រង់ជាព្រះវរបិតា មិនមែនជាព្រះមួយទៀតឡើយ។ ទ្រង់ជាព្រះបុត្រា មិនមែនជាព្រះមួយទៀតឡើយ។ ជាព្រះដដែល! អ្នក...មានបីមុខងារ។ ព្រះជាព្រះបិតាបានបែងចែក បើសិនជាអ្នកចង់ហៅ ភាពជាបិតា ភាពជាបុត្រា និងភាពជាព្រះវិញ្ញាណ គឺព្រះដដែលនៅក្នុងយើងឥឡូវ។ "ខ្ញុំនឹងនៅជាមួយអ្នក" ភាពជា "ខ្ញុំ"ជាសព្វនាមបុគ្គល "ខ្ញុំនឹងនៅជាមួយអ្នក" ដូច្នេះ អ្នកឃើញ វាមានកិច្ចការបី មិនមែនព្រះបីឡើយ។

ឥឡូវ បងប្អូន បើសិនពួកសាវកមិនបានប្រើ និងតរៀងមក...

236 ខ្ញុំមិននិយាយអ្វីទាស់នឹងវាឡើយ។ នោះគឺត្រឹមត្រូវហើយ។ ខ្ញុំប្រាប់អ្នក បើសិនជាមនុស្សចេញមកទីនេះ និងជ្រមុជទឹកដោយឈ្មោះ "ផ្កាកុលាបដែលដុះនៅវាលសារ៉ុនជាផ្កាកំភ្លឹងដែលដុះនៅច្រកភ្នំនិងជាផ្កាយព្រឹក" និងជឿថាព្រះយេស៊ូវជាព្រះសង្គ្រោះ ខ្ញុំនិយាយ "សូមព្រះប្រទានពរអ្នក បងប្អូន! ល្អហើយ យើងអាចបន្ត!" ឃើញ? នោះគឺត្រឹមត្រូវ។ ព្រោះបើចិត្តអ្នកមិនត្រឹមត្រូវ អ្នកក៏មិនត្រឹមត្រូវដែរ របៀបណាក្តី។ ពិតណាស់។ ហើយរបស់អ្នក—ចិត្តរបស់អ្នកត្រូវតែត្រឹមត្រូវ។

237 ហើយខ្ញុំនិយាយ "ឥឡូវមើលឥឡូវបើ ខ្ញុំស្វាគមន៍បងប្អូនល្អនេស(Ness)នៅត្រង់នេះ ខ្ញុំនិយាយ 'បូជាចារ្យបណ្ឌិតណេស' នោះគឺពិតណាស់។ គាត់ជាអ្នកដឹកនាំ។ គាត់សមនឹងទទួលការឲ្យតម្លៃជាបព្វជិត។ គាត់មានការ

សិក្សា និងសិក្សាច្រើន គាត់មានកម្រិតដុកទ័រ ដូច្នេះគាត់សមនឹងទទួលការហៅជា 'បណ្ឌិត' នោះជាងាររបស់គាត់ ឃើញ។ ហើយឈ្មោះរបស់គាត់គឺ 'នេស'ក៏ដោយ។ ឥឡូវខ្ញុំចង់និយាយថា 'ហេ Ness! ហេ ដុក!' ទេនោះមិនត្រឹមត្រូវទេ។ ខ្ញុំនិយាយ 'លោកគ្រូ Dr. Ness។'

238 "ឃើញ នោះជាអ្វីដែលខ្ញុំបានហៅឃើញអ្វីជាទ្រង់ទាំងជាព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ 'ជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ'។" ឃើញ?

239 និងខ្ញុំនិយាយ "បើខ្ញុំជ្រមុជទឹកក្នុងអ្នកទាំងអស់គ្នាជាក្រុមជំនុំផ្សេងៗ នោះជារបៀបខ្ញុំជ្រមុជទឹកដល់គេ" ខ្ញុំនិយាយ "តើអ្នកទទួលគាត់ឬទេបងប្អូនប្រុសNess?"

240 គាត់និយាយ "ពិតណាស់គាត់បានជ្រមុជទឹកក្នុងព្រះនាមព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។"

ខ្ញុំនិយាយ "តើអ្នកទទួលគាត់ទេ បងប្អូនប្រុសស៊ីម(Scism)?"

គាត់និយាយ "ពិតណាស់ គាត់ជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវ"

241 ខ្ញុំនិយាយ "ដូច្នេះអ្វីជាបញ្ហារបស់អ្នក បងប្អូនប្រុស? ហេតុអ្វីបានជាអ្នកមិនទទួលនិងបំបែកជញ្ជាំងនេះដែលមនុស្សគួរឲ្យអាណិតយ៉ាងណា...? ជាវ៉ែននីស ចង់ពិតណាស់សន្និបាតអង្គប្រជុំចង់ថ្វាយបង្គំជាមួយវ៉ែននីស និងបងប្អូនក៏តាមរបៀបនោះ។ ពួកគេជាផ្លូវ។ ប៉ុន្តែកាលបើអារក្សអាចធ្វើឲ្យពួកគេឈ្លោះគ្នា..."

242 ឥឡូវអ្នកឃើញថាខ្ញុំមានន័យយ៉ាងណា បងប្អូន? ខ្ញុំនាំឆ្ពោះទៅរឿងមួយ ព្រះយេស៊ូវគ្រីស្ទ និងការរួបរួមនៃរាងកាយព្រះគ្រីស្ទ។ នោះជាគោលបំណង។ [ក្រុមជំនុំនិយាយ "អាម៉ែន—Ed។]

243 ឥឡូវ ខ្ញុំមិននិយាយអ្វីពី "ហេ អ្នកមិនជ្រមុជដោយព្រះនាមព្រះយេស៊ូវអ្នកនឹងទៅស្ថាននរក" ឥឡូវបែបនោះគឺមិនមានហេតុផលឡើយ។

244 ខ្ញុំនឹងប្រាប់អ្នកអ្វីដែលកើត ឡើងនៅថ្ងៃផ្សេងទៀត។ ខ្ញុំចុះទៅតិចសាស។ "ដោយចាកចេញមុន...និង—បងប្អូនប្រុស នៅទីនេះជាទីបន្ទាល់។ ក្រុមជំនុំOneness មានព្រះវិហារចិតសិបពីរ ឧបត្ថម្ភការប្រជុំគ្នារបស់ខ្ញុំ។ ហើយខ្ញុំដាក់បង ប្អូនប្រុសPetty ជាអ្នកមកពីក្រុមជំនុំព្រះជាម្ចាស់ឡើងមកលើវេទិកានៅយប់នោះ។ ឥឡូវអ្នកដឹងហើយថាពិត។ គាត់ជាបងប្អូនវិសេសណាស់ បងប្អូន

ប្រុស ព្រីធី(Petty) មិនដឹងជានរណាម្នាក់ នៃអ្នករាល់គ្នាស្គាល់គាត់ គឺមកពីប៊ីត ម៉ោន (Beaumont) តិចសាស។ គាត់ជាម្នាក់នៃបងប្អូនល្អដែលខ្ញុំបានជួប។ ប្រពន្ធរបស់គាត់ជាអ្នកជឿ ប្រៃចិត្តពីកាតូលិក ជាស្ត្រីពិត។ លោកជាអ្នកបម្រើព្រះពិត។

245 ប្រាប់ខ្ញុំនរណាដែលល្អជាងវ៉យរីដ នៃក្រុមជំនុំអាសិមប្លីឱហ្វហ្គាឌ។ បញ្ជាក់ពីមនុស្សម្នាក់នេះ មើលត្រង់នេះ បងប្អូនប្រុសទាំងអស់នេះខ្ញុំស្គាល់ម៉្យនេះ។ បងប្អូនប្រុសមកពីក្រុមជំនុំភីឡាដែលភាទីនេះ និងជាមនុស្សមកពីក្រុមជំនុំព្រះជាម្ចាស់ និងនរណាជាមនុស្សល្អជាង? ប្រាប់ខ្ញុំមកថាតើនរណាល្អជាង ដេកម័រ? ប្រាប់ខ្ញុំមក។ គាត់ត្រូវបានគេហៅ...គេជាកម្មសិទ្ធិគាត់។ គាត់ជាអ្នកសំខាន់។ អ្នកនឹងរកឃើញមនុស្សសំខាន់នៅទាំងសងខាង និងនោះជាចំណុចមនុស្សបង្ហាញ និងនោះក៏ជាចំណុចអារក្សចង្អុលទៅដែរ។

246 ប៉ុន្តែពួកគាត់ជាអ្នកបម្រើព្រះ។ ព្រះប្រទានព្រះវិញ្ញាណបរិសុទ្ធ ដល់ពួកគេ។ បើសិនមិនមាន ព្រះគុណរបស់ព្រះ យើងនឹងចប់ហើយ ជាមួយនឹងពាក្យរអ៊ូរទាំរបស់យើងនិងអ្វីៗនោះ។ នោះជាការពិត។ ប៉ុន្តែព្រះគុណរបស់ព្រះបានចងយើងភ្ជាប់គ្នា។ មិនគួរឲ្យឆ្ងល់ទេ យើងអាចច្រៀង "មានពរហើយចំណងដែលចង់ចិត្តរបស់យើង ដោយក្តីស្រឡាញ់ គ្រីស្ទបរិស័ទ" នោះជាអ្វីដែល យើងត្រូវការដូច្នេះ។

247 និងដូច្នេះអ្នកដឹងអ្វី? ជាវត្តមានទូទៅដ៏ធំលើ—ក្រុមជំនុំ ហៅខ្ញុំនិងនិយាយ "តើអ្នកដឹងថាអ្នកធ្វើអ្វីយប់មុន?" យប់ទីពីររបស់ខ្ញុំទីនោះ។

ខ្ញុំនិយាយ "អស្ចារ្យ?" ខ្ញុំនិយាយ "មានការប្រជុំគ្នាយ៉ាងអស្ចារ្យ"

និយាយ "អ្នកមានមនុស្សដែលនៅលើវេទិកានោះជាមនុស្សបាប"

ខ្ញុំនិយាយ "ខ្ញុំមិនដឹងទេ" កន្លែងណាដែល...

និយាយ "គឺលោកព្រីធី (Petty)"

248 "អូ" ខ្ញុំនិយាយ "បាប? អ្វី?" ខ្ញុំនិយាយ "គាត់ជាអ្នកអធិប្បាយមកពីក្រុមជំនុំព្រះជាម្ចាស់ណា បងប្អូនប្រុស។"

249 គាត់និយាយ "បាទ ប៉ុន្តែគាត់នៅមានបាប ព្រោះគាត់បានជ្រមុជទឹកមិនត្រឹមត្រូវ។"

250 និងខ្ញុំនិយាយ "បងប្អូនប្រុស អធិស្ឋាន ប្រាប់ខ្ញុំមកហេតុអ្វី" ខ្ញុំនិយាយ "គាត់មានព្រះវិញ្ញាណបរិសុទ្ធមែនទេ។"

251 គាត់និយាយ "បងប្អូនប្រុសប្រានហាំ តើលោកពេត្រុសនិយាយថាដូចម្តេច? 'ចូរប្រែចិត្តនិងជ្រមុជក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទដើម្បីលាងបាបរបស់អ្នក' ដូច្នេះបាបរបស់អ្នកមិនអាចលាងជ្រះទេទាល់តែអ្នកជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវ"

ខ្ញុំនិយាយ "នោះជារូបមន្ត បងប្អូនប្រុស?"

គាត់និយាយ "នោះជារូបមន្ត។"

252 គាត់និយាយ "ព្រះមិនសព្វព្រះទ័យ នៅក្នុងកិច្ចការ10:49 ត្បិត 'កាលពេត្រុសកំពុងតែអធិប្បាយនៅឡើយ នោះព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមក សណ្ឋិតលើអស់អ្នកដែលកំពុងតែស្តាប់ព្រះបន្ទូល' មើលនិងពួកគេមិនបានជ្រមុជទឹកផង។ ដូច្នេះព្រះបានប្រទានព្រះវិញ្ញាណ បរិសុទ្ធដល់អ្នកដែលមិនបានប្រែចិត្ត?" ខ្ញុំនិយាយ "តើអ្នកកំពុងតែឈរនៅពិភពអ្វីនាពេលនេះ?"

253 គាត់និយាយ "អ្នកដឹងទេថាតើយើងនឹងធ្វើអ្វី?" និយាយ "យើងគូសរង្វង់បន្តិច និងគូសសិទ្ធិរបស់ខ្លួនខាងក្រៅរង្វង់របស់យើង"

254 "បន្ទាប់មក" ខ្ញុំនិយាយ"ខ្ញុំនឹងគូសរង្វង់មួយទៀត និងក្តោបយកអ្នកមកវិញ។" ខ្ញុំនិយាយ "អ្នកមិនអាចគូសយកខ្ញុំចេញទេ ព្រោះខ្ញុំស្រឡាញ់អ្នក។ មើលអ្នកមិនអាចធ្វើវាបានឡើយ។" ខ្ញុំនិយាយ "មានបងប្អូនរបស់—របស់អ្នកច្រើនណាស់ ដែលស្រឡាញ់ខ្ញុំនិងជឿដល់ខ្ញុំ។" ខ្ញុំនិយាយ "អ្នក ខ្ញុំនឹង—ខ្ញុំនឹង... យ៉ាងណាក៏ដោយពួកគេនឹងមក" ខ្ញុំនិយាយ "គេនឹងមកនិង អ្នកមិនអាចគូសផាត់ខ្ញុំចោលឡើយ។ បើអ្នកគូសខ្ញុំចេញ ខ្ញុំនឹងគូសអ្នកចូលវិញ" ខ្ញុំនិយាយ "ពេលអ្នកគូសរង្វង់ ព្រះដោយព្រះគុណទ្រង់ អនុញ្ញាតិឲ្យខ្ញុំគូសរង្វង់ មួយទៀតនិងទាញអ្នកចូលវិញ" នោះគឺត្រឹមត្រូវ គូសពួកគេឲ្យចូលវិញ។

255 ហើយ បងប្អូនប្រុស អូ ក្នុងព្រះនាមព្រះយេស៊ូវ តើខ្ញុំអាចនិយាយបែបនេះបានរឺទេ។ ខ្ញុំ—ខ្ញុំ...ខ្ញុំដឹងខ្ញុំជាប់ក្នុងពេលវេលានេះ ហើយវាជិតអស់ពេលហើយសម្រាប់បញ្ចប់ ខ្ញុំទាយ ប៉ុន្តែចូរឲ្យខ្ញុំនិយាយបែបនេះ មើល។

256 ហើយខ្ញុំនិយាយទៅបុរសម្នាក់នោះ ខ្ញុំនិយាយ "ខ្ញុំនឹងទៅជាមួយអ្នកដូចអ្នកអធិប្បាយតាមខគម្ពីរ និងមានសេចក្តីស្រឡាញ់ និងជឿថា—ថា...និងអធិប្បាយ

និងនិយាយថាអ្នកនឹងជ្រមុជទឹកមនុស្ស...មិនមែនក្នុងព្រះនាមនៃ 'ព្រះយេស៊ូវ' តាមពួកព្រះយេស៊ូវតែមួយគត់នោះទេ។ ទេលោក ខ្ញុំ—ខ្ញុំប្រាកដជាមិនធ្វើបែបនោះឡើយព្រោះខ្ញុំទាកទងជាមួយយេស៊ូមួយចំនួនពួកគេនៅអាហ្វ្រិក និងកន្លែងស្គាល់ផ្សេងៗគ្នាអ្នកដែលមានឈ្មោះថាយេស៊ូវ។ ប៉ុន្តែបើសិនជាអ្នកប្រើផ្នែកនៃ 'ព្រះអម្ចាស់យេស៊ូវគ្រីស្ទ' របស់យើងខ្ញុំនឹងបន្តជាមួយអ្នក។ នោះគឺត្រឹមត្រូវហើយ។ ខ្ញុំនឹងជាប់នៅខាងអ្នក។ ខ្ញុំគិតអ្នកគួរដាក់ 'ព្រះវរបិតា ព្រះបុត្រា ព្រះវិញ្ញាណបរិសុទ្ធ' ជាដំបូងឃើញ ដើម្បីឲ្យអ្វីៗបានត្រឹមត្រូវ" ខ្ញុំនិយាយ "ខ្ញុំគិតថាអ្នកគួរធ្វើ។"

ប៉ុន្តែ គាត់និយាយ "អូ ទេ ទេ! នោះត្រឡប់ទៅរកភាពត្រីឯកវិញហើយ។"

ខ្ញុំនិយាយ "វាមិនមែនជាត្រីឯកឡើយ វាជាព្រះនៅក្នុងកិច្ចការរបស់ទ្រង់។"

257 វាមិនមែនជាភាពត្រីឯកព្រះបីទេ។ យើងមិនមានព្រះបី នោះទេពិតជាមិនអាច។ មិនមានអ្វីបែបនោះទេ។ គឺមិនមានបង្រៀនក្នុងព្រះគម្ពីរឡើយ។ និងគឺមានព្រះតែមួយ។ "ចូរស្តាប់ ឱ អ៊ីស្រាអែលអើយ យើងជាព្រះអម្ចាស់ ជាព្រះ" ព្រះតែមួយ! បញ្ញត្តិទីមួយ "កុំឲ្យមានព្រះណាក្រៅពីយើងឡើយ" ពិតណាស់ ទ្រង់ជាព្រះតែមួយគត់ មិនមែនបី។

258 នោះគឺជំនាន់កាតូលិក គឺវា ចេញមកពីកាតូលិក ដល់លូធើរៀន និងបន្តមក និងបន្តមក និងវាត្រូវបានជឿមកថានៅជំ នាន់មនុស្សសព្វថ្ងៃមានព្រះបីអង្គ។

259 ហើយនោះជាកន្លែងអ្នកនឹងមិន...ដំណឹងល្អ បែបនេះនឹងមិនទៅដល់ជនជាតិយូដាឡើយ...ដែល ខ្ញុំថ្លែងទំនាយព្រឹកមួយទៀត នៃបេសកជន ជនជាតិយូដាទីនោះ។ អ្នកនឹងមិនយកព្រះត្រីឯកទៅកាន់យូដាឡើយ។ អ្នកនឹងមិនធ្វើបែបនោះឡើយ។ ដែលគាត់ មិនគាត់មានហេតុផលល្អជាងនោះ។ ឃើញគាត់ស្គាល់ច្រើន ពីព្រះគម្ពីរជាងនោះ។ ប៉ុន្តែទ្រង់មិនមែន ជាព្រះមានបី ចំពោះ—ជនជាតិយូដា ឡើយ។

260 ខ្ញុំជឿសេចក្តីទាំងអស់ នេះ។ "បងប្អូន សូមកុំខឹងខ្លួនឯងឡើយ ព្រោះជាព្រះហើយដែលធ្វើការនេះ" អ្នកឃើញ។ សម្រាប់—សម្រាប់អ្វីដែល...ដូច្នេះអាចរង់ចាំដល់ពេលនេះ នោះគឺដូច្នេះឯង ព្រោះសម័យសាសនដទៃរបស់យើងទើបតែផុត។ ឥឡូវខ្ញុំជឿថាដោយអស់ចិត្តរបស់យើង។ ដូច្នេះ អ្នកឃើញ បងប្អូនរបស់ខ្ញុំអើយ?

[ពួកជំនុំ និយាយ "អាមែន"—Ed] ខ្ញុំព្យាយាមនាំអ្វីមួយ នោះ ក្រុមមនុស្ស មនុស្ស ដែលជាអ្នកជ្រមុជទឹកឲ្យគេដោយព្រះវិញ្ញាណបរិសុទ្ធ។

261 ក្រុមអាំមីអឹមស៊ីហ្វីសាន់(Aimee McPherson) តើនាងនិយាយបែបណា? នាងជាអ្នកទីមួយនៃវ៉ននីស(Oneness) ខ្ញុំជឿ រួចហើយក៏ចេញមកនិងក្លាយជាក្រុមជំនុំព្រះជាម្ចាស់ និងទាញចេញមកជា អង្គកាផ្ទាល់ខ្លួនខុសគ្នាមួយ មិនយូប៉ុន្មានក៏មានក្រុមតូចមួយ រឿងតូចមួយ។

262 ខ្ញុំអង្គុយក្នុងការជួបជុំអូអិលចាហ្គឺ(O. L. Jaggers)។ ឥឡូវយើងទាំងអស់គ្នាស្គាល់O.L.Jaggers។ ឪពុករបស់គាត់—របស់គាត់ ជាអ្នកបង្កើត សភានៃក្រុមជំនុំព្រះជាម្ចាស់។ ឥឡូវO.L.Jaggers ជាមនុស្សអស្ចារ្យម្នាក់។ គាត់ជាគ្រូអធិប្បាយធំ។ ខ្ញុំប្រាប់គាត់មិនជាយូទេខ្ញុំនិយាយ "បងប្អូនប្រុសចាហ្គឺ(Jaggers) បើសិនជាខ្ញុំអាច អធិប្បាយដូចលោកធ្វើ ខ្ញុំនឹងមិនមានកម្មវិធីប្រោសឲ្យជាឡើយ" ប៉ុន្តែគាត់មានទាំងស្រានិងឈាម និងសម្ភារៈ មុនពេលគាត់ ចាប់ផ្តើមទាំងអស់នោះ។

263 សូមទោស ខ្ញុំធ្វើអោយអ្នកឈឺចាប់ក្នុងអារម្មណ៍ បងប្អូន លើបែបនោះ។ ខ្ញុំ—ខ្ញុំ...គឺបែបនោះ។ ព្រះជាម្ចាស់អាចធ្វើឲ្យឈាមមកស្រាក៏ចេញមក ឬប្រេងក៏មក អ្វីដែលទ្រង់ចង់ប៉ុន្តែនោះមិនបានអត់ទោសបាបនោះឡើយ។ ទេលោក។ទេលោក។ ទេពិតណាស់។ "លោហិតព្រះយេស៊ូវគ្រីស្ទនឹងមិនបាត់ព្រះចេស្តាឡើយ រហូតដល់ថ្ងៃសងនៃក្រុមជំនុំរបស់ព្រះបានសង្គ្រោះ និងមិនធ្វើបាបទៀត។"

264 ខ្ញុំនិយាយ "បងប្អូនប្រុសចាហ្គឺ(Jaggaer)"ខ្ញុំយកនិងគាត់ ខ្ញុំហៅគាត់។ ហើយពេលនោះខ្ញុំនៅជាមួយកិច្ចការក្រុមបុរសគ្រីស្ទបរិស័ទ។ ហើយ ខ្ញុំនិយាយ ខ្ញុំនិយាយ "បងប្អូនប្រុសអូអិល(O.L.)?"

265 ខ្ញុំនិយាយ "តើអ្នកនៅក្នុងភពមួយណា?" ខ្ញុំនៅក្នុងផ្ទះសំណាក់ថោកតូចមួយទីនោះ។ និងគាត់និយាយ "អ្នកមានន័យថា គេដាក់អ្នកនៅខាងក្រៅនោះ?"

266 ខ្ញុំនិយាយ "នោះជាបំណងរបស់ខ្ញុំ។ ពេលខ្ញុំចូលមកកាន់អ្នក" ខ្ញុំនិយាយ "តើអ្នកធ្វើអ្វី? អ្នកដាក់ខ្ញុំនៅទីនោះនៅក្នុងសណ្ឋាគារស្តេតឡឺ(Statler Hotel) និងខ្ញុំ គ្រាន់តែឈរនៅជ្រុងមួយ។ ពួកគេដាក់ខ្ញុំចុះ នៅលើតុ ខ្ញុំមិនដឹងថាតើគួរប្រើកាំបិតមួយណាទេឬមិនមានអ្វីទេ។ ហើយខ្ញុំមិន...ចុះទៅ តាមរយៈនោះមិនមាន

អាវធំ ពាក់ពួកគេចង់ដេញខ្ញុំចេញ" និងខ្ញុំនិយាយ "ខ្ញុំ—ខ្ញុំមិនដឹងពីរបៀបដែលដោះស្រាយខ្លួនឯង។"

និយាយ "ខ្ញុំនឹងយកអ្នកទៅទីនោះ បើសិនជាពួកគេក្រពេកដែលមិនអាចធ្វើវាបាន។"

267 ខ្ញុំនិយាយ "ទេ លោក" ខ្ញុំនិយាយ "អ្វីដែលខ្ញុំចង់ធ្វើគឺមានបរិភោគសាច់គោជាមួយអ្នក បើសិនជាអ្នកចេញលុយ។"

ហើយគាត់និយាយ "ត្រឹមត្រូវ។"

268 ដូច្នេះយងចេញទក្រៅកន្លែង និងយើងអង្គុយចុះ។ និងខ្ញុំនិយាយ "បងប្អូប្រុសចាហ្គឺ(Jaggers) ខ្ញុំសរសើរអ្នកណាស់..."

269 និងគាត់ជាមិត្តស្និទ្ធិស្នាលរបស់ខ្ញុំជាបងប្អូនវិសេសវិសាល។ និង ខ្ញុំ—ខ្ញុំ មានលិខិតខ្លីរបស់គាត់ និងគាត់...កន្លែងដែលគាត់ឲ្យស្ត្រីនោះ ពីនាយសមុទ្រមកទីនេះដែលគាត់មានឈាមក្នុងដៃនិងអ្វីៗ។ ដូច្នេះខ្ញុំមានវាតីនេះ។ ខ្ញុំចង់ឲ្យគាត់បដិសេធវាម្តង និងខ្ញុំមានវានៅលើក្រដាសរបស់—របស់គាត់ អ្នកដឹងហើយ។

270 ខ្ញុំនិយាយ "ខ្ញុំបានសម្គាល់កន្លែងដែលអ្នកនឹងធ្វើ មាន នឹងមានការផុសផុលមួយងើបឡើង" ព្រោះអ្នកជំនួញមាននៅទីនោះជាពិត។

271 មើលដូចមនុស្សបានដឹង។ បើព្រះវិញ្ញាណបរិសុទ្ធអាចបើកសម្តែងចេញមកទ្រង់មិនអាចប្រាប់ខ្ញុំពីអ្វីដែលមានក្នុងកន្លែងនោះទេរឺ បងប្អូន? [ពួកជំនុំនិយាយថា "អាមែន"—Ed។]

272 ខ្ញុំអាចប្រាប់អ្នកតាមពាក្យមួយៗ និងបង្ហាញអ្នកដោយបងប្អូនប្រុសខាល់សុន (Carlson) និងបងប្អូនប្រុសនៅ*ទីនេះ។* ខ្ញុំអង្គុយនៅកន្លែងប្រជុំគ្នា កាលពីម្សិលមិញ និងប្រាប់បងប្អូនពីអ្វីនឹងមាននៅព្រឹកនេះ។ [បងប្អូននិយាយ "មែនលោក"—Ed។] នោះគឺត្រឹមត្រូវហើយ។ ជាការពិត។ ["អាមែន"] ឃើញ? ព្រោះព្រះវិញ្ញាណបរិសុទ្ធដាស់ខ្ញុំឡើងនិងមានបន្ទូល "ឈរជិតបង្អួច" ខ្ញុំមើលបង្អួចនិងបង្ហាញខ្ញុំពិត*បែបនេះ*។ ខ្ញុំនិយាយ "ឥឡូវបងប្អូន..."[បងប្អូននិយាយ "គឺត្រូវហើយ"] ខ្ញុំបង្ហាញអ្នកការនេះ។ នោះ! ឃើញ?

ហេតុអ្វីពួកគេគួរតែដឹង។

273 ទីនេះមិនជាយូប៉ុន្មាន ទេមានមនុស្ស ទីនេះបានក្រោកឡើងនៅឆូតាហ្គូ (Chautauqua)និងនិយាយ"បងប្អូនប្រុសប្រានហាំជាព្យាការី" ខ្ញុំមិនបានប្រកាសថាជាព្យាការីឡើយ។ ឃើញ? ប៉ុន្តែគាត់និយាយ "បងប្អូនប្រុសប្រានហាំជាព្យាការី ពេលដែលគាត់ស្ថិតនៅក្នុងវិញ្ញាណដែលអាចស្ទង់វិញ្ញាណប៉ុន្តែ"និយាយ "អូគោល លទ្ធិរបស់គាត់គឺពុលហើយ។ ដូច្នេះសូមប្រយ័ត្នផង" ខ្ញុំគិតថា មនុស្សដែលមានការអប់រំម្នាក់ តើនឹងអាចនិយាយរឿងបែបនោះទេ?

274 តើព្យាការីមាន ន័យយ៉ាងដូចម្ដេច? "ជាអ្នកដែលបកស្រាយព្រះបន្ទូលព្រះ។" "ព្រះបន្ទូលរបស់ព្រះបានមកដល់ពួកព្យាការី" អ្នកឃើញ។ ប៉ុន្តែបែបនោះមិនព្រមិនទាំងនិយាយផង។

275 ប៉ុន្តែយ៉ាងណា បងប្អូនប្រុសចាហ្គឺ(Jaggers)។ និងខ្ញុំនិយាយ អូ...ខ្ញុំនិយាយ "ខ្ញុំឃើញស្រ្តីមានឈាមក្នុងដៃ"

276 "អូ" គាត់និយាយ "បងប្អូនប្រុសប្រានហាំ នោះជាហេតុការណ៍ដែលអ្នកធ្លាប់ឃើញ"

277 ខ្ញុំនិយាយ "បងប្អូនប្រុសចាហ្គឺ(Jaggers) ខ្ញុំស្រឡាញ់អ្នក។ ទីមួយខ្ញុំចង់ឲ្យអ្នកដាក់ដៃខ្ញុំក្នុងដៃអ្នក។ ចូរយើងធ្វើជាបងប្អូន។"

គាត់និយាយ "ប្រាកដណាស់។ តើនោះមានបញ្ហាអ្វី?"

278 ខ្ញុំនិយាយ"អ្នកជាអ្នកអធិប្បាយមានអំណាចម្នាក់ដែលខ្ញុំធ្លាប់ស្គាល់គឺ—គឺអ្នកពិតជាឧបករណ៍របស់ព្រះណាស់ហ្ន!"

279 ខ្ញុំនិយាយ "អរគុណ បងប្អូនប្រុសប្រានហាំ អ្នកពិតជា បន្ទាបខ្លួនណាស់។"

280 ខ្ញុំនិយាយ "ខ្ញុំមិននិយាយបែបនោះដើម្បីបន្ទាបខ្លួននោះទេខ្ញុំនិយាយបែបនោះ ព្រោះខ្ញុំជឿវា។ អ្នកជាអ្នកបម្រើរបស់ព្រះ" ប៉ុន្តែ ខ្ញុំនិយាយ "បងប្អូនប្រុសចាហ្គឺ (Jaggers) ដរាបណាទាល់តែអ្នក...អ្នក—អ្នករត់ចេញក្រៅពេកហើយ អ្នកត្រូវតែថ្លឹងថ្លែងតុល្យភាព សម្រាប់អ្វីដែលអ្នកនិយាយ។ អ្នកកំពុងតែតាំងមូលដ្ឋាន..."

281 និងមានបញ្ហាអីជាមួយបងប្អូនជាច្រើននាក់នៅក្នុងក្រុមជំនុំព្រះជាម្ចាស់ និងអ្នកផ្សេងទៀត ក្នុងកម្មវិធីប្រោសឲ្យជា។ ខ្ញុំមិនបន្ទោសអ្នកទេ។ វាហៅជ្រុលពេក... និងថមមី(Tommy) នៅទីនេះ ជាបងប្អូនដ៏ល្អ និងយើងដឹងថាគាត់ឈរមាំប៉ុណ្ណា។ ប៉ុន្តែមានអ្វីជាច្រើនក្នុងទឹកដីថ្ងៃនេះ ក្រោមឈ្មោះកាប្រោសឲ្យជាមកពីព្រះ មិន

មានអ្វីរឿងឆ្ងល់ទេអ្នកមិនចង់ឧបត្ថម្ភការប្រជុំនៅក្នុងក្រុងនេះ។ ពួកគេមកនិង បង្ហូរឈាមមនុស្ស និងចេញទី។ ហើយតើគេទទួលបានអ្វី? កុំឲ្យមនុស្សច្រើនជាង អ្នកធ្វើតាំងពីទម្រង់ការពីការបង្រៀនរបស់អ្នកផ្ទាល់។ ហើយអ្នកត្រូវមែន បងប្អូន។ ខ្ញុំកំពុងប្រាប់អ្នក អ្នកត្រឹមត្រូវហើយ។ ប៉ុន្តែវាដូចជា...

282 ខ្ញុំកំពុងអានប្រវត្តិរបស់លោក ម៉ាទីនលូធើ។ វានិយាយថា "វាមិនមែនជា អាថ៌កំបាំងទេដែលម៉ាទីនលូធើ អាចប្រឆាំងក្រុមជំនុំកាតូលិក និងចេញមក" អ្នកអានប្រវត្តិសាស្រ្ត។ "ប៉ុន្តែម៉ាទីនលូធើ នោះអាចទប់ក្បាលរបស់គាត់កុំឲ្យ ស្រើបស្រាលនិយមពីការផុសផុលដែលមកតាមក្រោយ នោះជាអាថ៌កំបាំង។"

283 ហើយព្រឹត្តការណ៍ត្រូវបានធ្វើឡើង គឺការមិនកាត់ស្បែក មានតាមក្រោយ ដូចជានៅអេស៊ីព្ទដែរ។ និងវាតែងតែបង្ករបញ្ហាចេញពីដែនដី។ យើងដឹងថា ពេល យើងចេញមក។ មួយណាដែល នាំឲ្យមានការងើបឡើងរបស់កូនចៅកូរ៉េ និងព្រះ បានបំផ្លាញពួកគេ។ ប៉ុន្តែបងប្អូន ខ្ញុំមិនបន្ទោសអ្នកឡើយ។

284 បងប្អូនប្រុសចាហ្គឺ(Jaggers) អង្គុយទីនេះនិងព្យាយាមប្រាប់ខ្ញុំថា នោះ ជាព្រះវិញ្ញាណបរិសុទ្ធដែលធ្វើការនោះ។ និងនិយាយ...និងខ្ញុំបាន ក្នុងក្រដាស ផ្ទាល់ខ្លួន...ខ្ញុំនិយាយ "បងប្អូនប្រុសចាហ្គឺ (Jaggers) ឥឡូវ" ខ្ញុំនិយាយ "ខ្ញុំជា សិស្សថ្នាក់ទីប្រាំពីរ។ និងអ្នកជា ដុកទ័រទេវសាស្រ្ត និងសិក្សាទៅជាមេធាវី។ អ្នក ត្រូវបានជំធាត់ឡើងដោយស្អាត ក្រុមជំនុំត្រឹមត្រូវ ក្រុមជំនុំព្រះជាម្ចាស់។ ឪពុក របស់អ្នកជួយអ្នកឲ្យរកបានជំនឿនោះ។ ហើយអ្នកទាញចេញ នោះអាស្រ័យនឹង អ្នក" ប៉ុន្តែខ្ញុំនិយាយ "នោះកើតមានលើមនុស្សណាក៏ដោយ ដែលចង់ធ្វើ។ ខ្ញុំមិន គូសខ្សែរខណ្ឌទៅឡើយ។ ប៉ុន្តែពេលវាមកត្រង់កន្លែងដែលឧបករណ៍ដូចជាអ្នក អាច ចាប់យកព្រលឹងវិញ្ញាណរាប់ពាន់នាក់សម្រាប់ព្រះគ្រីស្ទ នោះអ្នកសង់ពន្ធ័កិច្ចលើ ហេតុផល" ខ្ញុំនិយាយ "បងប្អូនប្រុសចាហ្គឺ(Jaggers)អ្នកសង់សសរដូចនោះបើ អ្នក មិនមានជញ្ជីងថ្លឹងសម្រាប់ការនោះវានឹងធ្លាក់ចុះបន្ទាប់ពីមួយខណៈពេល។ ហើយអ្នកត្រូវមានខគម្ពីរសម្រាប់អ្វីដែលអ្នកនិយាយ។"

គាត់និយាយ "មានខគម្ពីរ។"

ខ្ញុំនិយាយ "បង្ហើតវាមក។"

285 គាត់និយាយ "បងប្អូនប្រុសប្រានហាំ" និយាយ "នោះជាព្រះវិញ្ញាណបរិសុទ្ធដែលធ្វើវា។"

286 ខ្ញុំនិយាយ "បង្ហាញខ្ញុំនូវបទគម្ពីរកន្លែងវានិយាយ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើឲ្យឈាមចេញពីរាងកាយនរណា ម្នាក់និងបែបនោះដូចនោះ។ បង្ហាញមកប្រេងចេញពីវាមក។ អ្នកនិយាយ 'នោះជាប្រេងចេញមកពីការប្រោសឲ្យជាពីព្រះ' និង អ្នកនិយាយ 'នោះជាឈាមស្ត្រីដែលមាន សេចក្តីសង្គ្រោះដល់ជាតិសាសន៍នានា'។" ខ្ញុំនិយាយ "បើសិនជាវាដូច្នោះ នោះមានរឿងអ្វីចំពោះព្រះលោហិតព្រះយេស៊ូវគ្រីស្ទ? វាយកចេញហើយ។ និងអ្វីៗទាស់នឹងវា វាជាមេប្រឆាំង។ វាប្រឆាំងវា" ខ្ញុំនិយាយ "វាក្លាយជាគោលលទ្ធិរបស់មេប្រឆាំងនឹងព្រះគ្រីស្ទ។"

"អូ" គាត់និយាយ "បងប្អូនប្រុសប្រានហាំ អ្នកនឹងដឹងថ្ងៃណាមួយ។"

287 ខ្ញុំនិយាយ "ខ្ញុំសង្ឃឹមថាខ្ញុំមិនរៀនបែបនោះ។ ឥឡូវ បងប្អូន" ខ្ញុំនិយាយ "ខ្ញុំស្រឡាញ់អ្នក ហើយអ្នកជាបងប្អូនរបស់ខ្ញុំ" និងខ្ញុំនិយាយ "បងប្អូនប្រុសចាគីអ្នកនឹងទទួលមែកធាង បន្ទាប់មក អ្នកនឹងលែងបែរខ្នងទៀត។ ត្រឡប់មកវិញក្រុមជំនុំអ្នកនិងត្រឡប់មកវិញនិងនៅជាប់ជាមួយដំណឹងល្អ" ហើយខ្ញុំនិយាយ "កុំសង់វាលើទំនោអារម្មណ៍" ខ្ញុំនិយាយ "ជា..."

288 ឥឡូវគាត់ទទួល គាត់ទទួលការជ្រមុជទឹកជាជីវិតអស់កល្ប អ្នកដឹង "គ្រប់ពេលអ្នកជ្រមុជទឹក អ្នកត្រឡប់មកជាក្មេងប្រុសស្រីវិញ។ ឥឡូវនឹង...អ្នកនឹង(មិន) ស្លាប់។" ដូច្នេះនោះវាគាត់នៅចុងបញ្ចប់នៃមែកធាងឥឡូវនិងពួកវាជា "វីតាមីនចេញពីសមុទ្រស្លាប់។" អ្នកឃើញ? ប៉ុន្តែនោះគឺបែបនោះហើយ បងប្អូនប្រុស អ្នកចាប់ផ្ដើមទំនោរអារម្មណ៍បែបនោះ។

289 និងអ្នកជាមនុស្សនៅទីនេះ ដែលមានក្រុមជំនុំទាំងនេះ អ្នកនឹងមានអ្វីដូចជាទីក្រុងនោះ និង អ្នកដឹងអារក្សឆ្លាតវៃ និងវា—លោតទៅក្នុងអ្វីបែបនោះ។ វារអ៊ូរទាំលើវា។ និងវា—វាធ្វើឲ្យមនុស្សរបសួស និងវាបង្កការយល់ច្រឡំក្នុងក្រុមជំនុំ និងអ្វីដែលមិនដូច្នេះ។

290 ឥឡូវទីនេះមិនថាអ្នកត្រឹមត្រូវប៉ុណ្ណានោះទេ ទីនេះជាមួយក្នុងចំណោមអ្វីដែលអ្នកខកខានបងប្អូន។ ឥឡូវខ្ញុំបញ្ចប់ក្នុងការនិយាយនេះ។ មិនថាខ្ញុំត្រូវប៉ុណ្ណោះនោះទេនិងមិនថាខ្ញុំមានវិញ្ញាណប៉ុណ្ណានោះទេ ហើយខ្ញុំស្គាល់ព្រះជាម្ចាស់ព្រះគម្ពីរ

ទេបើសិនជា ខ្ញុំមិនមានវិញ្ញាណរបស់ព្រះ នៃសេចក្តីស្រឡាញ់ក្នុងចិត្តសម្រាប់មនុស្សជាតិ សាសន៍ទាំងមូលនិងទាំងអស់ ដូច្នេះខ្ញុំនឹងខុសហើយ។

291 ឥឡូវ ប៉ុលនិយាយ ក្នុងកូរិនថូស 13 " ទោះបើខ្ញុំចេះនិយាយ ជាភាសារបស់មនុស្សជាតិទាំងប៉ុន្មាន និងភាសារបស់ពួកទេវតាផង តែគ្មានសេចក្តីស្រឡាញ់ នោះខ្ញុំបានត្រឡប់ដូចជាលង្ហិន ដែលឮខ្ទរឬដូចជាឈឹងដែលឮទ្រហឹងប៉ុណ្ណោះ។ បើខ្ញុំចេះអធិប្បាយ ហើយស្គាល់អស់ទាំងសេចក្តីអាថ៌កំបាំង និងគ្រប់ទាំងចំណេះវិជ្ជា ហើយបើខ្ញុំមានគ្រប់ទាំងសេចក្តីជំនឿល្មមនឹងឲ្យភ្នំរើចេញបាន តែគ្មានសេចក្តីស្រឡាញ់ នោះខ្ញុំមិនជាអ្វីទេ ។ បើខ្ញុំចែកអស់ទាំងទ្រព្យសម្បត្តិខ្ញុំជាអាហារដល់គេ ហើយបើខ្ញុំប្រគល់រូបកាយខ្ញុំទៅឲ្យគេដុត តែគ្មានសេចក្តីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ។ ឯសេចក្តី...

292 ព្រះយេស៊ូវមានបន្ទូល "មនុស្សនឹងដឹងថាអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារតែអ្នករាល់ គ្នាមាន..." ពេលក្រុមជំនុំ ព្រះជាម្ចាស់ មានសេចក្តីស្រឡាញ់ វ៉ែននីស ហើយវ៉ែននីសមានសេចក្តីស្រឡាញ់ចំពោះក្រុមជំនុំព្រះជាម្ចាស់ "ពេលអ្នកមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក" ជាត្រូវ ឬ ខុស។ និងកាលបើមានគោលបំណងខុស ការជម្រុញខុស នោះគឺអ្នកខុសតាំងពីដើមមក។ តើនោះមិនដូច្នេះរឺ? [ពួកជំនុំ និយាយ "អាម៉ែន"—Ed។] មើល "ទោះបើខ្ញុំចេះនិយាយជាភាសារបស់ មនុស្សជាតិទាំងប៉ុន្មាន និងភាសារបស់ពួកទេវតាផង មិនចេះចែកទាន ខ្ញុំមិនជាអ្វីឡើយ" ព្រោះព្រះជាម្ចាស់មានក្តីស្រឡាញ់។ យើងដឹង។

293 និងខ្ញុំជឿ ក្នុងការនិយាយភាសាដទៃ។ ឥឡូវ មាននរណាម្នាក់និយាយ "បងប្អូនប្រុសប្រានហាំមិនជឿភស្តុតាងផ្តើមពីដំបូង" ខ្ញុំចង់បង្ហាញឲ្យច្បាស់ជាមួយអ្នកឥឡូវ។ យើងដឹង។

294 ខ្ញុំជឿថាពេលមនុស្ស ទទួលព្រះគ្រីស្ទ គាត់ទទួលចំណែកនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រោះ ព្រះយេស៊ូវមានបន្ទូល ក្នុងម៉ាថាយ—ជំពូក12 នៃខទី5 និងទីម្តេ—...ខ24។ ទ្រង់មានបន្ទូល។ ទេ ខ្ញុំជឿវានៅក្នុងយ៉ូហាន5:24។ រួចទ្រង់មានបន្ទូល "ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច" ឥឡូវ មានទម្រង់ជីវិតអស់កល្ប "ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ។"

295 ឥឡូវខ្ញុំជឿថាគ្មាននរណាម្នាក់ហៅខ្លួនឯងនោះទេ ព្រះត្រូវហៅគាត់។ និងបើសិនជាព្រះពិតជាត្រាស់ហៅគាត់...និងមានមនុស្សជាច្រើនយើងដឹង បងប្អូននោះមានកិច្ចការនិងគិតថាព្រះត្រាស់ហៅពួកគេ ប៉ុន្តែជីវិតរបស់គាត់ ឆាប់ៗ...រកឃើញ អ្នកនឹងរកឃើញ។ ប៉ុន្តែ បើសិនជាព្រះត្រាស់ហៅអ្នកហេតុអ្វី អ្នកជា អ្នកនឹងនោះទីនោះ និង អ្នកនឹងជាប់នៅឃើញ ដឹងហើយ។ និង បើ...ឥឡូវ នោះមិនមែនជាគោលលទ្ធិបាបទីស្ទឡើយ។ អ្នកដឹងហាយ ឃើញ។

296 ប៉ុន្តែខ្ញុំមិនជឿក្នុងការចាប់ដៃនិងមានសុវត្ថភាពអស់កល្បនោះឡើយនិងទាំងអស់សេចក្តីនោះ។ ខ្ញុំ—ខ្ញុំមិនជឿថាបែបនោះមិនជឿទាល់តែសោះ។ បើពួកគេចង់ជឿថា ល្អ នោះគឺត្រឹមត្រូវ។ ខ្ញុំនិយាយពួកគេជាបងប្អូនរបស់ខ្ញុំ។

297 នៅព្រឹកនោះ បើខ្ញុំនឹងសុំចម្រៀកនំភី (វាស្ទើរតែអាហារពេលល្ងាចហើយ) ខ្ញុំប្រហែលចូលចិត្តផ្លែឈើរី តែអ្នកចូលចិត្តផ្លែប៉ោម ប៉ុន្តែយើងទាំងអស់គ្នាបរិភោគនំភី។ ឃើញ ដូច្នេះ វាមិនធ្វើឲ្យ...ក៏ដូចជាយើងបរិភោគនំភី។

298 នោះជារបៀបយើងជឿ។ បើអ្នកចង់ក្លាយ ជាវ៉ននីស(Oneness) ចូរឲ្យនៅជាវ៉ននីស(Oneness) បើអ្នកជាក្រុមជំនុំព្រះជាម្ចាស់ ចូរនៅជាក្រុមជំនុំព្រះជាម្ចាស់។ បើអ្នកចង់បានអ្វីដែលអ្នកចង់ បាបទីស្ទ ព្រីប៊ីសស្ទើរៀន និងជាគ្រីស្ទបរិស័ទនៅក្នុងនោះ។ ឃើញ។

299 និង—និងស្វែងរកដោយខ្លួនអ្នកផ្ទាល់ ប៉ុន្តែកុំរអ៊ូរទាំជាមួយអ្នកផ្សេង។ ព្រោះរឿងតូចនេះ ពួកគេនឹងស៊ីគ្នា។ នោះគឺត្រឹមត្រូវហើយ។ ពួកគេនឹងស៊ីចង្វាក់គ្នា និងចូលមកត្រង់កន្លែងមួយ។

300 ហើយ—ហើយមិនថាយើងធ្វើអ្វីនោះទេ តើការអស្ចារ្យប៉ុន្មានដែលយើងអាចធ្វើឡើង តើភ្នំប៉ុន្មានដែលយើងអាចរើ ឬអ្វីក៏ដោយ ទាល់តែយើងមកកន្លែងមួយនោះគឺជាសេចក្តីស្រឡាញ់ មិនការខំធ្វើឲ្យជឿ ប៉ុន្តែយើងស្រឡាញ់គ្នាទៅវិញទៅមក។ ពេលយើងស្រឡាញ់បងប្អូនគ្រប់គ្នា មិនថាយើងជាកម្មសិទ្ធិក្នុងក្រុមជំនុំណានោះទេ យើងស្រឡាញ់គាត់ មិនត្រឹមតែក្លែងជាធ្វើ "ព្រោះយើងដឹងថាជាគំនិតសាសនា គឺវា" "យើងត្រូវធ្វើវា" ប៉ុន្តែដោយព្រោះយើងធ្វើវា យើងស្រឡាញ់គ្នាទៅវិញទៅមក ដូច្នេះ ការស៊ូទ្រាំ ត្រូវមានចំពោះគ្នាទៅវិញទៅមក។

301 ហើយខ្ញុំជឿនៅក្នុងកូឡូស3 ប្រហែល9 នៅត្រង់កន្លែង ណាមួយស្របបែប នោះ...ខ្ញុំប្រហែល ខ្ញុំ—ខ្ញុំមិន...ខ្ញុំប្រហែលខុសលើខគម្ពីរ ប៉ុន្តែវាបាននិយាយ បែបនេះ។ បន្ទាប់ពីយើងបានក្លាយជាគ្រីស្ទបរិស័ទ យើងមិនត្រូវច្រណែន។ ឃើញ? យើងមិនអាចមានជំនឿ ពេលយើងព្យាយាម ចំណាយការគោរពនិង លើកតម្កើងចំពោះគ្នាទៅវិញទៅមក។ ឃើញ យើងមិនអាចធ្វើបាន យើងមិនអាច មានជំនឿ។ យើងត្រូវលើកតម្កើងព្រះ ឃើញ លើកតម្កើងទ្រង់។ ជឿបងប្អូនរបស់ខ្ញុំ ពិតណាស់ បើស្រឡាញ់ ប៉ុន្តែគោរពនិងផ្តល់កិត្តិយសដល់ព្រះ! ដូចចំពោះ...ប៉ុន្តែ មានជំនឿនិងទំនុកចិត្តជាមួយអ្នកដទៃ។ "ហើយកុំកុហកចំពោះគ្នា" ឃើញ? "កុំ កុហកគ្នាៗ" បើសិនខ្ញុំប្រាប់អ្នករាល់គ្នាព្រឹកនេះ "ខ្ញុំស្រឡាញ់អ្នក" ខ្ញុំមានន័យពិត បែបនោះ។ បើវាមិនពិត ខ្ញុំជាមនុស្សកំពុត។ នោះពិតណាស់។

302 ឥឡូវបងប្អូន តាមខ្សែរនេះ...ឥឡូវ បងប្អូនប្រុសថមី(Tommy) ខ្ញុំសង្ឃឹមថាខ្ញុំ មិនចាប់ក្តោបត្រង់នេះខ្លាំងពេក។ ខ្ញុំ...បងប្អូនប្រុសថមមី(Tommy)មានអ្វីនិយាយ នៅក្នុងវិនាទីនេះ។ ប៉ុន្តែខ្ញុំគួរនិយាយបែបនេះ ពេលខ្ញុំមកនៅកណ្តាលអ្នក...

303 ខ្ញុំជឿបែបនេះ ខ្ញុំជឿថាព្រះជាព្រះបិតារបស់យើងគ្រប់បាំងលើស្ត្រីក្រមុំ ហៅថាម៉ារី និងបង្កើតត្រង់នេះជាកោសិកាឈាមដែលនាំព្រះយេស៊ូវគ្រីស្ទ ដែល ជាព្រះបុត្រារបស់ព្រះ ជារោងឧបោសថដែល ព្រះបើកឲ្យឃើញអង្គទ្រង់ ក្នុង សាច់ឈាម សម្តែងអង្គទ្រង់ក្នុងចំណោមយើង។ "ព្រះគង់ក្នុងព្រះគ្រីស្ទផ្សះផ្សា ផែនដីជាមួយទ្រង់វិញ" ខ្ញុំជឿថាកោសិកាឈាមបានបំបែកនៅកាល់វ៉ារី សម្រាប់ លុបបាបរបស់យើង។ និងវិញ្ញាណបានយាងចេញពី ទ្រង់ហើយមកគង់លើ ក្រុមជំនុំនាំឲ្យព្រះគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធ ព្រះគ្រីស្ទជាឡូហ្គូស(Logos)ដែលគង់ ក្នុងយើងឥឡូវ ព្រះវិញ្ញាណបរិសុទ្ធដោយការជ្រមុជទឹក។ ធ្វើឲ្យយើង...ព្រះគ្រីស្ទ បានញែកព្រះអង្គទ្រង់ប្រទានព្រះជន្មទ្រង់ផ្ទាល់ដល់យើងម្នាក់ៗ នោះយើងជាក្រុម មនុស្ស អាចមានក្រុមជំនុំនៃព្រះ។ និងមិនយូប៉ុន្មាន...

304 ខ្ញុំធ្លាប់ជិះ។ អ្នកធ្លាប់ដឹងហើយ។ ឪពុករបស់ខ្ញុំជាអ្នកជិះសេះ ជាអ្នកបាញ់ ពូកែ។ ខ្ញុំធ្លាប់ជិះ។ យើងចិញ្ចឹម—ជា...ក្នុងជ្រលងអារ៉ាប៉ាហូ(Arapaho) ឬ មានន័យថាទន្លេបញ្ហា (Troublesome River) នៅជួរភ្នំអារ៉ាប៉ាហូ (Arapaho)។ ហើដហ្វដអាសូស៊ីអេសិន (Herdford Association) ចិញ្ចឹមឲ្យស្មៅសត្វស៊ីនៅ ជ្រោះទីនោះ។ និងនៅជ្រោះមានម្ចាស់ស្មៅអាចផលិតបានចំបើងរាប់តោន អ្នក

អាចចិញ្ចឹមគោបានលើ—វាលស្មៅ នៅខាងក្រោមEstes Parkទីនោះ ហើយអ្នកអាចចិញ្ចឹមគោនៅវាល...ដីតារបស់ខ្ញុំជាអ្នកប្រមាញ់ដី ក៏នៅទីនោះដែរ។ ហើយខ្ញុំបានធ្វើជាម្ចាស់ស្មៅមួយឆ្នាំ។ ខ្ញុំមិនទាន់ទៅនៅឡើយ ទាំងពេលរដូវផ្ការីក និងស្លឹកឈើជ្រុះពេលខ្ញុំទំនេរនិងអាចទៅបាន និងកៀងប្រមូល គឺចង់នៅទីនោះព្រោះខ្ញុំចូលចិត្តជិះសេះ។ ហើយទាំងអស់-ឡើង-ចុះ...តាមវាល ជ្រលងនោះមានវាលស្មៅជាច្រើនដែលមានទីនេះ និងអាចចញ្ចឹមសត្វពាហនៈរបស់ខ្លួន។ និងនៅរដូវផ្ការីក មានពេលជាច្រើន ខ្ញុំជួយពួកគេប្រមូល សត្វចតុបាតុនិងឲ្យ ពួកវារត់ទៅទីនោះ។

305 ហើយមានរបងលេចឡើង នោះជាការបង្ហាញកុំឲ្យជ្រុលចូលទៅដីឯកជន ដែលតចុះមកពីជួរភ្នំ។ រហូតដល់...ពួកអ្នកស្រុកភ្នំឈររាប់សត្វចតុបាតពេលគេនៅក្នុងនោះ ពេលពួកវាចូលទៅ។ ហើយខ្ញុំបានអង្គុយជាយូថ្ងៃ រាប់ម៉ោង សម្លឹងមើលក្រុមលោកហ្គ្រីម (Mr.Grimes) នៅទីនោះ គាត់មានរបារពេជ្រ (Diamond Bar) យើងមានតែតួគីត្រាក់ និងពួកគេមាន—ទ្រីផូដ (Tripod) នៅពីក្រោមយើង និង ជេហ្វ្រី (Jeffrey) និងអ្វីផ្សេងទៀត។ ហើយពេលខ្ញុំដាក់ជើងចូល អ្នកភាគច្រើនបានដឹងហើយដាក់អាចសេះបញ្ចូលគ្នា និងអង្គុយទីនោះមើលពួកអ្នកស្រុកភ្នំដែលឈរទីនោះ រាប់សត្វចតុបាតរបស់គាត់។

306 ខ្ញុំសម្គាល់អ្វី គាត់មិនយកចិត្តទុកដាក់ខ្លាំងលើស្លាកសញ្ញាលើសត្វទេ។ ប៉ុន្តែមានរឿងមួយដែលគាត់មើល គឺជាស្លាកឈាម។ វាត្រូវតែជាពូជសុទ្ធហ្វដ(Ford) បើមិនដូច្នេះទេវាមិនអាចចូលរបងនោះបានឡើយ ប៉ុន្តែស្លាកសញ្ញាមិនមានអ្វីខុសគ្នាប៉ុន្មាននោះទេ។

307 និងខ្ញុំគិតថារបៀបដែលវាត្រូវទទួលការជំនុំជម្រះ។ មិនបាច់មើលស្លាកសញ្ញារបស់យើងឡើយ ប៉ុន្តែទ្រង់នឹងមើលស្លាកឈាម។

308 ខ្ញុំបានធ្វើកំហុសបងប្អូន និងធ្វើអ្វីជាច្រើនដែលខុស។ និងទោះមានអ្វីនៅតាមផ្លូវខ្ញុំបាននាំមកឬអ្នកបាន ឮអ្វីដែលខ្ញុំបានសម្គាល់ ឬនិយាយនោះបានផ្តល់ភាពអាម៉ាសនៃប្រភេទ ឬបើខ្ញុំនិយាយអ្វីនៅព្រឹកនេះដែលផ្ដល់ភាពអាម៉ាស ខ្ញុំសួរអ្នក ឬថាបើបងប្អូនប្រុសឬស្រីមកពីក្រុមជំនុំគ្រីស្ទបរិស័ទ អត់ទោសឲ្យខ្ញុំផង។ ខ្ញុំ

មិនមានបំណងធ្វើវាឡើយ។ ខ្ញុំត្រឹមតែចាក់ដួងចិត្តរបស់ខ្ញុំចេញ ដូច្នេះនោះយើងមិនដឹងឡើយ។

309 បើសិនមានការជ្រមុជទឹកមួយត្រូវបានធ្វើឡើង អ្នកជាបងប្អូនបានធ្វើវាដោយខ្លួនឯង ឃើញ។ នោះគឺ ខ្ញុំ—ខ្ញុំមិនធ្វើ។ បើខ្ញុំមាន នោះជារបៀបដែលខ្ញុំជ្រមុជទឹក មនុស្សម្នាក់បែបនោះ។ និងបើសិនជាបងប្អូនណាម្នាក់នៃចំណោមអ្នករាល់គ្នាអាចទទួលយកវា ឃើញ។ ដូច្នេះ អ្នកអាចយកមនុស្សនោះបាន ពួកគេអាចជ្រមុជទឹកក្នុងព្រះនាមព្រះវបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ និងពួកគេអាចជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់ យេស៊ូវគ្រីស្ទផងដែរ។ ដូច្នេះបើខ្ញុំជ្រមុជ ទឹកនរណាម្នាក់...ប៉ុន្តែខ្ញុំមិនបានធ្វើវានៅឡើយ។ គឺខ្ញុំជ្រមុជទឹកតាមតែរបៀបក្រុមជំនុំរបស់ខ្ញុំផ្ទាល់ និងនោះជាមនុស្សត្រង់នោះ។ នោះជារបៀបមនុស្ស នៅក្រុមជំនុំជ្រមុជទឹក។ ហើយបើសិនជាអ្នកមើលត្រឡប់ មកវិញនោះជាការអនុវត្តបេសកកម្មចាស់ ការអនុវត្តបេសកកម្មបាបទីស្ទ។ និង ឥឡូវបើ...នោះគឺបែបនោះ។

310 ខ្ញុំជឿការប្រោសឲ្យជាមកពីព្រះ។ ខ្ញុំជឿនៅក្នុងការជ្រមុជដោយព្រះវិញ្ញាណ។ ខ្ញុំជឿក្នុង—ព្រះវិញ្ញាណបរិសុទ្ធដែលនិយាយភាសាន់ទៃ។ ខ្ញុំជឿក្នុងរាល់អំណោយទានដែលព្រះប្រទានមកក្នុងក្រុមជំនុំ។ ខ្ញុំជាអ្នកសម្រាប់ពួកគេ មួយរយភាគរយ។ ប៉ុន្តែខ្ញុំជឿ...

311 ខ្ញុំមិននៅក្នុងនេះសម្រាប់មនុស្សងាយ បោកនៃការប្រោសឲ្យ ជានោះឡើយគឺអ្វីដែលយើង មានសព្វថ្ងៃនេះ។ ខ្ញុំចង់ធ្វើ ទីសម្គាល់នៅទីនេះ។ មានពេលមួយកន្លងទៅមានបងប្អូន...និងនោះ តើមិនមែនជាបងប្អូនថមីហ៊ីក (Tommy Hicks) ដែលវិសេសវិសាលរបស់ខ្ញុំទេឬ ទេឬដែលខ្ញុំចាត់ទុកថាគាត់ជាអ្នកបម្រើពិតរបស់ព្រះគ្រីស្ទ។ មានមនុស្សម្នាក់ទៀត នៅក្នុងប្រទេសមួយទៀត និងប្រទេសនេះមាន...គាត់ត្រឹមតែគ្រប់ពេល "អ្នកប្រោសឲ្យជាងាយបោករបស់ព្រះ! អ្នកប្រោសឲ្យជាងាយបោករបស់ព្រះ" អ្នកដឹង ដូចនោះ។

312 និងខ្ញុំទទួលបានសំបុត្របន្ទាប់ពីនោះមាន...ពីក្រុមជំនុំលូធើរៀន។ និងជំនួយការរបស់ខ្ញុំនៅទីនេះ ដឹងយើងមានក្នុងឯកសារ។ ខ្ញុំមិនហៅឈ្មោះមនុស្សនោះឡើយ ព្រោះវាមិនដូចជា—ព្រះគ្រីស្ទ ។ ទោះបីយ៉ាងណា ខ្ញុំមិនយល់ស្របជាមួយគំនិតរបស់មនុស្សប៉ុន្តែនោះគឺល្អណាស់។ ខ្ញុំស្រឡាញ់គាត់។ គាត់ជាបងប្អូនរបស់ខ្ញុំ។

313 ប៉ុន្តែវាមានកន្លែងដែល ពួកគេមានប្រភេទអារម្មណ៍ ឬរីកចូលគ្នា ឬអ្វីមួយស្រដៀងនោះ ឃើញ។ និង នោះគឺមិនល្អទេ ឃើញ។ បងប្អូនប្រុស..."កិច្ចការរបស់សាច់ឈាមធ្វើបានតិចតួច។"

314 និងដូច្នេះ នេះជាអ្នកដឹកនាំលូធើរៀន សរសេរឲ្យអ្នកដឹកនាំមួយទៀតជា—ជា—ជាសំបុត្រមួយ។ និងគាត់និយាយ "អ្នកជាអ្នកផ្សាយដំណឹងល្អអាមេរិកដែលបានចូលមកទីនេះ" និយាយ "ជាមួយការប្រោសឲ្យជាងាយបោកប្រាស់របស់អ្នកទៅកាន់មនុស្សគ្រប់គ្នា!"

315 និងសម្លេងនេះប្រៀបដូចជាបាច់ក្នុងសម្រាប់ខ្ញុំខ្លួនឯង ប៉ុន្តែព្រះជ្រាបខ្ញុំដឹងថាមានន័យរបៀបនោះ។ "ប៉ុន្តែ" គាត់និយាយ "ពេល—ពេលក្មេងតូចដេបូរ៉ាស្ទែនគ្លីវ (Deborah Stadsklev) បានស្លាប់ ក្មេងតូចនោះនិងម្តាយបានឈរជំហរបែបនោះនៅសម័យនោះ ក្នុងប្រទេសឥណ្ឌា—...ក្នុងកាលីហ្វ័រញ៉ា ជាកន្លែងដែលក្មេងតូចស្លាប់និងវាសោកស្តាយ។ និងឃើញ...ដាក់ក្មេងក្នុងដៃ បងប្អូនប្រុសប្រានហាំ និងគាត់ឈរនៅត្រង់នោះនិងអធិស្ឋាន។ ហើយក្មេងតូចចាប់ផ្តើមស្រែកនិងក្រដាស ហើយក៏ហុចឲ្យនាងវិញ។"

316 គាត់ដឹងដែរពីករណី យើងបាននិយាយម៉ិចស៊ីកូ។ ដែលយើងអាចចាក់ឫសដំណឹងល្អនៃកិច្ចការ បុរសនេះជាសេចក្តីថ្លែងការណ៍មួយ។ អ្នកអាចមានអ្វីដែលយើងបាននិយាយពីដុកទ័រ។ ពេលដែលទារកតូចជាតិម៉ិកស៊ីកូបានស្លាប់នៅព្រឹកនោះ ម៉ោងប្រាំបួន និងពម៉ោងេលនេះដប់មួយយប់នោះទីនោះ។ ដុកទ័រសរសេរសេចក្តីថ្លែងរបស់គាត់មក។ បងប្អូនប្រុសអេពីណូសាEspinoza ដែលអ្នកជាច្រើនជាបងប្អូន ក្រុមជំនុំព្រះជាម្ចាស់ដឹង គាត់ជាម្នាក់ដែលបានទទួលសេចក្តីថ្លែងនោះពីដុកទ័រថាគាត់ស្លាប់។

317 ហើយខ្ញុំឃើញនិមិត្តពីហ្វូងមនុស្ស ពេលដែលអ្នកជាខាងកាតូលិកពីរម៉ឺននាក់បានទទួលព្រះគ្រីស្ទ ក្នុងក្រុងម៉ិកស៊ីកូ។ ខ្ញុំនិយាយ "តើអ្នកមិនទទួលសេចក្តីនោះទេឬ។ ខ្ញុំមិនដឹង ថាក្មេង...ខ្ញុំទើបតែឃើញនិមិត្តនៅទីនេះ"

318 ហើយប៊ីលី(Billy)នៅទីនោះ ព្យាយាម ជាមួយអ្នកទទូលភ្ញៀវសាមទៅសែសិបនាក់ មិនអាចយកស្ត្រីម្នាក់នោះចេញពីជួរអធិស្ឋាន ជាមួយនឹងក្មេងម្នាក់។ គាត់អាចរត់ដោយប្រើជើងបាន និងគ្រប់យ៉ាង។ ដូច្នេះ ទីបំផុត ខ្ញុំបញ្ជូនជេកម័រ(Jack Moore) ចុះទៅ។ និយាយ "ទៅ អធិស្ឋានចុះ។"

319 ខ្ញុំមើលនៅទីនេះ និងខ្ញុំឃើញទារកតូចជនជាតិម៉ិកស៊ិកូញញឹម។ ខ្ញុំនិយាយ "រងចាំបន្តិច។ នាំមកទីនេះ" ឃើញ? និង ពេលខ្ញុំដាក់ដៃលើភួយនោះ...មានការចាក់ភ្លៀង ពេញមួយថ្ងៃ។ និងពួកគេឈរនៅទីនេះតាំងពីព្រលឹមស្រាងៗ និងនេះប្រហែលជាម៉ោងដប់មួយយប់នាយប់នោះ។ និងខ្ញុំដាក់ដៃលើទារកតូច។ វាក៏ចាប់ផ្តើមមានក្អកនិងឮសម្លេងញ៉េក។ ហើយពួកគេចាប់ផ្តើមស្រែក។

320 ដូច្នេះពួកគេយកចុះមកនិងធ្វើសេចក្តីថ្លែងប្រាប់។ ទៅជួបដុកទ័រ និងដុកទ័រនិយាយ "ខ្ញុំប្រកាសថាទារកតូចបានស្លាប់ នៅព្រឹកនេះនៅម៉ោងប្រាំបួន។ គឺស្លាប់ដោយជំងឺរលាកសួត" ឃើញ? និងដូច្នេះការនោះគឺ—គឺ—គឺពិត។ ពួកគេបានថ្លែងសេចក្តីមក។ វាត្រូវតែបែបនោះ។

321 យើងគួរតែស្មោះត្រង់និងគួរជាទីទុកចិត្តលើអ្វីៗ។ កុំធ្វើវាគ្រាន់តែ...គ្រាន់តែឲ្យវាទៅបែបនោះ។ ចូរឲ្យវា...ព្រះមិនត្រូវការជួយអ្វីឡើយ។ អ្នកឃើញទ្រង់—ទ្រង់—ទ្រង់ជាព្រះ។

322 ដូច្នេះនេះជាអ្វីគាត់និយាយឥឡូវ "ប៉ុន្តែពេលម្តាយនេះហៅបងប្អូនប្រុសប្រានហាំ ពីអាមេរិកឃំដាក់គាត់តាមទូរស័ព្ទ 'សូមមកនិងប្រោសកូនប្រុសខ្ញុំឲ្យរស់ឡើងវិញផង!' និង រដ្ឋាភិបាលសហរដ្ឋអាមេរិក..."

323 ប្តីរបស់គាត់ជាបព្វ ជិតនៃទ័ពអាមេរិក។ និងអ្នក ទាំងអស់គ្នាស្គាល់ហើយជូលៀស (Julius) អ្នករាល់គ្នាជាច្រើន អ្នកស្គាល់សរសេរសំបុត្រខ្ញុំ *ព្យាការីមកទស្សនៈកិច្ចអាហ្វ្រិក*។

324 និងម្តាយតូចន័រវេសមួយគួរឲ្យអាណិត ស្រែកអស់ពីសម្លេងគាត់ និយាយ "បងប្អូនប្រុសប្រានហាំ ខ្ញុំនៅទីនោះពេលដែលកូននោះមានជីវិតរស់វិញ!" និយាយ "យើងជឿលោកថាជាអ្នកបម្រើនៃ...នៃព្រះគ្រីស្ទ" និយាយ "មក សូមដាក់ដៃលើកូនរបស់ខ្ញុំ នោះវានឹងមានជីវិត" ទើបតែស្លាប់នៅថ្មីៗ ឬ ពីរ ដោយជំងឺរលាកសួតឈឺត្រឹមតែបួនម៉ោង ប្រាំ។

325 និងមនុស្សទាំងនេះនៅទីនោះស្រែកបង្អោកនិងស្រែកខ្លាំងៗ និងលោតចុះ-លោត-ឡើងនិយាយ "ព្រះនឹងប្រោសឲ្យរស់! ព្រះនឹងប្រោសឲ្យរស់!" និងនិយាយ...

326 ដោយសេចក្ដីនោះយន្តហោះអាមេរិច-...ឬ មិនមែនមិនមែនយន្តហោះអាមេរិច។ ទ័ពសហរដ្ឋអាមេរិក នឹងបង្ហោះខ្ញុំយកទៅ ដោយយន្តហោះនិងត្រឡប់មកវិញ ក្នុងថ្ងៃ នោះ។ ឃើញ?

327 ហើយខ្ញុំនិយាយ "មុនពេលខ្ញុំមក ចូរឲ្យខ្ញុំស្វែងរកបំណងព្រះអម្ចាស់" ដូច្នេះខ្ញុំអធិស្ឋាន ពីរថ្ងៃ។ ហើយគ្រូពេទ្យនោះចិត្តល្អណាស់ដែលឲ្យក្មេងនោះនៅទីនោះ។

328 ដូច្នេះ ព្រឹកមួយ ខ្ញុំភ្ញាក់ឡើងហើយចាប់ផ្ដើមដើរទៅចង្ក្រាន។ ខ្ញុំមើល ឈរនៅ ទីនោះ ទៅដល់ក៏មានពន្លឺមួយទំហំប្រហែលពន្លឺនេះ រាងជុំវិញនិយាយ"កុំប៉ះអ្វីនោះ។ កុំថាអ្វីអាក្រក់អ្វីនោះ នោះជាព្រះហស្តរបស់ព្រះ។"

329 ខ្ញុំរត់ទៅវិញ និងហៅប្រជាជាតិ ខ្ញុំហៅនិងនិយាយ "ខ្ញុំ—ខ្ញុំមិនអាចមក។"

330 ហើយមានអ្នកដឹកនាំខាង លូធើរៀនម្នាក់និយាយ "ហេតុអ្វីបានជាអ្នកមិនរងចាំរហូតដល់អ្នកទទួលការសម្រេចចិត្ត—កាត់ច្បាស់លាស់ ពីព្រះដូច បងប្អូនប្រុសប្រានហាំធ្វើ? នោះអ្នកនឹងដឹងថាអ្នកនិយាយពីអ្វី។"

331 ឥឡូវ នោះគឺវាបងប្អូនបើវាគ្រាន់តែលោតមកបញ្ចប់ និងរងចាំ និងទទួលរូបភាព ការសម្រេចចិត្ត—ច្បាស់ពីព្រះ។

332 និងទាំងអស់នេះនៅទីនេះ ប្រោសមនុស្សបាបឲ្យជាដែលមិនស្គាល់អ្វីសោះពីព្រះ។ ខ្ញុំជឿថាការប្រោសឲ្យជារបស់ព្រះអាស្រ័យលើគោលការណ៍ ដែលអ្នកគួរមកឯព្រះ ជាដំបូង និងថ្វាយចិត្តដល់ទ្រង់ និងលាងសំអាតជីវិតរបស់អ្នកដោយលោហិតព្រះយេស៊ូវគ្រីស្ទ និងដូច្នេះព្រះទ្រង់នឹងធ្វើការជាមួយអ្នកនិងប្រោសអ្នកឲ្យជា។ ដូចបងប្អូនប្រុសនេះនិយាយ ពីស្ត្រីតូចមួយដែលជួយអធិស្ឋាននៅទីនោះ ជាអ្នកបរិសុទ្ធរបស់ព្រះ អ្នកឃើញ។

333 ក្នុងជីវិតរបស់ខ្ញុំ ខ្ញុំធ្វើខុសជាច្រើន។ ខ្ញុំធ្វើរឿងជាច្រើនដែលខុស។ ខ្ញុំប្រហែលបើសិនជាខ្ញុំរស់នៅយូរទៀត។ ខ្ញុំនឹងធ្វើខុសច្រើនទៀត។ ប្រហែលមានកំហុសខ្លះនឹងរាំងខ្ទប់ផ្លូវរបស់អ្នកផង។ ខ្ញុំសង្ឃឹមថាអ្នកអត់ទោសដល់ខ្ញុំ។

334 ខ្ញុំអានពីរឿងអ័ប្រាហាំ ពីភាពវង្វេងរបស់គាត់ដែលបានធ្វើ។ របៀបដែលគាត់របស់ខ្ញុំ អ្វីដែលគាត់ធ្វើ គាត់សង្ស័យព្រះជាម្ចាស់ និងគាត់កុហកពីប្រពន្ធរបស់គាត់ និងគ្រប់យ៉ាង។ ប៉ុន្តែពេលសេចក្ដីណែនាំរបស់គាត់ពីព្រះដែលសរសេរក្នុងគម្ពីររ៉ូមជំពូក4 វាមិនដែលបង្ហាញបញ្ជាក់កំហុសរបស់គាត់ឡើយ ប៉ុន្តែនិយាយ "អ័ប្រា

ហាំមិនរោ៉″ អ្វីដែលគាត់ជឿ...តាមរយៈព្រះ "ប៉ុន្តែមានភាពខ្លាំងវិញ″ រាល់កំហុសរបស់គាត់គឺត្រូវបានបំភ្លេច ពេលដែលមានសេចក្តីណែនាំពីព្រះពីជីវិតគាត់ដែលបានកត់ទុក។ ភាពវង្វេងរបស់គាត់មិនបានបង្ហាញឡើយ។ កំហុសរបស់គាត់ក៏មិនបានបញ្ជាក់មកដែរ។

335 និង បងប្អូនប្រុស ខ្ញុំសង្ឃឹម ថាពេលមានសេចក្តីណែនាំដែលបានអាននៅថ្ងៃនោះ នោះទ្រង់នឹងលុបកំហុសខ្ញុំចេញដែរ និងមិនគិតពីវាសោះឡើយ។ ខ្ញុំសង្ឃឹមថាអ្នកធ្វើដែរ។ សូមព្រះប្រទានពរអ្នក។

336 [ដុកទ័រថមីហ៊ិក(Tommy Hicks) ទៅកាន់មេក្រូហ្វូន ដើម្បីណែនាំបន្ទាប់—Ed។]។

[ខ្ញុំគិតថាយើងអាចនិយាយនៅព្រឹកនេះដើម្បីបូកសរុបគ្រប់យ៉ាងដែលបាននិយាយក្នុងពាក្យទាំងនោះ: ព្រះគ្រីស្ទនៅក្នុងក្តីសង្ឃឹម នៃសិរីរុងរឿងរបស់ខ្ញុំ។ និយាយពួកវា សូមនិយាយ។ ព្រះគ្រីស្ទក្នុងខ្ញុំជាក្តីសង្ឃឹមនៃសិរីរុងរឿង]។

មានទាំងក្នុង—និង—ក្រៅ និងលើសទៀតនៅក្នុងជីវិតមនុស្សម្នាក់ៗ។ (ខ្ញុំនឹងនិយាយ) ខ្ញុំមានសារ។ ខ្ញុំជឿថាគ្រប់គ្រីស្ទបរិស័ទមាន...?...ព្រះយេស៊ូវ...?...ចិត្តរបស់ខ្ញុំមានការជំរុញនៅព្រឹកនេះ និងខ្ញុំជឿថាសម្រាប់មាន គ្នាយើងជាច្រើនមានអ្វីដែលរំខានយើង...?...ធ្វើឲ្យយើង ក្លាយជាអ្នកបម្រើប្រុស ស្រីរបស់ព្រះកាន់តែប្រសើរ ឡើង]

[កូនង៉ែតនាងរស់(Babe Ruth)ត្រូវបាន ស្គាល់ជាស្តេចហូមរ៉ុន(Homerun)។ ប៉ុន្តែអ្នកមិនដឹងទេឬថាកូនង៉ែតនាងរស់ (Babe Ruth) ក៏ជាស្តេចដែលគេដេញចេញដែរ? គាត់ត្រូវបានដេញឆ្ងាយច្រើនដងជាងការនៅក្នុងផ្ទះទៅទៀត។ គាត់ត្រូវបានគេទាត់ចោល1330ដង គាត់នៅក្នុងផ្ទះបានត្រឹមតែ860ដងប៉ុណ្ណោះ។ ប៉ុន្តែគ្រប់ពេលដែល (Babe Ruth)ត្រូវបានទាត់ចោល គាត់ត្រឡប់ទៅវិញដើម្បីស្វែងរកគ្រូបង្វឹកពេលដែលអាជ្ញាកណ្តាលស្រែកថា "អ្នកត្រូវដេញចេញ″ គាត់ត្រឡប់ទៅរកគ្រូបង្វឹកវិញនិងដុសដៃហើយចាប់កាន់ដំបងចង្អុលទៅកាន់របងនិងនិយាយ "ខ្ញុំមានអារម្មណ៍ថាសោកស្តាយចំពោះក្អមដែលនៅទីនោះ″]

[មិនជាអ្វីខុសទេក្នុងការដេញចេញប៉ុន្តែសូមចាំ: ជ្រើយយកដំបង...?...ព្រោះព្រះគ្រីស្ទគង់ក្នុងខ្ញុំក្តីសង្ឃឹមនៃសិរីរុងរឿង សូមនិយាយវាម្តងទៀត: ព្រះគ្រីស្ទគង់ក្នុងខ្ញុំក្តីសង្ឃឹមនៃសិរីរុងរឿង។ វាជាអ្វីៗទាំងអស់]

បាទ

[វាជាអ្វីៗទាំងអស់]។

នោះគឺត្រឹមត្រូវ។

[វាជាអ្វីៗទាំងអស់]។

អ្វីៗទាំងអស់ ។ អេម៉ែន។

[ហាលេលូយ៉ា។ ការជជែកឈ្លោះនិងជម្លោះនឹងមិនមានទៀយ។ យើងបានទៅជិត...]

អេម៉ែន

[...ផ្នែកផ្សេងទៀត។ យើងទៅកាន់ចំណុចដែលមិនត្រឡប់ក្រោយ។ តើប៉ុន្មានដងដែលខ្ញុំបានឮលោកប្រធានហៅយន្តហោះឲ្យត្រឡប់មកវិញ "នោះមានន័យថាខ្ញុំបានទៅជិតផ្នែកម្ខាងទៀតជាងខ្ញុំចាប់ផ្តើមចំណុចចាកចេញ]។"

[មិនជាយូរប៉ុន្មានខ្ញុំបានឮសំលេងពីពិភពមួយទៀតបាននិយាយមកកាន់ខ្ញុំនិងនិយាយថា "កូនប្រុស អ្នកបានដល់ចំនុចដែលមិនអាចត្រឡប់វិញបាន។" មានន័យថាខ្ញុំខិតជិតទៅនឹងចំនុចមួយទៀតជាងចំនុចដែលខ្ញុំចាប់ផ្តើម]

[សូមបិទភ្នែករបស់អ្នក សូមឱនក្បាល]។

[ព្រះបិតាដែលគង់ស្ថានរបស់ទូលបង្គំ ព្រឹកនេះ ពិតជាអរព្រះគុណនិងដឹងគុណដែលទូលបង្គំអាច និយាយបានយ៉ាងជ្រៅពីចិត្ត និងពីជម្រៅព្រលឹងនៃទូលបង្គំ "ព្រះគ្រីស្ទគង់ក្នុងទូលបង្គំ—ព្រះគ្រីស្ទគង់ក្នុងទូលបង្គំ ក្តីសង្ឃឹមនៃសិរីរុងរឿង" អូ ព្រះយេស៊ូវ សូមដាក់ព្រះហស្តសេចក្តីស្រឡាញ់របស់ទ្រង់ជុំវិញបុរសម្នាក់ៗនិងស្ត្រីគ្រប់គ្នា និងសូមឲ្យនិមិត្ត និងការមើលឃើញ របស់ទូលបង្គំងើបឡើងខ្ពស់ឡើង—ខ្ពស់ ខ្ពស់ឡើងជាងអ្វីៗនៅលោកកិយនេះ ដែលអាចឲ្យឃើញព្រះគ្រីស្ទ និងអ្នកផ្សេងអាចឃើញព្រះគ្រីស្ទក្នុងពួកទូលបង្គំ។ សូមដាក់ព្រះហស្តលើទូលបង្គំម្នាក់ៗនៃមនុស្សទាំងនេះជាអ្នកបម្រើទ្រង់...]

សូមទទួលវា ព្រះអម្ចាស់

[...នោះសូមឲ្យ ពេលទូលបង្គំចេញពីទីនេះនៅព្រឹកនេះដែលទូលបង្គំកំណត់ឲ្យឃើញព្រះគ្រីស្ទតែមួយគត់...]

អាម៉ែន

[...គឺជាការស្វាគមន៍ ក្នុងចំណោមគ្នា។ យើងដឹងតួនាទីជា—មានតួនាទីធំឲ្យសម្រេច ព្រះយេស៊ូវ មានចម្រូតយ៉ាងធំដែលត្រូវច្រូត]។

មែនហើយ ព្រះអម្ចាស់។

[អូ សូមជួយពួកទូលបង្គំ...]

មែនហើយ ព្រះអម្ចាស់

[...ទូលបង្គំនឹងរួមដៃគ្នា...]

សូមទទួលយក ព្រះអម្ចាស់

[...និងទៅប្រមូលផលចម្រូត...]

មែនហើយ ព្រះអម្ចាស់

[...ដើម្បីឈោងចាប់អ្នកបាត់បង់និងអ្នកកំពុងស្លាប់មិនយឺតពេល]។

មែនហើយ ព្រះអម្ចាស់

[ខ្ញុំចង់ឲ្យអ្នកលើកដៃរបស់អ្នក និងសសើរព្រះនាមនៃព្រះអម្ចាស់របស់យើងព្រះយេស៊ូវគ្រីស្ទ]។

[បងប្អូនប្រុសប្រានហាំនិងមនុស្សសរសើរព្រះអម្ចាស់]។

[គួរឲ្យយើងក្រោកឈរ។ ខ្ញុំចង់ឲ្យបងប្អូនលើកដៃនិងច្រៀងជាមួយខ្ញុំ "ខ្ញុំស្រឡាញ់ ទ្រង់។" តើអ្នកស្រឡាញ់ទ្រង់...]

អែមែន

[...ព្រឹកនេះ? តើអ្នកស្រឡាញ់ទ្រង់អស់ពីចិត្តទេ សូមលើកដៃ និងច្រៀងទាំងអស់គ្នា "ខ្ញុំស្រឡាញ់ទ្រង់"]

[ខ្ញុំស្រឡាញ់ទ្រង់ ខ្ញុំស្រឡាញ់ទ្រង់]
[ព្រោះទ្រង់ស្រឡាញ់ទូលបង្គំមុន]
[និងទិញសេចក្តីសង្គ្រោះរបស់ទូលបង្គំ]
[នៅដើមឈើកាល់វ៉ារី]

[សូមអ្នកគ្រហឹម...]

[អ្នកដឹងហើយ អ្នកដឹកនាំដែលរួមគ្នា នៅអាហ្សង់ទីន យើងមានមនុស្ស ច្រើនជាង 400 000 នាក់ក្នុងកម្មវិធីមួយ ពេលមួយទៅពេលមួយយើងឃើញ មនុស្ស។ និងខ្ញុំចងចាំ រសៀលថ្ងៃទីមួយ យើងមានមនុស្សជាង 400 000នាក់ ដែលច្រៀងជាភាសាអេស្ប៉ាញហើយខ្ញុំត្រូវច្រៀងគ្រហឹមហើយមនុស្សនៅខាងក្រៅ មានមនុស្ស ជាង 300 000 នាក់។ យើងសុំឲ្យមនុស្សខាងក្នុងនៅស្ងៀម ពេលដែលមនុស្សនៅ ខាងក្រៅគ្រហឹមពាក្យនៃចម្រៀង]។ ហើយពេលដែល ពួកគេកំពុងច្រៀង មានអ្វីមួយជន់មកក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំមិនដឹងថាជាការបើក សម្ដែងរបស់ព្រះគ្រីស្ទរហូតដល់ខ្ញុំឮសម្លេងបន្ទ រ300000 នាក់ខាងក្រៅកំពុង គ្រហឹមបទចម្រៀង។ "ខ្ញុំស្រឡាញ់ទ្រង់" ខាងក្រៅ...?...ព្រឹកនេះគឺជាទ័ព យ៉ាង មានអំណាចនៃស្ដេចនៃសិរីរុងរឿង និងពួកគេកំពុងច្រៀង។ តើពួកគេស្រឡាញ់ នរណា? ពួកគេស្រឡាញ់នរណា?]

មែន

[ព្រះគ្រីស្ទ ព្រះគ្រីស្ទក្នុងខ្ញុំ]

មែន

[សេចក្ដីសង្ឃឹមនៃសិរីរុងរឿង ។ បិទភ្នែករបស់អ្នក លើកដៃរបស់អ្នក និងច្រៀង ម្ដងទៀត គ្រប់គ្នា]

មែនហើយព្រះអម្ចាស់

[ខ្ញុំស្រឡាញ់ទ្រង់]
[ព្រោះទ្រង់ស្រឡាញ់ទូលបង្គំមុន]
[និងទិញសេចក្ដីសង្គ្រោះរបស់ទូលបង្គំ]
[នៅដើមឈើកាល់វ៉ារី]

[បើអ្នកស្រឡាញ់ទ្រង់នៅព្រឹកនេះ សូមកាន់ដៃមនុស្សបីបួននាក់ និងស្រីៗធ្វើ ដូចគ្នា និងនិយាយ "ខ្ញុំស្រឡាញ់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ" នោះគឺត្រឹមត្រូវហើយ ដាក់ដៃជុំវិញ...—Ed។]

337 បើសិនជាខ្ញុំអាចឃើញការនេះកើតឡើងពេញពិភពលោក ខ្ញុំនិយាយ "ព្រះអម្ចាស់ សូមអ្នកបម្រើរបស់ទ្រង់ចាកចេញទៅដោយស្ងប់ចិត្ត!"

## សេចក្តីពោរពេញរបស់ព្រះត្រូវបានពន្យល់ KHM61-0425B

(The Godhead Explained)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹក ថ្ងៃអង្គារ ថ្ងៃទី 25 មេសា 1961 នៅ Holiday Inn, Chicago, Illinois, U.S.A.។ រាល់ការខិតខំត្រូវបានធ្វើឡើង ដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លងនិង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារ ខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2020 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG